ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# កត្តាដែលធ្វើឱ្យសិស្សបោះបង់ការសិក្សានៅបឋមសិក្សា

## ករណីសិក្សា៖ ខេត្តកំពង់ធំ

**Factor That Make Students Dropout at Primary School**

**Case Study: Kampong Thom Province**


ដោយ/By

កុយ វ៉ាឡង់ទីណា/Mr. KOY VALENTINA


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០១៧ - ២០១៨


ឧបត្ថម្ភដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation (CIESF)

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


## វិទ្យាស្ថានជាតិអប់រំ

National Institute of Education


## និក្ខេបបទ

# កត្តាដែលធ្វើឱ្យសិស្សបោះបង់ការសិក្សានៅបឋមសិក្សា

## ករណីសិក្សា៖ ខេត្តកំពង់ធំ

**Factor That Make Students Dropout at Primary School**

**Case Study: Kampong Thom Province**


**ដោយ/By**

**កុយ វ៉ាឡង់ទីណា**/Mr KOY VALENTINA


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា២០១៧ - ២០១៩**


**សាស្ត្រាចារ្យដឹកនាំ៖ ឯកឧត្តមបណ្ឌិត ជ័យ សារិន**

**សាស្ត្រាចារ្យដឹកនាំរង៖ លោកស្រី ប៊ុន សុផានី**



**ឆ្នាំសិក្សា២០១៧ - ២០១៩**

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**កត្តាដែលធ្វើឱ្យសិស្សបោះបង់ការសិក្សានៅបឋមសិក្សា**" សម្រាប់បំពេញលក្ខខណ្ឌបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។ ស្នាដៃនេះពុំទាន់ត្រូវបានប្រើដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ ឬសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ឬខ្លឹមសារណាមួយត្រូវបានប្រើក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធឬពុំបានចុះបញ្ជីឯកសារយោងឡើយ។និក្ខេបបទស្រាវជ្រាវនេះ គឺពិតជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទ ពិតប្រាកដមែន។

ថ្ងៃសុក្រ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០
ហត្ថលេខាបេក្ខជន

**កុយ ទ៉ាឡង់ទីណា**

# លិខិតបញ្ជាក់

ឯកឧត្តមបណ្ឌិត **ជ័យ សារិន** ជាសាស្ត្រាចារ្យដឹកនាំ

លោកស្រី **ម៉ិន សុផានី** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

**លោក កុយ វ៉ាឡង់ទីណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**កត្តាដែលធ្វើឱ្យសិស្សបោះបង់ការសិក្សានៅបឋមសិក្សា**" ពិតប្រាកដមែន។

ថ្ងៃសុក្រ៨រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០

| | |
|---|---|
| ........................................ | ........................................ |
| **ឯកឧត្តមបណ្ឌិត ជ័យ សារិន** | **លោកស្រី ម៉ិន សុផានី** |
| អគ្គាធិការនៃអគ្គាធិការដ្ឋាន | នាយិការងវិទ្យាស្ថានជាតិអប់រំ |

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ អ្នកមានគុណទាំងពីរ បងប្អូន និងមិត្តភក្តិទាំងអស់ដែលបានជួយឧបត្ថម្ភគាំទ្រទាំងផ្នែកថវិកា សម្ភារៈ ចិត្ត គំនិត ប្រាជ្ញា និងផ្នែកស្មារតីដល់ខ្ញុំបាទខណៈពេលសិក្សានាពេលកន្លងមក។

ខ្ញុំបាទសូមអនុញ្ញាតគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងថ្នាក់ដឹកនាំប្រទេសគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំកសាងប្រទេសជាតិឱ្យមានសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍលើគ្រប់វិស័យរហូតមកដល់បច្ចុប្បន្ននេះ(ប្រទេសជាតិមានសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍ ទើបការអប់រំមានភាពសម្បូរបែប ល្អប្រសើរ មានគុណភាព និងមានការប្រកួតប្រជែងក្នុងតំបន់ និងសកលលោក)។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះក្រសួងអប់រំ យុវជន និងកីឡា និងថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់ក្រសួងអប់រំ ដែលបានខិតខំប្រឹងប្រែងយ៉ាងសស្រាក់សស្រាំក្នុងការកសាងនិងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ឱ្យមានភាពល្អប្រសើរគួរជាទីមោទនៈ(ពោលគឺការកសាងធនធានមនុស្សពេញលេញជូនជាតិមាតុភូមិ)។

ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងក្រៃលែងដល់វិទ្យាស្ថានជាតិអប់រំ ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃវិទ្យាស្ថានជាតិអប់រំ និងជាពិសេសអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (Cambodia International Education Support Foundation, CIESF) ដែលបានរៀបចំកម្មវិធី និងផ្ដល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនេះឡើង និងផ្ដល់ឱកាសសម្រាប់ខ្ញុំបាទបានប្រឡងជាប់ ហើយបានចូលសិក្សានៅវិទ្យាស្ថានជាតិអប់រំ ក្នុងឆ្នាំសិក្សា(២០១៧-២០១៩) នាពេលកន្លងទៅថ្មីៗនេះ។

ខ្ញុំបាទសូមគោរពថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ គណៈកម្មការគ្រប់គ្រងនិងដឹកនាំការបណ្ដុះបណ្ដាលវគ្គសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំគ្រប់លំដាប់ថ្នាក់ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រីជាសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃផ្ទេរចំណេះដឹង បំណិន ឥរិយាបថ បទពិសោធ និងមេរៀនជីវិតល្អៗជាច្រើន ពិសេសលើផ្នែកគ្រប់គ្រងដឹកនាំ ការរៀបចំ និងធ្វើផែនការក្នុងវិស័យអប់រំមកដល់ខ្ញុំបាទផ្ទាល់និងមិត្តរួមជំនាន់ដទៃទៀតដូចៗគ្នានិងស្មើៗគ្នា។ ជាពិសេស ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងអនេកដែលរកអ្វីមកប្រៀបផ្ទឹមពុំបានជូនចំពោះលោកសាស្ត្រាចារ្យបណ្ឌិត **ជ័យ សារិន** ជា

សាស្ត្រាចារ្យណែនាំ និងលោកស្រី **ប៊ុន សុផានី** ជាសាស្ត្រាចារ្យជំនួយ ដែលលោកទាំងទ្វេរតែងតែចំណាយពេលដ៏មានតម្លៃពន្យល់ណែនាំពីចំណុចគន្លឹះល្អៗពីដំណាក់កាលមួយទៅដំណាក់កាលមួយ និងគ្រប់ជំហានទាំងអស់រហូតទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបានសម្រេចជោគជ័យ បញ្ចប់យ៉ាងរលូន ប្រកបដោយគុណភាព និងប្រសិទ្ធភាពសម្រាប់បម្រើឱ្យការអភិវឌ្ឍវិស័យអប់រំកម្ពុជា។ មួយចំណែកទៀត ខ្ញុំបាទសូមថ្លែងអំណរគុណចំពោះ លោក លោកស្រីជាមិត្តរួមជំនាន់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំទាំងអស់ ខ្ញុំពិតជាមានមោទនភាពដែលមានលោក លោកស្រីជាមិត្ត ព្រោះលោកអ្នកទាំងអស់គ្នា ជាមនុស្សដែលមានសមានចិត្តល្អ ក្នុងការចែករំលែកនូវចំណេះដឹង បំណិន ឥរិយាបថ បទពិសោធ និងមេរៀនជីវិតល្អៗសម្រាប់ខ្ញុំ។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់ គណៈគ្រប់គ្រងមន្ទីរអប់រំខេត្ត ការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងសាលា បុគ្គលិកទីចាត់ការ លោកគ្រូ អ្នកគ្រូ ព្រមទាំងមាតាបិតា អាណាព្យាបាលសិស្ស នៅក្នុងខេត្តកំពង់ធំ ដែលបានសហការនិងសម្របសម្រួល យ៉ាងល្អប្រសើរក្នុងដំណើរការចុះប្រមូលទិន្នន័យ ដែលជាកត្តារួមចំណែកមួយយ៉ាងធំធេង ក្នុងការធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំទទួលបានលទ្ធផលជោគជ័យមួយរយភាគរយ។

ខ្ញុំបាទសូមឧទ្ទិសនូវស្នាដៃស្រាវជ្រាវនេះ ជូនចំពោះដួងវិញ្ញាណក្ខន្ធបុព្វបុរសខ្មែរគ្រប់សម័យកាល ដែលបានតស៊ូដើម្បីបុព្វហេតុជាតិមាតុភូមិ និងជូនចំពោះដួងវិញ្ញាណក្ខន្ធញាតិការប្រាំពីរសន្តានដែលបានបែកកាយរំលាយក្ខន្ធទៅកាន់បរលោកហើយនិងសូមលោកទាំងនោះបែរភក្ត្រាងាកក្រោយឱ្យពរជ័យដល់ប្រទេសកម្ពុជាប្រកបដោយសន្តិភាព និងការអភិវឌ្ឍ។

ជាទីបញ្ចប់ ខ្ញុំបាទសូមបួងសួងដល់អស់វត្ថុស័ក្តិសិទ្ធិក្នុងលោក ពិសេសក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រសិទ្ធិពរជ័យសិរីបវរមហាប្រសើរ ជូនចំពោះលោកអ្នកមានគុណទាំងពីរនិងអ្នកទាំងអស់គ្នា សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងកាយ ប្រាជ្ញា និងស្មារតីមាំមួន ភ្លឺថ្លា មានសេចក្តីសុខ និងសេចក្តីចម្រើន រកទទួលទានមានបាន កើតកាលវាលគុម្ព ត្រជាក់ត្រជុំ សុខដុមរមនា និងម្រេចបានជោគជ័យគ្រប់ភារកិច្ចជានិច្ចនិរន្តរ៍ និងជួបប្រសប់នូវពុទ្ធពរទាំងបួនប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ!***

# មូលន័យសង្ខេប

យើងបានដឹងហើយថា មានមូលហេតុជាច្រើន ដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សានៅកម្រិតបឋមសិក្សា។មូលហេតុខ្លះ ជាមូលហេតុដែលមានតែក្នុងសហគមន៍ ឬក្នុងប្រទេសតែប៉ុណ្ណោះ។ ការសិក្សាស្រាវជ្រាវមានគោលបំណងស្វែងរកបញ្ហាមួយចំនួនដែលបណ្តាលឱ្យសិស្សបោះបង់ នៅកម្រិតបឋមសិក្សាក្នុងតំបន់ជនបទ និងតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា ដោយប្រើករណីសិក្សា នៅក្នុងកម្រងពីរនៃសាលាបឋមសិក្សា ក្នុងស្រុកបារាយណ៍ និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ករណីសិក្សានេះស្វែងយល់បន្ថែមដែរ អំពីវិធានការ និងកំណែលម្អមួយចំនួនដែលក្រសួងអប់រំ យុវជន និងកីឡា និងសាលារៀនធ្លាប់បានអនុវត្តកន្លងមកដើម្បីជួយកាត់បន្ថយសិស្សបោះបង់ការសិក្សា។

ករណីសិក្សានេះ បានប្រើទាំងវិធីសាស្រ្តស្រាវជ្រាវបែបបរិមាណវិស័យ និងបែបគុណវិស័យ។ ដើម្បីឆ្លើយតបនឹងគោលបំណងខាងលើ យើងខ្ញុំបានបង្កើតកម្រងសំណួរពីរសម្រាប់សម្ភាសជាមួយសិស្ស និងមាតបិតា ឬអាណាព្យាបាលសិស្សបោះបង់ការសិក្សា ហើយទិន្នន័យ និងប្រភពព័ត៌មានមួយចំនួនទៀត ត្រូវបានប្រមូលពីលោកនាយកនាយិកាសាលា លោកគ្រូ អ្នកគ្រូ ប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីប្រើប្រាស់បំពេញបន្ថែម។ទិន្នន័យដែលយើងប្រមូលបានត្រូវធ្វើការវិភាគដោយឡែកពីគ្នារវាងសិស្សនិងមាតាបិតាសិស្សបោះបង់ហើយប្រៀបធៀបជាមួយព័ត៌មានដែលយើងប្រមូលបានពីប្រភពផ្សេងៗ។ លទ្ធផលសិក្សានេះនឹងធ្វើការប្រៀបធៀបផងដែរជាមួយការសិក្សាដែលមានស្រាប់។

ករណីសិក្សានេះបានរកឃើញថា សិស្សបោះបង់មួយចំនួនបណ្តាលមកពីបញ្ហាជាច្រើន(ឧបសម្ព័ន្ធ)ដែលយ៉ាងហោចណាស់ក៏មានកត្តាធំៗចំនួន៤ដែលមានឥទ្ធិពលខ្លាំងជាងគេក្នុងការធ្វើឱ្យសិស្សមួយចំនួននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាលបោះបង់ការសិក្សា ហើយមាតាបិតាក្មេងទាំងនោះក៏ជាអ្នកមានឥទ្ធិពលមួយផងដែរ ដែលធ្វើឱ្យពួកគេបោះបង់។ ក្នុងចំណោមកត្តាធំៗទាំងនោះរួមមាន ជីវភាពគ្រួសារ បញ្ហាអាយុ និងភេទ កត្តាសាលារៀន និងគ្រូបង្រៀន កត្តាសង្គម និងកត្តាសិស្សខ្លួនឯងផ្ទាល់។ ករណីសិក្សានេះរកឃើញផងដែរថា បរិយាកាសនយោបាយសង្គមមានឥទ្ធិពលទៅលើការអនុវត្តប្រកបដោយជោគជ័យ នៃប្រព័ន្ធអប់រំនៅកម្ពុជា។

បញ្ហាសិស្សបោះបង់ការសិក្សាក្នុងប្រទេសកម្ពុជា តម្រូវឱ្យមានការយកចិត្តទុដាក់ពីគ្រប់ភាគីអ្នកពាក់ព័ន្ធទាំងអស់ ទាំងផ្នែករដ្ឋ ទាំងផ្នែកឯកជន ទាំងអង្គការជាតិ អន្តរជាតិ ទាំងសហគមន៍ ពិសេសសិស្សខ្លួនឯង។

Abstract

We already know that there are many reasons why students drop out of primary school. The study aims to explore some of the causes of students dropping out of primary school in rural and remote areas of Cambodia, using case studies in two primary schools in Baray and Kampong Svay districts, Kampong Thom. The case study also explores some of the measures and improvements that the Ministry of Education, Youth and Sport, and schools have implemented to help reduce student dropout.

The case study uses both quantitative and qualitative research methods. To meet the above objectives, we created two questionnaires for interviews with students and parents or guardians of dropout students, and some other information and resources were collected from the principal, teachers, teachers, community members for use. The data we collect is analyzed separately by students and parents Dropout, and compared with the information we collect from other sources. The result of this study will compare well with existing studies.

The case study found that some dropouts were caused by problems (annexation), with at least four major factors influencing the dropout in some rural and remote areas. Education and their parents are also influencers that make them drop out sex schools and teacher factors, social factors and factors students themselves. The case study also found that the socio-political environment influences the successful implementation of the education system in Cambodia.

The problem of dropouts in Cambodia requires the attention of all stakeholders,both public and private, national and international organizations, and especially the students themselves.

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........................................ I

លិខិតបញ្ជាក់ពីសាស្ត្រាចារ្យ ........................................ II

សេចក្តីថ្លែងអំណរគុណ ........................................ III

មូលន័យសង្ខេប ........................................ V

Abstract ........................................ VI

បញ្ជីតារាង ........................................ X

បញ្ជីក្រាប ........................................ XI

បញ្ជីអក្សរកាត់ ........................................ XII

**ជំពូកទី១៖**

**សេចក្តីផ្តើម** ........................................ 1

១.១លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ 1

១.២ចំណោទបញ្ហានៃការស្រាវជ្រាវ ........................................ 7

១.៣សំណួរស្រាវជ្រាវ ........................................ 9

១.៤គោលបំណងស្រាវជ្រាវ ........................................ 9

១.៥សារៈសំខាន់នៃការស្រាវជ្រាវ ........................................ 9

១.៦ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................ 10

១.៧រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ 11

**ជំពូកទី២៖**

**រំលឹកទ្រឹស្តី** ........................................ 12

២.១ការអប់រំទូទៅនៅកម្ពុជា ........................................ 12

២.២ការអប់រំនៅកម្ពុជា និងបញ្ហាប្រឈម ........................................ 12

២.៣ការបោះបង់ការសិក្សា ........................................ 14

២.៣.១កត្តាចម្ងាយផ្លូវ និងថ្នាក់រៀនមិនគ្រប់កម្រិត....14
២.៣.២ភាពក្រីក្រ....14
២.៣.៣ការសិក្សាមានតម្លៃខ្ពស់....16
២.៣.៤កត្តាគ្រូបង្រៀន និងសម្ភារៈ....16


**<u>ជំពូកទី៣៖</u>**

**វិធីសាស្ត្រស្រាវជ្រាវ**.... 21
៣.១វិធីសាស្ត្របែបគុណវិស័យ.... 21
៣.២វិធីសាស្ត្របែបបរិមាណវិស័យ.... 21
៣.៣ការជ្រើសរើសសាលាគោលដៅ.... 21
៣.៤កម្រងសំណួរស្រាវជ្រាវ.... 22
៣.៥គំរូសំណាក.... 23
៣.៦ការវិភាគទិន្នន័យ.... 25
៣.៧ក្រមសីលធម៌អ្នកស្រាវជ្រាវ.... 25


**<u>ជំពូកទី៤៖</u>**

**លទ្ធផលស្រាវជ្រាវ**.... 27
៤.១របកគំហើញពីកម្រងសំណួរ(សិស្ស).... 27
៤.១.១កត្តាជីវភាពគ្រួសារ(ភាពក្រីក្រ)....29
៤.១.២បញ្ហាអាយុ និងភេទ....35
៤.១.៣កត្តាសាលារៀន និងសង្គម....37
៤.១.៤កត្តាសិស្សផ្ទាល់....40
៤.២របកគំហើញពីកម្រងសំណួរពីមាតាបិតាសិស្ស.... 41
៤.២.១កត្តាគ្រួសារ និងកត្តាសិស្សផ្ទាល់....43
៤.២.២កត្តាសាលារៀន និងកត្តាគ្រូបង្រៀន....46
៤.២.៣កត្តាសង្គម....48
៤.៣ការពិភាក្សា.... 48

៤.៣.១កត្តាគ្រួសារ ....48
៤.៣.២កត្តាសាលារៀន និងសង្គម....50
៤.៣.៣កត្តាសិស្សផ្ទាល់....51

**<u>ជំពូកទី៥៖</u>**

**សន្និដ្ឋាន និងសំណូមពរ**.... 52

៥.១សង្ខេបរបកគំហើញ .... 52

៥.១.១កត្តាជីវភាពគ្រួសារ ....52
៥.១.២បញ្ហាអាយុ និងភេទ ....52
៥.១.៣កត្តាសាលារៀន និងសង្គម....53
៥.១.៤កត្តាសិស្សផ្ទាល់ និងមាតាបិតា ....53

៥.២សន្និដ្ឋាន .... 54

៥.៣សំណូមពរ .... 54

**ឯកសារយោង**.... 55

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាងទី១ កំណើនសិស្សទៅមធ្យមសិក្សា ........................................................... 8

តារាងទី២ ទិន្នន័យសិស្សបោះបង់ការសិក្សាពីឆ្នាំ២០១៧-២០១៨ក្នុងខេត្តកំពង់ធំ ...... 17

តារាងទី៣ អត្រាចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យរបស់សិស្សថ្នាក់ទី៦(គិតជា%)ក្នុងឆ្នាំសិក្សា២០១៦-២០១៦............................................................................ 18

តារាងទី៤ ចំនួនសិស្សបោះបង់តាមក្រុមអាយុ និងតាមថ្នាក់ ..................................... 23

តារាងទី៥  ចំនួនសិស្សបោះបង់តាមភេទ តាមសាលាគោលដៅ ............................. 23

តារាងទី៦  ចំនួនបងប្អូនបង្កើតរបស់សិស្សបោះបង់ ................................................ 24

តារាងទី៧ អត្រាបោះបង់ការសិក្សាកុមារា និងកុមារីនៅបឋមសិក្សា ........................ 36

# បញ្ជីក្រាប


ក្រាបទី១៖អ្នកដែលសម្រេចចិត្តឱ្យសិស្សបោះបង់ ....................................................27

ក្រាបទី២៖ស្ថានភាពការងារដែលពួកគេបានធ្វើក្រោយពីបោះបង់ការសិក្សា.............. 28

ក្រាបទី៣៖បង្ហាញពីការឈប់រៀនដើម្បីជួយរកប្រាក់ចំណូលគ្រួសារ......................... 30

ក្រាបទី៤៖បង្ហាញពីមូលហេតុឈប់រៀនដើម្បីជួយការងារផ្ទះ .................................. 33

ក្រាបទី៥៖បង្ហាញពីមូលហេតុនៃការបោះបង់ដោយការចំណាយលើការសិក្សា .......... 34

ក្រាបទី៦៖បង្ហាញពីទំនាក់ទំនងរវាងសាលារៀនជាមួយមាតាបិតាសិស្ស .................. 41

ក្រាបទី៧៖បង្ហាញពីទំនាក់ទំនងរវាងសាលារៀនជាមួយមាតាបិតាសិស្ស.................. 42

ក្រាបទី៨៖បង្ហាញមូលហេតុនៃការបោះបង់ដោយរកប្រាក់ចំណូលមិនគ្រប់គ្រាន់........ 43

ក្រាបទី៩៖បង្ហាញមូលហេតុនៃការបោះបង់ដោយសារគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ការសិក្សារបស់កូន ...................................................................................... 44

ក្រាបទី១០៖បង្ហាញមូលហេតុនៃការបោះបង់ព្រោះជួយធ្វើកិច្ចការផ្ទះ ....................... 45

# បញ្ជីអក្សរកាត់

| | |
|---|---|
| UNDP | កម្មវិធីអភិវឌ្ឍសហប្រជាជាតិ |
| UNFPA | មូលនិធិសហប្រជាជាតិសម្រាប់សកម្មភាពប្រជាជន |
| UNICEF | មូលនិធិបន្ទាន់សម្រាប់កុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ |
| WORLD BANK | ធនាគារពិភពលោក |
| KAPE | កម្មភាពកម្ពុជាសម្រាប់ការអប់រំបឋមសិក្សា |
| EMIS | ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ |
| EFA | ការអប់រំសម្រាប់ទាំងអស់គ្នា |
| ADB | ធនាគារអភិវឌ្ឍអាស៊ី |
| UNESCO | អង្គការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌របស់អង្គការសហប្រជាជាតិ |
| ESP | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |

# ជំពូកទី១៖
# សេចក្តីផ្តើម

# ជំពូកទី១៖
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រព័ន្ធអប់រំចំណេះទូទៅនៅកម្ពុជា បានឆ្លងកាត់សម័យកាលជាច្រើនក្នុងចុងសតវត្សទី២០ និងដើមសតវត្សទី២១។ នៅមុនឆ្នាំ១៩៧៥ ប្រព័ន្ធអប់រំចំណេះទូទៅមានរយៈពេល១៣ឆ្នាំគឺ(៦+៤+២+១) ប៉ុន្តែ នៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំគ្រប់ផ្នែក និងគ្រប់កម្រិតថ្នាក់ទាំងអស់នៅកម្ពុជាត្រូវបានបិទទ្វារនឹងរងការបំផ្លិចបំផ្លាញទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងបុគ្គលិកសិក្សា។ ពួកគេបានយកសាលារៀនធ្វើជាមន្ទីរឃុំឃាំង ធ្វើជាផ្ទះបាយរួម ធ្វើជាក្រោលគោ ឬរុះរើបំផ្លិចបំផ្លាញចោល ហើយចាត់ទុកសាស្ត្រាចារ្យ បញ្ញាវន្ត វេជ្ជបណ្ឌិត លោកគ្រូ អ្នកគ្រូ និងបញ្ញាជនទាំងអស់ថាជាអ្នកជិះជាន់ទៅវិញដោយពួកគេស្វែងរកចាប់ខ្លួនពួកគាត់យកទៅឃុំឃាំងរួចសម្លាប់ចោលស្ទើរអស់។

ទោះបីប្រទេសកម្ពុជាត្រូវខ្ទេចខ្ទាំដោយសង្គ្រាមរ៉ាំរ៉ៃ និងគ្រោះប្រល័យពូជសាសន៍ក្នុងអំឡុងឆ្នាំ១៩៧០-១៩៧៩ យ៉ាងណាក៏ដោយ ក៏ការស្តារ និងកសាងប្រទេសជាតិឡើងវិញត្រូវបានចាប់ផ្តើមឡើងពីកម្រិតសូន្យលើគ្រប់វិស័យ។ ពិសេសវិស័យអប់រំត្រូវបានចាប់ដំណើរការជាបណ្តើរៗ ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ ក្រោមរូបភាពខ្វះមុខខ្វះក្រោយយ៉ាងខ្លាំងទាំងធនធានមនុស្ស សម្ភារៈ ថវិកា។

ជាង៤ទសវត្សមកហើយ ចាប់តាំងពីប្រទេសកម្ពុជាបានរួចផុតពីរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វិស័យអប់រំនៅកម្ពុជាត្រូវបានស្តារ និងអភិវឌ្ឍយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់។ នៅឆ្នាំ១៩៧៩ សាលារៀនត្រូវបានបើកទ្វារស្ទើរគ្រប់ទីកន្លែង ដោយរដ្ឋាភិបាលនៅពេលនោះមានគោលនយោបាយមួយគឺ អ្នកចេះច្រើនបង្រៀនអ្នកចេះតិច និងអ្នកចេះតិចបង្រៀនអ្នកមិនចេះ[1] ពីព្រោះក្នុងសម័យប៉ុល ពត សាលារៀនស្ទើរទាំងអស់ត្រូវបានបិទទ្វារ។ សាស្ត្រាចារ្យ បញ្ញាវន្ត វេជ្ជបណ្ឌិត លោកគ្រូ អ្នកគ្រូ និងអ្នកចេះដឹងមួយចំនួនធំបានបាត់បង់ជីវិតស្ទើរតែអស់។ ប្រឈមនឹងបញ្ហាលំបាកខាងលើ ក្រសួងអប់រំ យុវជន និងកីឡា ខិតខំបណ្តុះបណ្តាលបុគ្គលិកសិក្សាទាំងអ្នកគ្រប់គ្រងរដ្ឋបាល ទាំងគ្រូបង្រៀននៅបឋមសិក្សា ទាំងគ្រូបង្រៀនមធ្យមសិក្សា

[1] Karen Knihgt and Macleod, 2004.p7

និងសាស្ត្រចារ្យឧត្តមសិក្សា និងបានកំណត់ទិសដៅលើកកម្ពស់ គុណភាពអប់រំដោយផ្តើមចេញពីការកែលម្អ កម្មវិធីសិក្សា សៀវភៅសិក្សា វិក្រឹតការគ្រូបង្រៀន វិធីសាស្ត្របង្រៀន និងរយៈពេលសិក្សាក្នុងប្រព័ន្ធអប់រំចំណេះទូទៅជាបន្តបន្ទាប់ដូចខាងក្រោមៈ

- នៅពេលដំបូងពីឆ្នាំ១៩៧៩ ដល់ ១៩៨៦ ប្រព័ន្ធអប់រំចំណេះទូទៅអនុវត្តប្រព័ន្ធសិក្សារយៈពេល១០ឆ្នាំ(៤+៣+៣)គឺកម្រិតសិក្សាទី១ពីថ្នាក់ទី១-៤ កម្រិតសិក្សាទី២ពីថ្នាក់ទី៥-៧ និងកម្រិតសិក្សាទី៣ ពីថ្នាក់ទី៨-១០។នៅពេលនោះ កុមារា កុមារី និងយុវជនបាននាំគ្នាស្រវាសទិញក្នុងការសិក្សារៀនសូត្រយ៉ាងស្រេកឃ្លានបផុត
- ពីឆ្នាំ ១៩៨៦ ដល់ ១៩៩៦ រដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា បានប្តូរប្រព័ន្ធសិក្សាចំណេះទូទៅ ពី១០ទៅ១១ឆ្នាំ(៥+៣+៣) ប៉ុន្តែមធ្យមសិក្សាចំណេះទូទៅមានរយៈពេល៦ឆ្នាំដដែល។
- ពីឆ្នាំ ១៩៩៦ រហូតបច្ចុប្បន្ន អនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ(៦+៣+៣)តែមធ្យមសិក្សាចំណេះទូទៅមានរយៈពេល៦ឆ្នាំដដែល។

ទន្ទឹមនឹងកំណែលម្អកម្មវិធីសិក្សា សៀវភៅសិក្សា និងប្រព័ន្ធអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានកែលម្អ បច្ចេកទេសបង្រៀន និងរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល តាមរយៈវគ្គតម្រង់ទិស ការប្រើប្រាស់សៀវភៅសិក្សាថ្មីគ្រប់កម្រិតថ្នាក់ ដែលឧបត្ថម្ភដោយអង្គការយូនីសេហ្វ អង្គការន័រវេសន៍សង្គ្រោះកុមារកម្ពុជា និងដៃគូអភិវឌ្ឍវិស័យអប់រំដទៃទៀត។

នៅឆ្នាំ២០០០ ផ្អែកលើគោលនយោបាយកំណែទម្រង់វិស័យអប់រំ ដោយផ្តោតលើយុទ្ធសាស្ត្រ"កាត់បន្ថយភាពក្រីក្រ" រាជរដ្ឋាភិបាលបានយកចិត្តទុដាក់ផ្តល់ "កម្មវិធីសកម្មភាពជាអាទិភាព" ជូនដល់ក្រសួងអប់រំ យុវជន និងកីឡា ផ្នែកបឋមសិក្សា ដើម្បីអនុវត្តសាកល្បងចំនួន១០ខេត្តក្រុង។ ចាប់តាំងពីឆ្នាំ២០០១មក រាជរដ្ឋាភិបាលបានអនុញ្ញាតពង្រីកម្មវិធីនៅទូទាំងប្រទេស រួមទាំងមធ្យមសិក្សាបឋមភូមិផងដែរ។ យើងសង្កេតឃើញថា មុនពេលមានកម្មវិធីសកម្មភាពជាអាទិភាពកំណើនសិស្សចូលរៀនថ្មីមានប្រមាណ៧,១០% និងក្រោយពេលមានកម្មវិធីនេះ កំណើនសិស្សចូលរៀនមាន២១,៩៣% ក្នុងអំឡុង៣ឆ្នាំជាប់គ្នា[2]។ ទន្ទឹមនឹងកំណើនសិស្សចូលរៀនថ្មីនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានរកវិធានការជាច្រើនទៀតដើម្បីបង្កើនគុណភាពបង្រៀន

[2] គោលនយោបាយស្តីពីសាលាកុមារមេត្រី ២០០៧

និងរៀន ដូចជាការបំប៉នសិស្សរៀនខ្សោយ នៅបឋមសិក្សាក្នុងពេលវិស្សមកាលធំ ការបំប៉នសិស្សខ្សោយស្របពេលសិក្សា ការបង្រៀនបន្ថែមថ្ងៃព្រហស្បត៍ និងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រឱ្យសិស្សក្រីក្រនៅសាលាបឋមសិក្សា។

ផ្អែកលើនិន្នាការអប់រំសកលលោក ដែលផ្តោតខ្លាំងលើការអភិវឌ្ឍសិទ្ធិកុមារពិសេសការធានាឱ្យកុមារគ្រប់រូបបានចូលរៀនប្រកបដោយសមធម៌នោះ ចាប់ពីឆ្នាំ ២០០២ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានអនុញ្ញាតឱ្យដំណើរការកម្មវិធីកុមារមេត្រីជាបណ្តើរៗ តាមរយៈបទពិសោធដោយឡែកៗពីគ្នានៃអង្គការមួយចំនួនដូចជា៖

- អង្គការយូនីសេហ្វ ទ្រទ្រង់កម្រងក្នុងខេត្តកំពង់ធំ កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង ឧត្តរមានជ័យ
- អង្គការន័រវេសន៍សង្គ្រោះកុមារកម្ពុជា ទ្រទ្រង់កម្រងក្នុងខេត្តសៀមរាប កំពង់ឆ្នាំង ពោធិសាត់ ព្រះវិហារ ឧត្តរមានជ័យ កំពង់ចាម និងរាជធានីភ្នំពេញ
- អង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា ទ្រទ្រង់កម្រងក្នុង ខេត្តកំពង់ចាម[3]។

នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ រដ្ឋមន្ត្រីអប់រំ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ក្នុងកិច្ចប្រជុំនៅទីក្រុងបាំងកក ប្រទេសថៃ បានឯកភាពថា "ជំរុញ និងអភិវឌ្ឍសាលារៀនរបស់យើងនៅទូទាំងប្រទេសឱ្យប្រែក្លាយជាសាលាកុមារមេត្រី"។

ស្របពេលគ្នានេះក្រសួងអប់រំ យុវជន និងកីឡា ក៏បានវាយតម្លៃខ្ពស់លើលទ្ធផលនៃការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៃអង្គការទាំង៣ផងដែរ។ សេចក្តីថ្លែងការណ៍ជាសកលស្តីពីការអប់រំសម្រាប់ទាំងអស់គ្នានៅឆ្នាំ១៩៩០ ដែលបានរៀបចំដោយអង្គការ UNDP, CINFPA, UNICEF, និងWORLD BANK និងចូលរួមដោយប្រទេសចំនួន១៥៥ ក្នុងនោះមានប្រទេសកម្ពុជាផងដែរ។ សេចក្តីថ្លែងការណ៍នោះ បានចែងថា "មនុស្សគ្រប់រូប ទាំងកុមារ យុវជន និងមនុស្សចាស់ ត្រូវទទួលបាននូវឱកាសការអប់រំដើម្បីបំពេញនូវតម្រូវការសិក្សាមូលដ្ឋានរបស់គេ"[4]។

នៅក្នុងសន្និសីទទីក្រុងដាកានៃប្រទេសសេណេហ្គាល់ ពីថ្ងៃទី២៦ ខែមករា ដល់ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០០ រដ្ឋទាំងអស់ដែលជាសមាជិកក្នុងនោះមានប្រទេសកម្ពុជាផងដែរ

[3] ក្រសួងអប់រំ យុវជន និងកីឡា ២០០៧ គោលនយោបាយស្តីពីសាលាកុមារមេត្រី

[4] Report on the Assessment of the Functional Literature Levels of the adultPopulation in Cambodia, 2000

បានសន្យាថាសម្រេចឱ្យបាននូវគោលដៅទាំង៥ ដូចខាងក្រោមៈ

- ពង្រីកវិសាលភាព និងលើកកម្ពស់ដល់ការថែទាំ និងអប់រំកុមារតូចជាពិសេសកុមារដែលងាយរងគ្រោះ។
- ធានាធ្វើយ៉ាងណាឱ្យកុមារទាំងអស់ជាពិសេស កុមារដែលក្រីក្របំផុត កុមារដែលធ្វើការងាររកកម្រៃ គឺកុមារដែលត្រូវទទួលការអប់រំ ជាពិសេសឱ្យបានរៀនចប់ថ្នាក់បឋមសិក្សា ប្រកបដោយគុណភាពនៅត្រឹមឆ្នាំ២០១៥។
- ធានាតម្រូវការរបស់យុវវ័យទាំងអស់ត្រូវបំពេញតាមរយៈសមធម៌នៃការចូលរៀនសមស្រប និងបានរៀននូវកម្មវិធីបំណិនជីវិតនានា
- លុបបំបាត់នូវវិសមភាពយេនឌ័រនៅក្នុងការអប់រំបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០០៥ ជាគោលដៅដើម្បីសម្រេចឱ្យបាននូវសមភាពយេនឌ័រក្នុងកម្មវិធីអប់រំនៅ ឆ្នាំ២០១៥។
- កែលម្អគុណភាពអប់រំតាមគ្រប់រូបភាព ដើម្បីសម្រេចលទ្ធផលនៃការអប់រំដែលមានការទទួលស្គាល់ និងការវាស់វែងបាន ជាពិសេសផ្នែកអក្ខរកម្ម និងបំណិនជីវិត សំខាន់ៗក្នុងការរស់នៅរបស់ពួកគេប្រកបដោយនិរន្តរភាព។

ដោយឡែក ចំពោះគោលការណ៍អប់រំជាមូលដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា ក៏បានយកចិត្តទុកដាក់ធ្វើកំណែលម្អ និងបង្កលក្ខណៈឱ្យសាលាបង្គោលក្នុងកម្រងបើកថ្នាក់សាលាកុមារមេត្រីនៅបឋមសិក្សា និងពង្រីកកម្មវិធីនេះនៅអនុវិទ្យាល័យទៀត។ នៅឆ្នាំ២០០៧ សាលាបង្គោលក្នុងឃុំត្រូវបានពង្រីកជាអនុវិទ្យាល័យ ដែលមានទាំងអស់ប្រមាណ៣០% ក្នុងចំណោមអនុវិទ្យាល័យសរុប៧៤៨ ដែលនៅក្នុងសាលាបង្គោលរបស់កម្រង[5]។

ទោះបីជាវិស័យអប់រំនៅកម្ពុជាមានភាពរីកចម្រើនយ៉ាងនេះក្តី ក៏នៅមានបញ្ហាមួយចំនួនដែលយើងគួរព្រួយបារម្ភ និងត្រូវយកចិត្តទុកដាក់បំផុតដូចជា ការប្រមូលកុមារឱ្យចូលរៀនមិនទាន់បានអស់ អត្រាឡើងថ្នាក់ទាប អត្រាត្រួតថ្នាក់ច្រើន អត្រាបោះបង់ការសិក្សាខ្ពស់ អត្រាសិស្សប្រឡងជាប់ឆ្លងភូមិសិក្សាមានចំនួនតិច មិនទាន់សមស្រប និងសិស្សបានបន្តចូលរៀននៅឧត្តមសិក្សាមានចំនួនតិច បើប្រៀបធៀបជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក។

[5] ក្រសួងអប់រំ យុវជន និង កីឡា ២០០៧ គោលនយោបាយស្តីពីសាលាកុមារមេត្រី

ដូចបណ្តាប្រទេសដទៃក្នុងពិភពលោកដែរ ប្រទេសកម្ពុជាយកចិត្តទុកដាក់បំផុតលើការអប់រំកម្រិតមូលដ្ឋាន។ តាមរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ត្រង់ជំពូកទី៦ មាត្រាទី៦៨ចែងថា៖ រដ្ឋផ្តល់កិច្ចការអប់រំផ្នែកបឋមសិក្សា និងមធ្យមសិក្សាសាធារណៈសម្រាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំ។ ព្រះរាជាណាក្រកម្ពុជា ជាហត្ថលេខីមួយក្នុងសេចក្តីថ្លែងការណ៍ពិភពលោកស្តីអំពី ការអប់រំសម្រាប់ទាំងអស់គ្នា។ ផែនការអប់រំសម្រាប់ទាំងអស់គ្នា ជាគោលមួយសម្រាប់វាស់ស្ទង់វឌ្ឍនភាពរបស់កម្ពុជា ឆ្ពោះទៅរកការអប់រំសម្រាប់ទាំងអស់គ្នា។ ដំណើរការរៀបចំផែនការនេះ ក៏ផ្តល់ឱកាសឱ្យរាជរដ្ឋាភិបាលធ្វើការពិចារណាលើឥទ្ធិពលនៃការប៉ាន់ស្មាន និងសេណារីយ៉ូសម្រាប់គោលនយោបាយកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធ ធនធាន និងភាពជាដៃគូ។ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំយុវជន និងកីឡា ព្រមទាំងសហគមន៍ជាតិ-អន្តរជាតិ ផ្នែកឯកជន អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងារផ្តល់ជំនួយផ្សេងៗទៀត ដែលធ្វើការក្នុងប្រទេសកម្ពុជាទាំងអស់នូវបំណងតែមួយគឺជំរុញសមភាពនៃការចូលរៀន ពិសេសពីថ្នាក់ទី១ ដល់ទី៩ នៅទូទាំងប្រទេស។ ដើម្បីសម្រេចនូវគោលបំណងនេះយើងទាំងអស់គ្នាត្រូវតែចូលរួមគ្រប់សកម្មភាពដែលបម្រើឱ្យវិស័យអប់រំ ពិសេសការចំណាយរបស់ឪពុកម្តាយទៅលើគ្រូបង្រៀន និងការរៃអង្គាសប្រាក់គ្រប់រូបភាពផ្សេងៗទៀត។ យុទ្ធសាស្ត្រសំខាន់ៗក្នុងការធានាការចូលរៀននៅក្នុងការអប់រំមូលដ្ឋានកាន់តែច្រើន នឹងត្រូវបន្តដើម្បីកាត់បន្ថយចំណាយរបស់មាតាបិតាសិស្សដោយចំពោះ និងមិនចំពោះ ដែលជាឧបសគ្គដ៏ធំចំពោះសិស្សដែលមកពីគ្រួសារក្រីក្រ តាមរយៈការបង្កើនប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន។ យុទ្ធសាស្ត្រពាក់ព័ន្ធមួយទៀតគឺ ការបង្កើនថវិកាដំណើរការសាលារៀនដើម្បីទូទាត់នូវតម្រូវការរបស់សាលារៀនពីឪពុកម្តាយសិស្ស។ យុទ្ធសាស្ត្រនេះនឹងជួយឱ្យគ្រូបង្រៀននិងសិស្សានុសិស្សមានវត្តមាននៅសាលារៀនជានិច្ច និងកែលម្អអត្រាឡើងថ្នាក់ និងសម្ភារៈបង្រៀននៅក្នុងការអប់រំមូលដ្ឋានដែលជាផ្នែកមួយនៃវិធានការកែលម្អគុណភាពអប់រំ។ យុទ្ធសាស្ត្រជាអាទិភាពមួយទៀត គឺកម្មវិធីផ្តល់ការលើកទឹកចិត្តដល់កុមារដែលមកពីគ្រួសារក្រីក្រដើម្បីធានាឱ្យកុមារទាំងនោះមានលទ្ធភាពអាចចូលរៀនបឋមសិក្សា មធ្យមសិក្សា និងការបណ្តុះបណ្តាលក្រោយពេលចេញពីសាលារៀនប្រកបដោយសុវត្ថិភាព។

ខាងក្រោមនេះជាគោលដៅសង្ខេបនៃការអប់រំមូលដ្ឋាន ក្នុងក្របខ័ណ្ឌអប់រំសម្រាប់ទាំងអស់គ្នា៖

1. ធានាថានៅឆ្នាំ២០១៥ កុមារទាំងអស់ ពិសេសកុមារី កុមារដែលស្ថិតក្នុងកាលៈទេសៈលំបាក និងកុមារដែលមកពីក្រុមជនជាតិភាគតិចបានទទួល និងបំពេញចប់នូវកាតព្វកិច្ចអប់រំបឋមសិក្សា ដោយឥតគិតថ្លៃ និងប្រកបដោយគុណភាព។
2. លុបបំបាត់គម្លាតយេនឌ័រក្នុងបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០០៥ និងធ្វើឱ្យបានសម្រេចនូវសមភាពយេនឌ័រក្នុងវិស័យអប់រំនៅឆ្នាំ២០១៥ ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឱ្យកុមារី បានទទួលលទ្ធភាពចូលរៀនដោយពេញលេញ និងស្មើភាព ព្រមទាំងសម្រេចបាននូវការរអប់រំមូលដ្ឋានប្រកបដោយគុណភាព។
3. កែលម្អលើគ្រប់ទិដ្ឋភាពនៃគុណភាពអប់រំ និងធានាបាននូវគុណភាពប្រសើរបំផុតគ្រប់ផ្នែកដើម្បីឱ្យមនុស្សគ្រប់រូបដណ្តើមបាននូវលទ្ធផលរៀនសូត្រមានកម្រិតវាស់បាននិងមានការទទួលស្គាល់ជាពិសេសផ្នែកអក្សរសាស្ត្រ លេខនព្វន្ត និងជំនាញចាំបាច់សម្រាប់ចិញ្ចឹមជីវិត(បំណិនជីវិត)។

   វត្ថុបំណងទូទៅពាក់ព័ន្ធនឹងគោលដៅទាំងនេះសម្រាប់កម្ពុជាមាន៖

   - ការចូលសិក្សារបស់កុមារអាយុ ៦ឆ្នាំ ជាសកល
   - ការចូលសិក្សា និងបញ្ចប់ការសិក្សានៅបឋមសិក្សា ឬកម្រិតសមមូលនៅឆ្នាំ២០១០
   - ការចូលសិក្សានិងបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ឬកម្រិតសមមូលនៅឆ្នាំ២០១០
   - ពង្រឹងប្រសិទ្ធភាពអប់រំទៅសាលាក្នុងប្រព័ន្ធ
   - ផ្តល់ថវិការបស់រាជរដ្ឋាភិបាលប្រកបដោយនិរន្តភាពដល់ការអប់រំមូលដ្ឋាន
   - ការសម្រេចបាននូវលទ្ធផលសិក្សាជាសកល ជាពិសេសអក្ខរកម្ម ការចេះគិតលេខនព្វន្ត និងបំណិនជីវិតចាំបាច់[6]។

យើងបានដឹងហើយថា ប្រទេសមួយ ជាតិសាសន៍មួយ មានការរីកចម្រើនទៅបានលុះត្រាតែមានអ្នកចេះដឹងជ្រៅជ្រះច្រើន។ យ៉ាងណាមិញ ប្រទេសកម្ពុជាមានគោល

[6] ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា២០០៣-២០១៥

នយោបាយឱ្យប្រជាពលរដ្ឋទាំងអស់រៀនចប់ថ្នាក់កម្រិតមូលដ្ឋានជាចាំបាច់ ដើម្បីបន្តទៅរៀននៅមធ្យមសិក្សាទុតិយភូមិបន្ទាប់មកប្រឡងយកសញ្ញាបត្រទុតិយភូមិ រួចបន្តទៅឧត្តមសិក្សាឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ហេតុនេះហើយរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងអង្គការក្រៅរដ្ឋាភិបាល សហគមន៍ជាតិ សហគមន៍អន្តរជាតិ និងប្រទេសជាមិត្តជាច្រើនបានចូលរួមអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាយ៉ាងយកចិត្តទុកដាក់បំផុត ពិសេសការកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្សនៅបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ។ យើងត្រូវយកចិត្តទុកដាក់លើបញ្ហាខាងលើព្រោះ ប្រសិនបើសិស្សបោះបង់ការសិក្សាច្រើននៅបឋមសិក្សាមួយភាគធំបង្កភាពស្មុគស្មាញដល់សង្គមគ្រួសារ និងសង្គមជាតិ ដូចជាអ្នកខ្លះក្លាយជាបងធំបងតូច ខ្លះសេពគ្រឿងញៀន ខ្លះរកការងារធ្វើមិនបាន និងខ្វះការគិតពិចារណាឱ្យបានជ្រៅជ្រះ ងាយរងការអូសទាញរបស់ជនខិលខូចដទៃទៀត។ ហេតុនេះហើយបានជាអ្នកស្រាវជ្រាវត្រូវសាកល្បងធ្វើការសិក្សាអំពីមូលហេតុចម្បងៗនៃការបោះបង់ការសិក្សា និងលើកឡើងនូវសំណូមពរមួយចំនួនផ្តល់ឱ្យភាគីពាក់ព័ន្ធទាំងអស់ដើម្បីពិចារណាក្នុងការរកវិធីដោះស្រាយដើម្បីកាត់បន្ថយ ការបោះបង់ការសិក្សានាពេលអនាគត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

កំពង់ធំ ជាខេត្តមួយស្ថិតនៅកណ្តាលនៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ចាម និងខេត្តក្រចេះ។ ខាងត្បូងជាប់នឹងខេត្តកំពង់ចាម និងខេត្តកំពង់ឆ្នាំង ខាងលិចជាប់បឹងទន្លេសាប និងខេត្តកំពង់ឆ្នាំង។ ចំណែកខាងជើងជាប់ខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តស្ទឹងត្រែង។ ខេត្តកំពង់ធំ មានស្រុកចំនួន៨ ឃុំចំនួន៨១ និងមាន ចម្ងាយ១៦៨គីឡូម៉ែតពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ៦ ។

ជាក់ស្តែងក្នុងឆ្នាំសិក្សា ២០១៧-២០១៨នេះ ខេត្តមានសាលាមត្តេយ្យសិក្សាចំនួន៣៨៨នាក់ មានថ្នាក់រៀនសរុបចំនួន៥៣២ សិស្សសរុបចំនួន១៧,១៣៦នាក់ ស្រី៨,៦២០នាក់ និងបុគ្គលិកសិក្សាសរុប ៥២៩នាក់ ស្រី៥០៣នាក់។ សាលារៀនបឋមសិក្សាទូទាំងខេត្ត មានចំនួន៤៨៧ កើនចំនួន០៥សាលា និងមានសិស្សសរុបចំនួន១០០,៦៤៧ នាក់ស្រី៤៨,៩៣៩នាក់។ បុគ្គលិកសរុបដែលបម្រើការនៅបឋមសិក្សាមានចំនួន៣,៨៦១នាក់ស្រី២,០០១នាក់។ សាលារៀនមិនគ្រប់កម្រិត៤៣សាលាហើយចំនួនកម្រងសរុប ៧៥កម្រង។ សាលាឯកជនចំនួន០៤ ថ្នាក់ចំនួន៨៥។ សិស្សក្រីក្រសរុប១៩,៨៦៥ នាក់ ស្រី

១០,១៥៧នាក់។ សិស្សពិការសរុប ១,១៦៣ នាក់ ស្រី៤៨២ នាក់។

ក្នុងឆ្នាំសិក្សា២០១៧-២០១៨ សាលាបឋមសិក្សាមានៈ

- អត្រារួមចូលរៀនថ្មីមាន ១១២,៥០% ស្រី ១១១,៧០%
- អត្រាពិតចូលរៀនថ្មីមាន ៩២,៤០% ស្រី៩៣,៥០%
- អត្រារួមនៃការសិក្សាមាន ១០៦,៥០% ស្រី១០៦,៧០%
- អត្រាពិត នៃការសិក្សាមាន៩២,១០% ស្រី៩៣,១០%
- អត្រាឡើងថ្នាក់មាន ៨៧,៥០% ស្រី៩០,៣០%
- អត្រាត្រួតថ្នាក់មាន ៧,៣០% ស្រី៥,៦០%
- អាត្រាបោះបង់ការសិក្សាមាន ៥,៣០% ស្រី៤,១០%
- អត្រាឆ្លងភូមិសិក្សាមាន ៨៩,២១% ស្រី៨៩,៩០%[7]។

ទោះបីមានការរីកចម្រើនយ៉ាងនេះក៏ដោយ ក៏នៅមានអត្រាសិស្សបោះបង់ការសិក្សា និងអត្រាសិស្សរៀនត្រួតថ្នាក់នៅមានកម្រិតខ្ពស់ដដែលបើប្រៀបធៀបទៅនឹងស្ថិតិសាលាបឋមសិក្សានៅទូទាំងប្រទេស។

**តារាងទី១** កំណើនសិស្សចូលទៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ធំ

| គ្រឹះស្ថាន | ចំនួនសិស្សឆ្នាំសិក្សា ២០១៦-២០១៧ | | ចំនួនសិស្សឆ្នាំសិក្សា ២០១៧-២០១៨ | | កំណើនសរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ម.បឋមភូមិ | ២៩ ៣៤១ | ១៥៩០៨ | ៣០៥៤០ | ១៦ ៦៩១ | ១១៩៩ | ៧៨៣ |

ទោះបីមានការរីកចម្រើនយ៉ាងនេះក៏ដោយ ក៏នៅមានសិស្សបោះបង់ការសិក្សា និងអត្រារៀនត្រួតថ្នាក់នៅមានកម្រិតខ្ពស់ដដែលបើប្រៀបធៀបទៅនឹងប៉ុន្មានឆ្នាំមុន នៅបឋមសិក្សាក្នុងខេត្ត ។

[7] របាយការណ៍បូកសរុបការងារអប់រំ យុវជន និង កីឡាខេត្តកំពង់ធំ ឆ្នាំសិក្សា ២០១៧-២០១៨ ផ្នែកមត្តេយ្យសិក្សា និងបឋមសិក្សាចំណេះទូទៅ

## ១.៣ សំណួរស្រាវជ្រាវ

តាមរយៈបញ្ហាប្រឈមខាងលើ ការសិក្សាស្រាវជ្រាវនេះនឹងត្រូវធ្វើឡើងដើម្បីឆ្លើយតបសំណួរ "តើកត្តាអ្វីខ្លះដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សានៅបឋមសិក្សា?"

## ១.៤ គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺ មានទិសដៅស្វែងរកឱ្យឃើញនូវមូលហេតុដែលនាំឱ្យសិស្សបោះបង់ការសិក្សានៅមុនពេលបញ្ចប់ថ្នាក់បឋមសិក្សា និងស្វែងរកមូលហេតុចម្បងៗទាំងឡាយដែលពាក់ព័ន្ធនឹងការបោះបង់ការសិក្សា និងភាគីពាក់ព័ន្ធទាំងអស់ព្រមទាំងបរិយាកាសសង្គមផងដែរ។ ការសិក្សានេះស្វែងយល់ផងដែរអំពីវិធានការ និងកំណែលម្អមួយចំនួនដែលក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងសាលារៀនធ្លាប់បានអនុវត្តកន្លងមក។ អ្នកស្រាវជ្រាវនឹងវិភាគកត្តាមួយចំនួនដែលគ្មាននៅក្នុងកម្រងសំណួរស្រាវជ្រាវតែវាមានឥទ្ធិពលទៅលើការបោះបង់ការសិក្សានេះផងដែរ គឺតាម រយៈការសម្ភាសក្រៅផ្លូវការ។

សរុបមកការសិក្សាស្រាវជ្រាវនេះផ្តោតទៅលើចំណុចសំខាន់ដូចខាងក្រោមៈ

កំណត់បង្ហាញពីមូលហេតុមួយចំនួន ដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សានៅបឋមសិក្សាមុនពេលចូលរៀននៅមធ្យមសិក្សាបឋមភូមិ ក្នុងខេត្តកំពង់ធំ នៅជនបទ និងតំបន់ដាច់ស្រយាល និងធ្វើការវិភាគទៅលើផលប៉ះពាល់មួយចំនួន ដែលបណ្តាលមកពីការបោះបង់ការសិក្សា។

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងស្វែងរកអនុសាសន៍មួយចំនួនដើម្បីផ្តល់ឱ្យភាគីពាក់ព័ន្ធក្នុងការជួយទប់ស្កាត់ ឬកាត់បន្ថយការបោះបង់ការសិក្សារបស់សិស្សនៅបឋមសិក្សាដើម្បីឱ្យសិស្សទាំងនោះមានលទ្ធភាពបន្តការសិក្សាថ្នាក់មធ្យមសិក្សា ឬជំនាញវិជ្ជាជីវៈផ្សេងៗទៀតនៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេសផងដែរ។ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសាលាបឋមសិក្សា២ក្នុងស្រុកកំពង់ស្វាយ និងស្រុកបារាយណ៍ ដើម្បីរកឱ្យឃើញនូវមូលហេតុចម្បងៗដែលបណ្តាលឱ្យសិស្សបោះបង់ចោលការសិក្សានៅបឋមសិក្សា។ ម្យ៉ាងទៀត ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ក្នុងការកែលម្អ

ចំណុចខ្វះខាតរបស់សាលារៀន គ្រូបង្រៀន សហគមន៍ មាតាបិតាសិស្ស ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់ ដូចជាសាលារៀនត្រូវយកចិត្តទុកដាក់ក្នុងការបង្រៀន និងគ្រប់គ្រងវត្តមាន អវត្តមានសិស្ស វិន័យសិស្សឱ្យបានម៉ត់ចត់ ដោយមានទំនាក់ទំនងល្អជាមួយមាតាបិតាសិស្ស សហគមន៍ ឬអាជ្ញាធរមូលដ្ឋានក្នុងការតាមដានការសិក្សារបស់សិស្ស។ ចំណែកមាតាបិតាសិស្ស ឬអាណាព្យាបាលសិស្ស ត្រូវចូលរួមយ៉ាងសកម្មក្នុងការតាមដានការសិក្សារបស់សិស្សដោយមានទំនាក់ទំនងល្អជាមួយលោកគ្រូ អ្នកគ្រូ លោកនាយកសាលា តាមរយៈសៀវភៅតាមដានការសិក្សា តារយៈព្រឹត្តិបត្រពិន្ទុរបស់សិស្ស តាមរយៈមិត្តភក្តិរបស់ពួកគេ និងតាមរយៈការជួបសន្ទនាគ្នាផ្ទាល់។

ដោយឡែកក្រសួងអប់រំ យុវជន និងកីឡា ត្រូវផ្តល់សម្ភារៈសិក្សា សៀវភៅសិក្សាគោល និងថវិកាឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់សាលារៀន។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំកម្មវិធីសិក្សាឱ្យបានសមស្របនឹងតម្រូវការទីផ្សារ និងតម្រូវការតាមតំបន់ភូមិសាស្ត្ររបស់ពួកគេ ដើម្បីឱ្យពួកគេមានឱកាសក្នុងការរកស៊ី ឬធ្វើការងារអ្វីៗដើម្បីជីវភាពគ្រួសាររបស់ពួកគេបានធូរធារ។ នៅក្នុងកម្រិតទ្រឹស្តី របាយការណ៍ស្រាវជ្រាវនេះ នឹងជាវិភាគទានមួយដើម្បីបង្ហាញថាការយល់ដឹងអំពីមូលហេតុនានាដែលបណ្តាលឱ្យសិស្សមួយចំនួនបានបោះបង់ចោលការសិក្សា។

ការវិភាគត្រូវបានធ្វើទៅលើកត្តាធំ១៥គឺៈ កត្តាជីវភាពគ្រួសារ(ភាពក្រីក្រ) កត្តាភេទនិងអាយុ កត្តាសិស្សផ្ទាល់ កត្តាសាលារៀននិងគ្រូបង្រៀន និងកត្តាសង្គម។ ការសិក្សានេះក៏នឹងក្លាយទៅជាវិភាគទានមួយក្នុងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ពិសេសផ្នែកបឋមសិក្សា។

## ១.៦ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ជាទូទៅ សិស្សរៀននៅបឋមសិក្សាក្នុងខេត្តកំពង់ធំ មានអាយុចន្លោះពី ៦ ទៅ១៦ឆ្នាំ។ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះ គឺសិក្សាលើកុមារា កុមារីដែលបោះបង់ការសិក្សា ក្នុងអាយុចន្លោះពី ៦ឆ្នាំទៅ១៦ឆ្នាំ។

សិស្សបោះបង់ការសិក្សានៅបឋមសិក្សា ក្នុងឆ្នាំ២០១៧-២០១៨ គឺជាសិស្សមានឈ្មោះក្នុងបញ្ជីត្រូវរៀន (ថ្នាក់ទី៥ឬទី៦) តែមិនបានមករៀននៅដើមឆ្នាំសិក្សាឬឈប់រៀននៅដំណាច់ឆមាសទី១ ឬមិនបានប្រឡងឆមាសទី២ ឬគ្មានពិន្ទុប្រចាំឆ្នាំ។ សិស្សបោះ

បង់មិនមែនជាសិស្សផ្ទេរការសិក្សា ឬសិស្សផ្លាស់ទីលំនៅតាមឪពុកម្តាយ ឬអាណាព្យាបាលឡើយ។ យើងនឹងសិក្សាលើកម្រងសាលាបឋមសិក្សាគោលដៅ២គឺ កម្រងសាលាបឋមសិក្សាត្នោតជុំ ស្រុកបារាយណ៍ និងកម្រងសាលាបឋមសិក្សាសានគរ ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ការសិក្សានេះសិក្សាតែអំពីមូលហេតុដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សានៅបឋមសិក្សាមុនចូលមធ្យមសិក្សាបឋមភូមិតែប៉ុណ្ណោះ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូក រួមមាន៖

ជំពូកទី១៖ សេចក្តីផ្តើម

ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវ នឹងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងវិសាលភាពនៃការស្រាវជ្រាវ។

ជំពូកទី២៖ រំលឹកទ្រឹស្តី

រាល់ទ្រឹស្តីរបស់អ្នកសិក្សាស្រាវជ្រាវមុនៗ ដែលពាក់ព័ន្ធនឹងប្រធានបទនេះ ត្រូវបានលើកឡើងដើម្បីធ្វើជាគំនិត និងឆ្លុះបញ្ចាំងទៅនឹងការរកឃើញថ្មី នៅក្នុងស្នាដៃស្រាវជ្រាវនេះផងដែរ។

ជំពូកទី៣៖វិធីសាស្ត្រស្រាវជ្រាវ

នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញនូវឧបករណ៍ស្រាវជ្រាវវិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសគំរូសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យដែលប្រមូលបាន។

ជំពូកទី៤៖លទ្ធផលនៃការស្រាវជ្រាវ

លទ្ធផលនៃការស្រាវជ្រាវ នឹងត្រូវបានយកមកបកស្រាយ និងពិភាក្សាយ៉ាងក្បោះក្បាយ ដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើឱ្យប្រសើរឡើងវិញនៅក្នុងស្ថាន ភាពជាក់ស្តែង របស់សាលារៀននីមួយៗ។

ជំពូកទី៥៖សេចក្តីសន្និដ្ឋាន និងសំណូមពរ

នេះជាផ្នែកដែលអ្នកស្រាវជ្រាវ ធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគព្រមទាំងលើកឡើងនូវសំណូមពរមួយចំនួនក្នុងបំណង កាត់បន្ថយការបោះបង់ការសិក្សានៅបឋមសិក្សា។

# ជំពូកទី២៖
# រំលឹកទ្រឹស្តី

# ជំពូកទី២៖
# រំលឹកទ្រឹស្តី

## ២.១ ការអប់រំខ្វះនៅនៅកម្ពុជា

អត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សា បានកើនឡើងយ៉ាងឆាប់រហ័សនៅប៉ុន្មានឆ្នាំកន្លងទៅនេះ ដែលមានប្រហែលជាង៩០% នៅឆ្នាំសិក្សា២០១៧-២០១៨។ សាលាបឋមសិក្សាមានពីថ្នាក់ទី១ដល់ទី៦ដូចប្រទេសដទៃទៀតដែរ។ សិស្សអាចចុះឈ្មោះចូលរៀនបាននៅបឋមសិក្សាចំណោះទូទៅកាលណាគេមានអាយុគ្រប់៦ឆ្នាំ នៅពេលពួកគេរៀនចប់ថ្នាក់ទី៦គេនឹងចុះឈ្មោះចូលរៀនបន្តនៅមធ្យមសិក្សាបឋមភូមិ(ពីថ្នាក់ទី៧ដល់ថ្នាក់ទី៩) ជាស្វ័យប្រវត្តិដោយគ្មានឆ្លងកាត់ការប្រឡងឡើយ និងបន្តចូលរៀននៅមធ្យមសិក្សាទុតិយភូមិ (ពីថ្នាក់ទី៩ដល់ថ្នាក់ទី១២) ដោយឆ្លងកាត់ការប្រឡងថ្នាក់ទី៩ (ប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ) បើប្រឡងធ្លាក់មិនអាចចូលរៀនថ្នាក់ទី១០ បានឡើយ។

ប៉ុន្តែសិស្សប្រមាណ៤៣% ដែលបានចុះឈ្មោះចូលរៀននៅបឋមសិក្សាបានបោះបង់ការសិក្សារបស់គេទាំងមិនបានបញ្ចប់ការសិក្សានៅថ្នាក់បឋមសិក្សានៅឡើយ។ លើសពីនេះទៅទៀត ចំនួនសិស្សពាក់កណ្តាលដែលបញ្ចប់ការសិក្សានៅបឋមសិក្សាមិនបានបន្តការសិក្សារបស់ពួកគេនៅមធ្យមសិក្សាបឋមភូមិទេ[8]។ ទោះបីជាសាលាត្រូវបានបើកទ្វារដោយឥតបង់ថ្លៃសម្រាប់សិស្សទាំងនោះក៏ដោយ។ ម្យ៉ាងទៀត ទោះបីការអប់រំត្រូវបានកំណត់ជាសមាសភាគដ៏សំខាន់នៃយុទ្ធសាស្ត្រអភិវឌ្ឍជាតិរបស់ប្រទេសកម្ពុជាក៏ដោយ[9] ក៏អត្រាចូលរៀននៅថ្នាក់មធ្យមសិក្សាបឋមភូមិនៅតែមានកម្រិតទាប។

## ២.២ ការអប់រំនៅកម្ពុជា និងបញ្ហាប្រឈម

ប្រព័ន្ធអប់រំនៅកម្ពុជា ត្រូវបានបិទទ្វារទាំងស្រុង និងត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរក្នុងរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម។ ៣ភាគ៤ នៃបញ្ញវន្តត្រូវបានគេសម្លាប់ ក្នុងនោះរួមមានសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត វេជ្ជបណ្ឌិត អ្នកឯកទេស និងបញ្ញាជនផ្សេងៗទៀតជាច្រើន[10]។

[8] EMIS ២០០៥-២០០៦

[9] ESP, ២០១៦

[10] Country Paper of the State of Cambodia, Ministry of Education, 1990

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សាលារៀនត្រូវបានបើកទ្វារឱ្យសិស្ស និស្សិតចូលរៀនឡើងវិញ។ ប៉ុន្តែ ទោះបីសាលារៀនត្រូវបានបើកទ្វារក៏ដោយ ក៏ស្ថានភាពនៅពេលនោះជួបការលំបាកខ្លាំងទាំងធនធានមនុស្ស សម្ភារៈ និងថវិកា។ សង្គ្រាមរ៉ាំរ៉ៃនៅក្នុងប្រទេសបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ សាលារៀន ផ្លូវថ្នល់ មន្ទីរពេទ្យ និងសម្លាប់ជីវិតមនុស្សអស់ជាច្រើនក្នុងអំឡុងឆ្នាំ១៩៧៩ដល់ឆ្នាំ១៩៩៨។ ក្នុងអំឡុងពេលនោះដែរ ប្រជាជនមានជីវភាពខ្វះខាតយ៉ាងខ្លាំង ពិសេសប្រជាជនរស់នៅតាមជនបទចុងកាត់មាត់ញក ព្រមទាំងជីវភាពគ្រូបង្រៀនផងដែរ។ ក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ ប្រាក់បៀវត្សមន្ត្រីរាជការមានប្រមាណពី៦ដុល្លាទៅ២៣ដុល្លារ ក្នុងមួយខែ នៅឆ្នាំ១៩៩៨ និងប្រមាណពី ២០ទៅ ២៧ដុល្លារក្នុងមួយខែនៅឆ្នាំ២០០០[11]។

បញ្ហាប្រឈមធំមួយទៀតគឺ ប្រព័ន្ធនយោបាយលើវិស័យអប់រំ ដោយប្រើប្រាស់នយោបាយមជ្ឈការច្រើន ទោះបីក្នុងទ្រឹស្តីគេនិយាយថាប្រើក្នុងវិមជ្ឈការ សហវិមជ្ឈការក៏ដោយ ដូចជាការធ្វើកម្មវិធីសិក្សា ការប្រើប្រាស់ថវិកា ការធ្វើគោលនយោបាយអប់រំ ឬការបង្កើតបញ្ញត្តិផ្សេងៗទៀតសុទ្ធតែថ្នាក់កណ្តាលជាអ្នកសម្រេចទាំងអស់។ល។

ចាប់តាំងពីសន្និសីទនៅចុមធៀម (Jomtien) ប្រទេសថៃមក ប្រព័ន្ធអប់រំនៅបឋមសិក្សាត្រូវបានពង្រីកសមត្ថភាពរបស់ខ្លួនគ្រប់តំបន់ទាំងអស់នៅក្នុងពិភពលោក។ ការអប់រំនៅបឋមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍខ្លះបានពង្រីកសមត្ថភាពរបស់ខ្លួនស្ទើរទៅដល់ផ្ទះក្មេងទាំងអស់ ដែលមានអាយុត្រូវចូលរៀន ហើយប្រទេសទាំងនេះបានខិតខំប្រឹងប្រែងឱ្យការចុះឈ្មោះចូលរៀនប្រកបដោយសមភាព និងសមធម៌។ នៅឆ្នាំ២០០១ ក្មេង៣២៥លាននាក់បានបោះបង់ការសិក្សានៅបឋមសិក្សា និងមធ្យមសិក្សាភាគច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍ[12]។ ការបោះបង់ការសិក្សានៅបឋមសិក្សាគ្មាននៅក្នុងប្រទេសឧស្សាហកម្មទេពីព្រោះគេមានច្បាប់កាតព្វកិច្ចសិក្សា។ចំណែកនៅប្រទេសកំពុងអភិវឌ្ឍការបោះបង់ការសិក្សាជាបញ្ហាចម្បងមួយ។ សិស្សប្រមាណ ៩៦លាននាក់ ដែលបានចូលសាលារៀន(នៅឆ្នាំ១៩៩៥) ២៤លាននាក់បានបោះបង់ការសិក្សារបស់ពួកគេនៅមុនថ្នាក់ទី៥[13]។ ក្នុងបរិបទនេះ ការអប់រំទូទាំងពិភពលោកនៅតែប្រឈមក្នុងវិបត្តិដ៏ជ្រាលជ្រៅដែលទាក់ទងនឹងសេដ្ឋកិច្ចសង្គម វប្បធម៌ អស្ថេរភាពនយោបាយ និងការផ្លាស់ប្តូរយ៉ាងលឿនអំពីបុគ្គលិកលក្ខណៈរបស់មនុស្ស។

---

[11] RGC, Second- Five Year Socio-Economic Development Plan 2001-2005. (Draft-March 2001)

[12] UNDP 2001 *Human Development Report, Chapter one*

[13] UNESCO,EFA,1998

ការផ្លាស់ប្តូរសេដ្ឋកិច្ចមានផលប៉ះពាល់យ៉ាងខ្លាំងលើវិស័យអប់រំ ដែលជាកម្លាំង ជំរុញដ៏ធំមួយក្នុងកំណែទម្រង់វិស័យអប់រំ។ គេបានរកឃើញថា ការចុះឈ្មោះចូលរៀនមានការធ្លាក់ចុះនៅក្នុងប្រទេសដែលមានវិបត្តិសេដ្ឋកិច្ច និងនយោបាយ។ ក្នុងរយៈពេលមានវិបត្តិ កុមារដែលមកពីគ្រួសារក្រីក្រត្រូវបានទទួលផលប៉ះពាល់ធ្ងន់ធ្ងរជាងក្មេងដែលមកពីគ្រួសារធូរធារ។ ដោយសារវិបត្តិនេះប្រព័ន្ធអប់រំនៅឥណ្ឌូស៊ី និងនៅថៃ ប្រឈមមុខនឹងបញ្ហាបោះបង់ការសិក្សាច្រើននាប៉ុន្មានឆ្នាំមុននៅគ្រប់កម្រិតថ្នាក់ទាំងអស់។

## ២.៣ ការបោះបង់ការសិក្សា

### ២.៣.១ កត្តាចម្ងាយផ្លូវ និងសាលារៀនមិនគ្រប់កម្រិតថ្នាក់

នៅបឋមសិក្សា ក៏ដូចជាមធ្យមសិក្សាដែរ សិស្សមួយចំនួនមានលំនៅដ្ឋានឆ្ងាយពីសាលារៀនទោះបីជាគោលនយោបាយអប់រំកំណត់ថា សង់សាលារៀនឱ្យដល់លំនៅដ្ឋានរបស់សិស្សយ៉ាងណាក៏ដោយពិសេសកូនចៅប្រជាពលរដ្ឋនៅតាមជនបទ។ មូលហេតុមួយដែលធ្វើឱ្យសិស្សបោះបង់ការសិក្សាទាំងបឋមសិក្សា ទាំងមធ្យមសិក្សា គឺបណ្តាលមកសាលារៀននៅឆ្ងាយពីផ្ទះសិស្ស[14] ដែលជាហេតុធ្វើឱ្យសិស្សពិបាកធ្វើដំណើរទៅមក ហើយសិស្សអវត្តមានច្រើន យូរៗទៅសិស្សក៏សម្រេចចិត្តឈប់រៀន។ ម្យ៉ាងទៀតបើចម្ងាយផ្លូវរវាងសាលារៀននិងលំនៅដ្ឋានគ្រូក៏ឆ្ងាយធ្វើឱ្យការបង្រៀនរបស់គ្រូមិនជិតដល់ ក៏នាំឱ្យសិស្សបោះបង់ការសិក្សាផងដែរ។ មូលហេតុមួយទៀត គឺសាលារៀនមិនគ្រប់កម្រិតថ្នាក់[15]។ សាលាបឋមសិក្សាមួយចំនួននៅទូទាំងប្រទេសកម្ពុជា ជាសាលាមិនគ្រប់កម្រិតថ្នាក់ (មានន័យថាសាលារៀនទាំងនោះមានថ្នាក់រៀនមិនដល់ថ្នាក់ទី៦) ដែលជាកម្រិតថ្នាក់ចុងក្រោយនៃសាលាបឋមសិក្សា។ អនុវិទ្យាល័យបានបង្កើតគ្រប់ឃុំនៅទូទាំងប្រទេស ដែលមានចម្ងាយឆ្ងាយពីលំនៅដ្ឋានកុមាររស់នៅ មានតែនៅតាមទីប្រជុំជន ទីរួមស្រុក និងទីរួមខេត្តប៉ុណ្ណោះដែលជាហេតុធ្វើឱ្យសិស្សនិងឪពុកម្តាយសិស្សសម្រេចចិត្តបោះបង់ការសិក្សានៅពេលពួកគេបញ្ចប់ថ្នាក់ទី៦។

### ២.៣.២ ភាពក្រីក្រ

យើងដឹងហើយថា កត្តាធំបំផុតក្នុងការអប់រំសិស្ស គឺកត្តាសេដ្ឋកិច្ច ពិសេសសេដ្ឋកិច្ចគ្រួសារ។ ភាពក្រីក្របានធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្សដូចជាការចុះឈ្មោះចូលរៀន

[14] សន្និបាទអប់រំ សុន្ទរកថា លោក អ៊ុំ អេង ខែកក្កដា ២០១៤

[15] EMIS2014

ការបោះបង់ការសិក្សា។ មូលហេតុចម្បងនៃការបោះបង់ការសិក្សានៅបឋមសិក្សាក្នុងប្រទេសហ្វីលីពីនក្នុងអំឡុងទសវត្សឆ្នាំ១៩៥០ គឺបណ្តាលមកពីកត្តាសេដ្ឋកិច្ចសង្គម[16]។ ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញថា កុមារមួយចំនួនធំនៃគ្រួសារក្រីក្រ ក្នុងប្រទេសកំពុងអភិវឌ្ឍត្រូវការធ្វើការរកស៊ីដើម្បីចិញ្ចឹមជីវិត និងផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេ ដូចជាធ្វើស្រែចម្ការ កម្មករលីសែង កម្មករសំណង់ បម្រើសេវាផ្លូវភេទ...។ ទាំងនេះជាឧបសគ្គរបស់ពួកគេក្នុងការចូលរៀន។ កត្តាស្វែងរកការងារធ្វើរបស់សិស្សនៅទីក្រុង និងទីប្រជុំជនក្នុងខេត្តក៏ជាឧបសគ្គក្នុងការសិក្សាផងដែរ។ ម្យ៉ាងទៀត ពេលដែលសិស្សឈប់កាន់តែច្រើន និងលើសពីកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងសាលាធ្វើឱ្យពួកគេខ្លាចសាលារៀនហើយរៀនមិនយល់ដល់គេដែលជាកត្តាមួយជំរុញឱ្យពួកគេបោះបង់ការសិក្សា[17]។ កុមារដែលមានអាយុចាប់ពី១៥ឆ្នាំទៅ១៧ឆ្នាំ ចំនួន៣៩៨ ២៧២នាក់ បានបោះបង់ការសិក្សារួចបានលក់កម្លាំងពលកម្មរបស់ខ្លួនដើម្បីរកកម្រៃចិញ្ចឹមជីវិត និងជួយដល់ក្រុមគ្រួសាររបស់ពួកគេ[18]។ ជារួមសិស្សដែលមិនបានទៅរៀនទៀងទាត់បែរជាមកជួយការងារក្រុមគ្រួសារ បណ្តាលឱ្យមានការកើនឡើងនៃអត្រាប្រឡងឡើងថ្នាក់ និងអត្រាត្រួតថ្នាក់រួចឈានទៅរកការបោះបង់ការសិក្សា។ មានសិស្សមួយចំនួនដោយសារសមាជិកក្រុមគ្រួសាររបស់គេច្រើនពេកក៏សម្រេចចិត្តឈប់រៀន រួចទៅធ្វើការងារដើម្បីជួយរំលែកបន្ទុកមាតាបិតា ព្រោះពុំមានលទ្ធភាពសិក្សាបានទាំងអស់គ្នាទេ។ ការងារផ្ទះ ដូចជារៀបចំអាហារ សម្អាតផ្ទះសម្បែង បោកគក់សម្លៀកបំពាក់ លក់ដូរ ឃ្វាលគោក្របី ក៏ជាកត្តាមួយដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សាផងដែរ ពិសេសសិស្សស្រីមានអត្រាបោះបង់ខ្ពស់ជាងសិស្សប្រុស គឺកុមារាបោះបង់៨% ចំណែកកុមារីបោះបង់២០,៧%[19]។

ចំណែកពាហ៍ពិពាហ៍ ក៏ជាកត្តាមួយដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សាផងដែរ ពិសេសសិស្សស្រី ព្រោះបើក្មេងស្រីឆាប់រៀបការ ឬរៀបការនៅវ័យជំទង់ ការរៀនសូត្ររបស់ពួកគេនឹងត្រូវបញ្ចប់[20]។

[16] M. Brimer and L.Pauli,1971

[17] ការសិក្សាស្រាវជ្រាវការប្រតិបត្តិអប់រំឆ្នាំ២០០៤

[18] ដកស្រង់ពី"តើអ្នកដឹងទេ? ហើយតើអ្នកអាចធ្វើបាន" របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ឆ្នាំ២០០២ ស្តីអំពីពលកម្មកុមារលទ្ធផលអង្កេត សេដ្ឋកិច្ចសង្គម ឆ្នាំ១៩៩៩

[19] ការសិក្សាស្រាវជ្រាវ ប្រតិបត្តិអប់រំ ឆ្នាំ២០០៤

[20] ADB, 2000,P,118

### ២.៣.៣ ការសិក្សាមានតម្លៃខ្ពស់

សិស្សមានការចំណាយច្រើនសម្រាប់ការសិក្សារបស់ពួកគេដូចជា ទិញសម្លៀកបំពាក់ ទិញសម្ភារៈសិក្សា ចំណីអាហារ ការរៀនគួរបន្ថែម និងចំណាយផ្សេងៗទៀតជាច្រើន។ ការចំណាយរបស់មាតាបិតាសិស្សទាំងផ្លូវការ ទាំងក្រៅផ្លូវការនៅតែមានកម្រិតខ្ពស់ប្រមាណជា ៣០-៣៥% ក្នុងឆ្នាំសិក្សា២០០៣-២០០៤ ទោះបីជាមានការលុបបំបាត់ការបង់ប្រាក់វិភាគទាននៅដើមឆ្នាំសិក្សា និងបញ្ឈប់ការរៃអង្គាសគ្រប់រូបភាពក៏ដោយ[21]។

ទោះបី ការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍខ្លះដោយឥតបង់ថ្លៃយ៉ាងណាក៏ដោយ ក៏នៅក្នុងគ្រួសារក្រីក្របានប្រឈមមុខនឹងការចំណាយរបស់ខ្លួនដោយផ្ទាល់ ដោយប្រយោល នៅពេលពួកគេទៅសាលារៀន។ សូម្បីស្ថិតនៅទីក្រុង និងតំបន់ជនបទដែលសម្ភារៈប្រើប្រាស់មានគ្រប់គ្រាន់យ៉ាងណាក៏ដោយ។ តម្លៃទាំងនេះជាបន្ទុកធ្ងន់ធ្ងររបស់គ្រួសារ ពិសេសគ្រួសារក្រីក្រ។ កត្តាទាំងនេះ បានដាក់សម្ពាធទៅលើមាតាបិតាសិស្សក្នុងការសម្រេចចិត្តថាតើត្រូវបញ្ជូនកូនទៅរៀន ឬអត់ ហើយអាចរក្សាពួកគេនៅក្នុងសាលារៀនបន្ត ឬឱ្យពួកគេឈប់រៀន។ មាតាបិតាខ្លះ បានធ្វើការថ្លឹងថ្លែងដ៏សមហេតុផល អំពីទំនាក់ទំនងរវាងសាលា តម្លៃសង្គម និងផលប្រយោជន៍ដែលទទួលបានពីការអប់រំ។

នៅក្នុងប្រទេសវៀតណាម ប្រជាជន១/៥នៅក្នុងគ្រួសារក្រីក្របំផុតត្រូវតែចំណាយ ២២%នៃចំណូលដែលជាចំណីអាហារ ដើម្បីបញ្ជូនទៅឱ្យកូនគេម្នាក់ទៅសាលារៀន។ ក្នុងប្រទេសនេប៉ាល់ប្រជាជនក្រីក្របំផុតត្រូវចំណាយលើស៤០% នៃចំណូលគ្រួសារជាមធ្យមដើម្បីឱ្យកូនម្នាក់ទៅរៀននៅសាលាបឋមសិក្សាអត្រានេះកើង២ដងក្នុងគ្រួសារអ្នកមានបំផុត។ នៅឥណ្ឌូនេស៊ី ថ្លៃចំណាយទៅបឋមសិក្សាម្នាក់៣៨% នៃចំណូលពីគ្រួសារក្រីក្របំផុត។ ក្នុងប្រទេសហ្សង់តានៀ២០% នៃជាជនដែលក្រីក្របំផុតចំណាយជាមធ្យម៨%នៃចំណូលរបស់គេដើម្បីបញ្ជូនកូនទៅរៀនម្នាក់[22]។

### ២.៣.៤ កត្តាគ្រូបង្រៀន និងសម្ភារៈសិក្សា

ប្រាក់បៀវត្សគ្រូបង្រៀនមិនគ្រប់គ្រាន់ក្នុងការចំណាយ និងសាលារៀនមួយចំនួនខ្វះគ្រូបង្រៀននេះក៏ជាឧបសគ្គមួយដែរក្នុងការសិក្សា កត្តាសំខាន់មួយទៀតដែលទាក់ទងទៅនឹង

[21] ឯកសាររបស់ ADB បានរៀបចំឡើងសម្រាប់សិក្ខាសាលាស្តីអំពីវិធីសាស្រ្តសម្រាប់ទូទាំងវិស័យ "SWAp" ដែលបានប្រព្រឹត្តទៅ ពីថ្ងៃទី១៣១៦មិថុនា ២-០០៥

[22] Oxfam International, 2000

ការបោះបង់ការសិក្សារបស់សិស្ស គឺប្រាក់បៀវត្សគ្រូបង្រៀននៅមានកម្រិតទាបធ្វើឱ្យការបង្រៀនមិនបានល្អបើតាមប្រភពពីធនាគារពិភពលោកក្នុងសិក្ខាសាលាស្តីពីវិធីសាស្ត្រទូទាំងវិស័យអប់រំដែលបានរៀបចំធ្វើឡើងនៅក្នុងខែមិថុនា ឆ្នាំ២០១៥ បានបង្ហាញថា បញ្ហាចម្បងមួយទៀតរបស់វិស័យអប់រំគឺប្រាក់បៀវត្សទាបរបស់គ្រូបង្រៀន។ នេះជាកត្តាមួយដែលត្រូវបានគេទទួលស្គាល់ថាគឺជាបុព្វហេតុដ៏ចម្បងដែលនាំឱ្យគុណភាពអប់រំធ្លាក់ចុះទាបព្រោះនាំឱ្យមានការបង់ថ្លៃក្រៅផ្លូវការដែលកំណត់ដោយគ្រូបង្រៀន ដើម្បីបំពេញកង្វះខាតជីវភាពគ្រួសាររបស់គាត់។ ការបង់ប្រាក់ក្រៅផ្លូវការគឺជាឧបសគ្គមួយដែលរារាំងដល់ការសិក្សារបស់សិស្សក្រីក្រផងដែរ។

**តារាងទី២** ទិន្នន័យសិស្សបោះបង់កាសិក្សាពីឆ្នាំ២០១៧ដល់២០១៨ក្នុងខេត្តកំពង់ធំ

| កម្រិតសិក្សា | ឆ្នាំសិក្សា២០១៧-២០១៧ | | ឆ្នាំសិក្សា២០១៧-២០១៨ | |
|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី |
| បឋមសិក្សា | ៤,៨% | ៤,២% | ៥,៣% | ៤,១% |
| ឆ្លងភូមិសិក្សា | ៨៧,៨% | ៨៨,៤% | ៨៩,២១% | ៨៩,៩% |

(ដកស្រង់ពីសៀវភៅ ស្ថិតិ និងអាំងឌីកាទ័រអប់រំនៅខេត្ត កំពង់ធំ)

តារាងខាងលើជាទិន្នន័យការបោះបង់កាសិក្សានាឆ្នាំកន្លងមកក្នុងខេត្តកំពង់ធំ។ តាមតារាងខាងលើយើងសង្កេតឃើញថាក្នុងឆ្នាំ២០១៦-២០១៧ សិស្សបោះបង់ការសិក្សាត្រឹម ៤,៨%តែប៉ុណ្ណោះ។ តែមកដល់ឆ្នាំសិក្សា២០១៧-២០១៨ អត្រាបោះបង់ការសិក្សានៅបឋមសិក្សាមានការកើនឡើងមានរហូតដល់៥,៣% មានន័យថាក្នុងឆ្នាំនោះការបោះបង់ការសិក្សានៅបឋមសិក្សាមានកម្រិតខ្ពស់បើប្រៀបធៀបនឹងឆ្នាំកន្លងទៅ។

ជារួមក្នុងឆ្នាំសិក្សាកន្លងមក សិស្សានុសិស្សនៅបឋមសិក្សា ក្នុងខេត្តកំពង់ធំ មានអត្រាបោះបង់ការសិក្សាខ្ពស់ជាងគេគឺថ្នាក់ទី៦។ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ សិស្សបោះបង់ការសិក្សាមានអត្រាខ្ពស់ជាឆ្នាំសិក្សាផ្សេងទៀត។ ដោយឡែក តាមរបាយការណ៍ស្តីពីសភាពការណ៍អប់រំបឋមសិក្សានៅដំណាច់ឆ្នាំសិក្សា២០១៧-២១០៨ ដែលទើបតែកន្លងផុតទៅថ្មីៗនេះបានបង្ហាញឱ្យឃើញថាចាប់តាំងពីដើមបវេសនកាលរហូតមកដល់ដំណាច់ឆ្នាំសិក្សានេះសិស្ស

បោះបង់ការសិក្សានៅបឋមសិក្សាមានចំនួន ៧៥ ២១៩នាក់ ស្មើនឹង៥,៣%(ស្រី៤,១%) បើប្រៀបធៀបទៅឆ្នាំសិក្សា២០១៦-២០១៧ គឺកើនចំនួន០,៥០%។ តាមរបាយការណ៍ខាងលើក៏បង្ហាញផងដែរថា នៅដើមឆ្នាំសិក្សានីមួយៗ កុមារតែងតែនាំគ្នាទៅចុះឈ្មោះចូលរៀនយ៉ាងច្រើន។ ប៉ុន្តែ បន្ទាប់ពីបានបន្តការសិក្សាមួយរយៈពេលមក សិស្សមួយចំនួនបានបោះបង់ការសិក្សាដោយសារបញ្ហាខ្វះលទ្ធភាពបន្តការសិក្សាដូចជាៈ ខ្វះមធ្យោបាយធ្វើដំណើរពីផ្ទះទៅសាលារៀន ជីវភាពខ្វះខាតក្នុងក្រុមគ្រួសារ បម្រើការងារក្នុងរោងចក្រកាត់ដេរ រៀបអាពាហ៍ពិពាហ៍ប្រកបរបរអាជីវកម្ម ឬបង្កបង្កើនផល...។តាមរបាយការណ៍នោះក៏បានបង្ហាញទៀតថា ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ចំនួនសិស្សនៅបឋមសិក្សា បានកើនឡើងខ្ពស់ដែលចោទជាបញ្ហាប៉ះពាល់ផ្នែកគុណភាពអប់រំ និងបណ្តាលឱ្យសិស្សមួយចំនួនបោះបង់ការសិក្សាផងដែរ ដោយសារសាលារៀនមួយចំនួន ខ្វះបន្ទប់រៀន ខ្វះគ្រូបង្រៀន ខ្វះបង្គន់អនាម័យ ខ្វះបន្ទប់ទឹក និងទឹកស្អាត ខ្វះបណ្ណាល័យ ខ្វះសៀវភៅសិក្សាគោល ខ្វះការអប់រំបំណិនជីវិត...។

## ស្ថានភាពនៃការចុះឈ្មោះចូលរៀន និងការបោះបង់ការសិក្សានៅបឋមសិក្សាក្នុងប្រទេសកម្ពុជា

ក្នុងផ្នែកនេះ យើងនឹងលើកឡើងពីស្ថានភាពនៃការចុះឈ្មោះចូលរៀន និងការបោះបង់ការសិក្សានៅថ្នាក់បឋមសិក្សាដោយផ្អែកលើទិន្នន័យរបស់EMIS។ ជារៀងរាល់ឆ្នាំ EMIS បានមូល និងវិភាគទិន្នន័យដែលប្រមូលបានពីសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា។ ទិន្នន័យក្នុង EMIS បានបង្ហាញពីស្ថានភាពថ្មីៗរបស់សាលារៀន ដូចជាអត្រានៃការចុះឈ្មោះចូលរៀន និងអត្រាការបោះបង់ការសិក្សាទៅតាមសាលាបឋមសិក្សា និងឆ្លងភូមិសិក្សាទៅអនុវិទ្យាល័យនានា ។

តារាងខាងក្រោម បង្ហាញអំពីអត្រាចុះឈ្មោះចូលរៀន នៅអនុវិទ្យាល័យ ក្រោយការបញ្ចប់ការសិក្សានៅថ្នាក់ទី៦។ មធ្យមភាគនៃអត្រាចុះឈ្មោះចូលរៀនទូទាំងប្រទេសគឺ៨៥,៥% ក្នុងឆ្នាំសិក្សា២០១៥-២១០៦។

**តារាងទី៣** អត្រាចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យ របស់សិស្សដែលបានបញ្ចប់ថ្នាក់ទី៦(គិតជា%)ក្នុងឆ្នាំសិក្សា២០១៥-២១០៦

| ឈ្មោះខេត្ត ក្រុង | សិស្សសរុប | សិស្សស្រី |
|---|---|---|
| បន្ទាយមានជ័យ | ៨៣,៥ | ៨៥,៩ |

| | | |
|---|---|---|
| បាត់ដំបង | ៧៩,៤ | ៨១,៩ |
| កំពង់ចាម | ៨៥,២ | ៨៨,៤ |
| កំពង់ឆ្នាំង | ៨៨,២ | ៩១,៣ |
| កំពង់ស្ពឺ | ៨៥,៨ | ៨៨,៣ |
| កំពង់ធំ | ៨៥,៧ | ៨៧,៣ |
| កំពត | ៨៨,៥ | ៩១,១ |
| កណ្ដាល | ៨៨,១ | ៩២,០ |
| កែប | ៩០,១ | ៩៤,៥ |
| កោះកុង | ៨៦,៩ | ៨៦,១ |
| ក្រចេះ | ៧៣,៨ | ៧៥,៣ |
| មណ្ឌលគិរី | ៧៩,៤ | ៨០,២ |
| ឧត្ដរមានជ័យ | ៧៩,៩ | ៨២,៩ |
| ប៉ៃលិន | ៩៣,១ | ៩៣,៧ |
| ភ្នំពេញ | ៩៣,១ | ៩៥,២ |
| ព្រះវិហារ | ៨១,៤ | ៨៤,២ |
| ព្រៃវែង | ៨០,៦ | ៨២,៩ |
| ពោធិសាត់ | ៨៨,១ | ៩៣,២ |
| រតនគិរី | ៨៥,៣ | ៨៧,៣ |
| សៀមរាប | ៨០,៣ | ៧៨,៩ |
| ក្រុងព្រះសីហនុ | ៨៦,១ | ៨៩,៣ |
| ស្ទឹងត្រែង | ៦៨,២ | ៦៧,៩ |
| ស្វាយរៀង | ៨៩,៨ | ៩២,៦ |
| តាកែវ | ៩០,៨ | ៩៣,៧ |
| ត្បូងឃ្មុំ | ៧៨,៨ | ៨១,០ |
| ទូទាំងប្រទេស | ៨៥,៥ | ៨៨,៣ |

តាមតារាងខាងលើបានបង្ហាញថា មានសិស្សជាច្រើនដែលបានបោះបង់ការសិក្សានៅពេលរៀននៅបឋមសិក្សា និងមួយចំនួនទៀតដែលបានបញ្ចប់ការសិក្សានៅថ្នាក់ទី៦ពុំបានបន្តការសិក្សារបស់ពួកគេនៅអនុវិទ្យាល័យទេ ទោះបីជាពួកគេត្រូវបានឡើងថ្នាក់ឱ្យរៀនបន្តទៅអនុវិទ្យាល័យក៏ដោយ នៅតាមទីប្រជុំជនអត្រាចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យមានកម្រិតខ្ពស់ ទទឹមនឹងនេះដែរនៅតាមតំបន់ឯទៀតអត្រាចុះឈ្មោះចូលរៀនកម្រិតទាប ។ ភាពខុសគ្នាវាហាក់ដូចជាបណ្តាលមកពីកត្តាភូមិសាស្ត្រ ដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើការចុះឈ្មោះចូលរៀន។ ម្យ៉ាងទៀត ទោះបីជានៅតាមសាលាបឋមសិក្សាត្រូវបានកាត់បន្ថយនូវអត្រាបោះបង់ការសិក្សាក៏ដោយ ក៏អត្រាបោះបង់នៅអនុវិទ្យាល័យ មិនត្រូវបានកាត់បន្ថយដែរ។ ទោះបីជាអត្រាបោះបង់ថ្នាក់ជាតិស្ថិតនៅថេរក៏ដោយ ក៏អត្រាបោះបង់ការសិក្សាតាមខេត្ត ទៅតែមានការប្រែប្រួលដដែល។

# ជំពូកទី៣៖
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖

# វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ និងបែបបរិមាណវិស័យ។ វិធីសាស្ត្រទាំងពីរនេះត្រូវបានប្រើប្រាស់ជាមធ្យោបាយដើម្បីសង្កេតពីមូលហេតុសំខាន់ៗនៃការបោះបង់ការសិក្សារបស់សិស្សថ្នាក់បឋមសិក្សាក្នុងខេត្តកំពង់ធំ ប្រទេសកម្ពុជា។ ទោះបីយ៉ាងណាក៏ដោយ វាមានសារៈសំខាន់ណាស់ដើម្បីបង្ហាញដោយសង្ខេបអំពីប្រភេទទិន្នន័យ និងវិធីនីមួយៗ។

## ៣.១ វិធីសាស្ត្របែបគុណវិស័យ

ការប្រមូលទិន្នន័យ ឬសាកសួរព័ត៌មានដោយគ្មានកម្រងសំណួរត្រូវបានធ្វើឡើងជាមួយលោកនាយកសាលា លោកគ្រូ អ្នកគ្រូ អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋក្នុងសហគមន៍ សិស្សានុសិស្សដែលជាមិត្តភក្តិរបស់សិស្សបោះបង់។ មិនតែប៉ុណ្ណោះ យើងបានប្រមូល និងដកស្រង់ព័ត៌មានមួយចំនួនដែលពាក់ព័ន្ធនឹងមូលហេតុនៃការបោះបង់ការសិក្សា ពីកម្រងសាលាបឋមសិក្សាគោលដៅទាំងពីរ និងពីមន្ទីរអប់រំយុវជន និងកីឡាខេត្តថែមទៀត ។

## ៣.២ វិធីសាស្ត្របែបបរិមាណវិស័យ

វិធីតាមបែបបរិមាណវិស័យ ទាក់ទងទៅនឹងការប្រមូលទិន្នន័យ និងការផ្ទៀងផ្ទាត់អត្ថបទនៃទិន្នន័យតាមសាលាបឋមសិក្សាដែលទទួលបានពីការសម្ភាស ជាមួយសិស្សបោះបង់ការសិក្សា និងមាតាបិតាដែលមានកូនបោះបង់ការសិក្សា។ ការប្រើប្រាស់គោលការណ៍ស្រាវជ្រាវក៏បានប្រមូលផងដែរពីមូលហេតុនៃការបោះបង់ការសិក្សាដែលបានមកពីប្រភពនៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដែលអ្នកស្រាវជ្រាវមុនៗបានរកឃើញដើម្បីពន្យល់ និងប្រៀបធៀបជាមួយមូលហេតុដែលបានរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ។

## ៣.៣ ការជ្រើសរើសសាលាគោលដៅ

ការសិក្សាស្រាវជ្រាវនេះ បានជ្រើសរើសកម្រងសាលាបឋមសិក្សាពីរ ក្នុងខេត្ត

កំពង់ធំ។ កម្រងសាលាបឋមសិក្សាទាំងពីរនេះទីតាំងស្ថិតនៅតំបន់ជនបទ ឆ្ងាយពីទីប្រជុំជន៖

- កម្រងសាលាបឋមសិក្សាត្នោតជុំ ស្ថិតនៅចម្ងាយប្រមាណ ៣០គីឡូម៉ែត ភាគនារតីនៃទីរួមខេត្តកំពង់ធំ តាមបណ្តោយផ្លូវលំមួយ ដែលជាតំបន់ជនបទ។ នៅឆ្នាំសិក្សា ២០១៧-២១០៨ កម្រងសាលានេះមានសាលាសម្ព័ន្ធចំនួន៤ មានសិស្សសរុបចំនួន១១១៦នាក់ ក្នុងនោះ ស្រី៥៣៩នាក់[23] ។
- កម្រងសាលាបឋមសិក្សាសានគរ ស្ថិតនៅចម្ងាយប្រមាណ២៥គីឡូម៉ែត្រ ភាគពាយ័ព្យទីរួមខេត្តកំពង់ធំ តាមបណ្តោយផ្លូវជាតិលេខ៦ ដែលជាតំបន់ជនបទ។ នៅឆ្នាំសិក្សា ២០១៧-២០១៨ កម្រងសាលានេះមានសាលាសម្ព័ន្ធចំនួន៨ សិស្សសរុបមានចំនួន ២០៩៤ នាក់ ស្រី ១០៦០នាក់[24]។

## ៣ ៤. កម្រងសំណួរស្រាវជ្រាវ

កម្រងសំណួរស្រាវជ្រាវពីរត្រូវបានយកមកប្រើប្រាស់ក្នុងការសិក្សានេះ (ឧបសម្ព័ន្ធ)។ សិស្សបោះបង់ត្រូវបានសម្ភាសដោយប្រើកម្រងសំណួរមួយ ដែលប្រមូលទិន្នន័យទៅលើអាយុ ភេទ មុខរបរមាតាបិតាសិស្ស ចំនួនបងប្អូនបង្កើត កម្រិតថ្នាក់ដែលពួកគេបានបោះបង់ការសិក្សា មធ្យោបាយ និងរយៈពេលធ្វើដំណើរពីផ្ទះទៅសាលារៀន។ យើងក៏បានសួរផងដែរអំពីអ្នកដែលសម្រេចចិត្តឱ្យពួកគេឈប់រៀន មុខរបរដែលពួកគេធ្វើបន្ទាប់ពីបោះបង់ និងពីបំណងចង់ចូលរៀនវិញរបស់ពួកគេ ព្រមទាំងមានសំណួរស្តីអំពីមូលហេតុនៃការបោះបង់ចំនួន១២សំណួរទៀតផង។ កម្រងសំណួរស្រាវជ្រាវមួយទៀតត្រូវសម្ភាសជាមួយមាតាបិតា ឬអាណាព្យាបាលរបស់សិស្សបោះបង់ការសិក្សា ដើម្បីប្រមូលព័ត៌មានអំពីភេទ អាយុ ចំនួនកូន មុខរបរជីវភាពគ្រួសារ អ្នកសម្រេចចិត្តឱ្យកូនឈប់រៀន ទីលំនៅ មុខរបររបស់កូនគាត់ក្រោយពេលបោះបង់ បំណងចង់ឱ្យកូនៗចូលរៀនវិញ និងមានសំណួរស្តីពីមូលហេតុដែលនាំឱ្យកូនបោះបង់ការសិក្សាចំនួន១២សំណួរ។

[23] របាយការណ៍បូកសរុបការិយាល័យអប់រំ យុវជន និងកីឡា ស្រុកបារាយណ៍

[24] ប្រភព អន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពង់ធំ, ២០១៨

## ៣.៥ គំរូសំណាក

ការជ្រើសរើសគំរូសំណាក គឺជ្រើសរើសដោយចៃដន្យដែលជាលទ្ធផលយើងទទួលបានសិស្សបោះបង់ដែលធ្លាប់បានរៀន ឬមានឈ្មោះត្រូវរៀននៅថ្នាក់ទី៥ចំនួន ១៣នាក់ និងថ្នាក់ទី៦ មានចំនួន ១៧នាក់ ដែលពួកគេទាំងនេះមានអាយុចន្លោះពី ១០ ដល់១៦ឆ្នាំ ។

**តារាងទី៤** ចំនួនសិស្សបោះបង់តាមក្រុមអាយុ និងតាមកម្រិតថ្នាក់

| អាយុ | ថ្នាក់ទី៥ | ថ្នាក់ទី៦ | សរុប |
|---|---|---|---|
| ១០-១៣ | ៦ | ៧ | ១៣ |
| ១៤-១៦ | ៧ | ១០ | ១៧ |
| សរុប | ១៣ | ១៧ | ៣០ |

តារាងខាងលើ បង្ហាញពីចំនួននៃគំរូសំណាក ដែលយើងធ្វើការសម្ភាស ក្រោយពេលពួកគេបានបោះបង់ការសិក្សា។ ចំនួនសិស្សដែលត្រូវបានជ្រើសរើសយកមកធ្វើជាគំរូសំណាកមានចំនួន៣០នាក់ ស្រី១២នាក់ ក្នុងនោះសិស្សបោះបង់នៅកម្រងសាលារៀនត្នោតជុំមានចំនួន ១១នាក់ និងនៅកម្រងសាលារៀនសានគរ ចំនួន ១៩នាក់។

**តារាងទី៥** ចំនួនសិស្សបោះបង់តាមភេទ តាមសាលារៀនគោលដៅ

| ភេទ | សាលាកម្រងត្នោតជុំ | សាលាកម្រងសានគរ | សរុប |
|---|---|---|---|
| ប្រុស | ៥ | ៧ | ១២ |
| ស្រី | ៦ | ១២ | ១៨ |
| សរុប | ១១ | ១៩ | ៣០ |

ក្នុងចំណោមពួកគេទាំង៣០នាក់ មាន១៨នាក់ រស់នៅជាមួយមាតាបិតា ៧នាក់រស់នៅជាមួយតែមាតា ៤នាក់រស់នៅជាមួយជីដូននឹងមានតែ១នាក់ប៉ុណ្ណោះ ដែលរស់នៅតែជាមួយបិតា។ ហើយក្នុងចំណោមទាំង៣០នាក់នេះ ពួកគេមានបងប្អូនបង្កើត

ចន្លោះពី១-៣នាក់ មានចំណួន១៧នាក់ ចន្លោះពី៤-៦នាក់ មានចំនួន១២នាក់ ចន្លោះពី៧-៩នាក់មានចំនួន២នាក់។

**តារាងទី៦** ចំនួនបងប្អូនបង្កើតរបស់សិស្សបោះបង់

| ចំនួនបងប្អូនបង្កើត | ចំនួន | ភាគរយ |
|---|---|---|
| ១-៣ | ១៦ | ៥៣,៣៣% |
| ៤-៦ | ១២ | ៤០% |
| ៧-៩ | ២ | ៦,៦៦% |
| សរុប | ៣០ | ១០០% |

ចំណែកមាតាបិតា ឬអាណាព្យាបាលសិស្សបោះបង់ ដែលត្រូវបានជ្រើសរើសធ្វើគំរូសំណាកមានចំនួន៣០នាក់ ក្នុងនោះម្តាយមានចំនួន១៦នាក់។ មាតាបិតា ឬអាណាព្យាបាលសិស្សបោះបង់ ដែលយើងបានសម្ភាសទាំង៣០នាក់ ពួកគាត់មានអាយុចន្លោះពី៤០-៦៨ឆ្នាំ មានទីលំនៅក្នុងស្រុកកំពង់ស្វាយ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ក្នុងចំណោមពួកគាត់ទាំងអស់មានកូនចន្លោះពី ២-៩ នាក់ដូចគ្រួសារដទៃទៀតដែរ។ ក្នុងចំណោមពួកគាត់ទាំងអស់ ដែលយើងបានធ្វើការសម្ភាស មាន១៨នាក់ធ្លាប់រៀននៅថ្នាក់បឋមសិក្សា ៩នាក់ធ្លាប់បានរៀននៅថ្នាក់មធ្យមសិក្សាបឋមភូមិ និងមានតែ៣នាក់ប៉ុណ្ណោះដែលធ្លាប់បានរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិ។

យើងអ្នកស្រាវជ្រាវបានចុះប្រមូលទិន្នន័យសិស្សបោះបង់ការសិក្សាពី នាយកសាលា និងប្រធានកម្រង លោកគ្រូ អ្នកគ្រូ នាឆ្នាំសិក្សា ២០១៧-២១០៨ ក្នុងកម្រងទាំងពីរគឺកម្រងត្នោតជុំ ស្ថិតក្នុងស្រុកបារាយណ៍ និងកម្រងសានគរស្ថិតនៅស្រុកកំពង់ស្វាយ ខេត្តពង់ធំ ។ បន្ទាប់មកអ្នកស្រាវជ្រាវ បានចុះសម្ភាសសិស្សដែលបោះបង់ការសិក្សាក្នុងសាលាបឋមសិក្សា គឺកម្រិតថ្នាក់ទី៥ និងទី៦ នៅតាមមូលដ្ឋានដែលពួកគេរស់នៅ និងសម្ភាសមាតាបិតា ឬអាណាព្យាបាលដែលមានកូនបោះបង់ការសិក្សា។

ការសម្ភាសនេះគឺ សម្ភាសទាំងសិស្សបោះបង់ការសិក្សា និងទាំងមាតាបិតា ឬអាណាព្យាបាលសិស្សបោះបង់ការសិក្សា ឬសម្ភាសតែសិស្ស ឬសម្ភាសតែមាតាបិតា ឬ

អាណាព្យាបាលសិស្សដែលបោះបង់ការសិក្សាតែប៉ុណ្ណោះក្នុងគ្រួសារពួកគេនីមួយៗ។ អ្នកស្រាវជ្រាវបានធ្វើការសម្ភាសិស្សបោះបង់កាសិក្សាចំនួន៣០នាក់ ក្នុងនោះស្រីចំនួន១៨នាក់ សម្ភាសមាតាបិតាសិស្សចំនួន ៣០នាក់ផងដែរ ដោយប្រើកម្រងសំណួរជាទម្រង់បិទ និងទម្រង់បើកដែលបានចំណាយពេលអស់៥ សប្តាហ៍។

## ៣.៦ ការវិភាគទិន្នន័យ

ចំពោះកិច្ចការស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យ ដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានវិភាគដាច់ដោយឡែកពីគ្នាទៅតាមប្រភេទនៃសំណាកនីមួយៗ(នាយកសាលា គ្រូបង្រៀន មាតាបិតា ឬអាណាព្យាបាលសិស្ស) បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវ បានសំយោគបញ្ចូលគ្នាដោយផ្តោតលើចំណុចសំខាន់ៗដូចជា៖ ការយល់ឃើញរបស់សិស្សលើការបោះបង់ការសិក្សា គណៈគ្រប់គ្រងសាលា គ្រូបង្រៀន និងការដឹកនាំគ្រប់គ្រងសាលា បញ្ហាប្រឈម និងផលលំបាក និងតម្រូវការដែលបម្រើឱ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ។

ដើម្បីឆ្លើយតបទៅនឹងចំណុចទាំងនេះ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធី SPSS សម្រាប់ស្វែងរកតម្លៃមធ្យម ភាគរយ និងប្រេកង់ និងកម្មវិធី Ms. Excel សម្រាប់សង់ក្រាប ធ្វើតារាង និងបកស្រាយព័ត៌មានរបស់ធាតុសំណាកនីមួយៗ។ ចំណែកការវិភាគទិន្នន័យបែបគុណវិស័យគឺអ្នកសិក្សាស្រាវជ្រាវបានប្រមូលផ្តុំចម្លើយរបស់ភាគីពាក់ព័ន្ធដែលទទួលបានតាមរយៈការសម្ភាស និងអង្កេតក្នុងគោលបំណងស្វែងរកឱ្យឃើញពីបញ្ហាប្រឈម និងតម្រូវការក្នុងការសិក្សានៅតាមសាលាបឋមសិក្សានានាក្នុងខេត្តកំពង់ធំ និងផ្តុំមតិ សំណូមរបស់សិស្ស គ្រូ និងនាយកដាក់ទៅតាមចំណុចដែលដូចគ្នាក្នុងគោលបំណងលើកជាសំណូមពរចំពោះក្រសួងអប់រំ មន្ទីរអប់រំខេត្ត ការិយាល័យអប់រំស្រុក សាលារៀន និងលោកគ្រូ អ្នកគ្រូ ដើម្បីជ្រាបជាព័ត៌មាន ធ្វើការកែទម្រង់ និងចាត់ជាវិធានការចំពោះបញ្ហាប្រឈមដែលកើតមានឡើង។

## ៣.៧ ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវ បានផ្តោតការយកចិត្តទុកដាក់ពីក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវចំពោះភាគីពាក់ព័ន្ធ ពីព្រោះវាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធានាប្រសិទ្ធភាពនៃការស្រាវជ្រាវ ក៏ដូចជាបង្កើននូវភាពជឿជាក់ និងភាពទុកចិត្តបាន

ចំពោះអ្នកចូលរួមផ្តល់ចម្លើយ។ ម្យ៉ាងវិញទៀត ទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះ គឺគ្មានភាពលម្អៀង។ អ្នកសិក្សាស្រាវជ្រាវ បានរក្សាក្រមសីលធម៌ខ្ពស់ក្នុងដំណាក់កាលនីមួយៗមុនពេលស្រាវជ្រាវដូចជាៈ សុំការអនុញ្ញាតដោយធ្វើលិខិតស្នើសុំពីមន្ទីរអប់រំខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាស្រុក និងសាលាគោលដៅដើម្បីសុំការឯកភាព និងសហការនៅក្នុងអំឡុងពេលស្រាវជ្រាវ។ អ្នកសិក្សាស្រាវបានណែនាំពីគោលបំណងនិងសារៈប្រយោជន៍នៃការសិក្សាស្រាវជ្រាវដល់អ្នកចូលរួមឱ្យបានជ្រាប និងចូលរួមផ្តល់ចម្លើយដែលអាចទុកចិត្តបាន និងរក្សាភាពអនាមិកនូវចម្លើយរបស់ពួកគាត់ និងក្រោយពេលស្រាវជ្រាវ អ្នកសិក្សាស្រាវជ្រាវ បានរក្សាភាពស្មោះត្រង់ចំពោះការបញ្ចូលទិន្នន័យនូវចម្លើយរបស់អ្នកចូលរួមដោយមិនបំផ្លើសនិងបំពេញបន្ថែមលើចំណុចណាមួយឡើយ។ ការធ្វើបែបនេះ គឺមានន័យថា ការសិក្សាស្រាវជ្រាវនេះនឹងទទួលបានលទ្ធផលល្អ និងជឿទុកចិត្តបានហើយវាក៏ជាភស្តុតាងមួយបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យប្រកបដោយភាពត្រឹមត្រូវ និងក្រមសីលធម៌ខ្ពស់ក្នុងនាមជាអ្នកសិក្សាស្រាវ។

# ជំពូកទី៤៖

# លទ្ធផលស្រាវជ្រាវ

# ជំពូកទី៤៖

# លទ្ធផលនៃការស្រាវជ្រាវ

## ៤.១ របកគំហើញពីកម្រងសំណួរ

ក្រោយពីបានធ្វើការសម្ភាសរួចមក យើងសង្កេតឃើញថាក្នុងចំណោមសិស្សបោះបង់ការសិក្សាចំនួន៣០នាក់ កាលពីពួកគេទៅរៀនធ្វើដំណើរទៅសាលារៀនតាមមធ្យោបាយផ្សេងៗពីគ្នាគឺដោយថ្មើរជើង ដោយកង់ និងដោយលាយឡំគ្នា។ ចំណែកការចំណាយពេលពីផ្ទះទៅសាលាឬពីសាលាមកផ្ទះក៏មានរយៈពេលផ្សេងៗពីគ្នាគឺស្ថិតនៅចន្លោះពី ៥នាទីទៅ ២៥នាទី ហើយអ្នកដែលសម្រេចចិត្តឱ្យពួកគេបោះបង់ការសិក្សាក៏មានភាពខុសគ្នាដែរ(ក្រាបទី១)។

**ក្រាបទី១** អ្នកដែលសម្រេចចិត្តឱ្យសិស្សបោះបង់




<u>ប្រភពសម្ភាសសិស្ស</u>

ក្រាបខាងលើបង្ហាញថា អ្នកដែលសម្រេចចិត្តឱ្យសិស្សបោះបង់ការសិក្សាគឺ ដោយសិស្សខ្លួនឯងផ្ទាល់មានចំនួន៥នាក់(១៦,៦៧%) ដោយមាតាបិតាមានចំនួន១១នាក់(៣៦,៦៧%) ដោយការព្រមព្រាងរវាងមាតាបិតានិងសិស្ស មានចំនួន១៤នាក់ (៤៦,៦៧%) តួលេខនេះបានបង្ហាញឱ្យយើងឃើថា សិស្សនៅបឋមសិក្សាជាច្រើនមិនអាចសម្រេច

ចិត្តធ្វើអ្វីមួយដោយខ្លួនពួកគេនោះឡើយ។

ពេលអ្នកស្រាវជ្រាវសួរថា៖ ក្រោយពីការបោះបង់ការសិក្សា តើពួកគេប្រកបមុខរបរអ្វី? ពួកគេចំនួន៨នាក់(២៦,៦៧%) បានឆ្លើយថាពួកគេធ្វើការងារដោយមានប្រាក់ចំណូល ១៣នាក់(៤៣,៣៣%) ឆ្លើយថាពួកគេធ្វើការងារដែលគ្មានប្រាក់ចំណូល និង៩នាក់ទៀត(៣០%)ឆ្លើយថាពួកគ្មានធ្វើអ្វីទាំងអស់(ក្រាបទី២)។ ម្យ៉ាងទៀត ពេលអ្នកស្រាវជ្រាវសួរថា៖ ចាប់តាំងពីប្អូនឈប់រៀន តើមិត្តភក្តិ ឬគ្រូរបស់ប្អូនធ្លាប់បានហៅប្អូនឱ្យចូលរៀនវិញដែរឬទេ? ៩នាក់ ត្រូវជា(៣០%) បានឆ្លើយថាធ្លាប់ ចំណែក២១នាក់ផ្សេងទៀតត្រូវជា(៧០%) បានឆ្លើយថា ពួកគេមិនដែលមានអ្នកហៅចូលរៀនវិញទេ។

**ក្រាបទី២** ស្ថានភាពការងារដែលពួកគេបានធ្វើក្រោយពីការបោះបង់ការសិក្សា




តាមការសាកសួរព័ត៌មាន ដែលទទួលបានពីសិស្សបោះបង់ការសិក្សាបានបង្ហាញថាចំនួន៣៦,៦៧% ឈប់រៀនដើម្បីទៅរកការងារធ្វើដែលមានប្រាក់ចំណូល ដូចជា កម្មករកាត់ដេរ ជាងសំណង់ រត់ម៉ូតូឌុប...។ រីឯ ៤៦,៦៧% ពួកគេឈប់រៀនដើម្បីជួយធ្វើការងារផ្ទះដោយគ្មានប្រាក់ចំណូល ដូចជាមើលប្អូន ធ្វើស្រែចំការ ឃ្វាលគោ ក្របី..។ ចំណែក១៦,៦៧% ពួកគេគ្មានធ្វើអ្វីទាំងអស់មានន័យថា ពួកគេមានភាពទំនេរច្រើន ចូនកាលដើរលេងបង្ករឿងហេតុជាមួយអ្នកដទៃ ដែលធ្វើឱ្យមាតាបិតា ឬអាណាព្យាបាលទាំងឡាយមិនពេញចិត្តទាល់តែសោះ។ក្នុងផ្នែកនេះ របាយការណ៍ស្រាវជ្រាវពីមូលហេតុ

នៃការបោះបង់ការសិក្សានៅ បឋមសិក្សាក្នុងខេត្តកំពង់ធំ ចែកចេញជា៥កត្តាធំៗគឺៈ កត្តាជីវភាពគ្រួសារ(ឬភាពក្រីក្រ) កត្តាភេទនិងអាយុ កត្តាសាលារៀននិងគ្រូបង្រៀន កត្តាសង្គមនិងកត្តាសិស្សផ្ទាល់។

**៤.១.១ កត្តាជីវភាពគ្រួសារ** (ភាពក្រីក្រ)

ភាពក្រីក្រ គឺជាឧបសគ្គធំមួយចំពោះការអប់រំរបស់មនុស្សជាពិសេសកុមារ និងយុវជន។ ភាពក្រីក្រធ្វើឱ្យកុមារ និងយុវជន ត្រូវធ្វើការដោយកម្លាំង ដើម្បីជីវិតរស់នៅរបស់ពួកគេដែលធ្វើឱ្យឱកាសនៃការសិក្សាទាំងផ្នែកចំណេះដឹងទ្រឹស្តី និងផ្នែកបំណិនជីវិតត្រូវបានកម្រិត។ ក្នុងចំណុចនេះបង្ហាញថា ពួកគេឈប់រៀនមកពីមូលហេតុគ្រួសារក្រីក្រ។ តាមការវាយតម្លៃជាច្រើន បានបង្ហាញពីកម្រិតនៃភាពក្រីក្រនៅកម្ពុជា។ តាមការប៉ាន់ស្មានបានឱ្យដឹងថាសន្ទស្សន៍អង្កេតពីភាពក្រីក្រនៅឆ្នាំ១៩៩៩ មាន៣៦%[25]។ ទោះបីជាការប្រៀបធៀបរង្វាស់នៃភាពក្រីក្រខុសៗគ្នាមានការលំបាកក៏ដោយ ក៏អត្រានៃភាពក្រីក្រហាក់ដូចជាពុំមានការប្រែប្រួល ជាដុំកំភួនឡើយចាប់តាំងពីឆ្នាំ១៩៩៧មក។ ភាពក្រីក្រមានអត្រាខ្ពស់ទៅតាមតំបន់ជនបទ ដែលមានប្រជាពលរដ្ឋក្រីក្រប្រហែលជា៩០,៥០% ប្រជាពលរដ្ឋក្រីក្រខ្លះទៀតរស់នៅតាមតំបន់ទីក្រុងផ្សេងៗទៀត(៧,២%) និងរស់នៅរាជធានីភ្នំពេញ(២,៣%)។ អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាឆ្នាំ១៩៩៩មិនបានបញ្ជាក់ពីតួលេខទាំងនេះទេ។ ប្រាក់ចំណូលប្រចាំឆ្នាំជាមធ្យមនៅតាមតំបន់ជនបទ មានតិចជាងមួយភាគបីប្រាក់ចំណូលរបស់ប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ(ក្នុងមួយឆ្នាំប្រជាពលរដ្ឋនៅតាមជនបទរកបានតែ១៩៧ដុល្លារសហរដ្ឋអាមេរិកប៉ុណ្ណោះ ចំណែកឯប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញវិញរកបានដល់ទៅ ៦៩១ដុល្លារ សហរដ្ឋអាមេរិក)។ ប្រទេសកម្ពុជាធ្វើការប្រៀបធៀបសន្ទស្សន៍ភាពក្រីក្រ ជាមួយប្រទេសអាស៊ានផ្សេងទៀតឃើញថាការប្រៀបធៀបសម្រាប់ប្រទេសកម្ពុជាមានលក្ខណៈមិនអំណោយផលឡើយ។ ឧទាហរណ៍: តាមសន្ទស្សន៍ភាពក្រីក្រ ដែលធ្វើឡើងដោយកម្មវិធីអភិវឌ្ឍសហប្រជាជាតិប្រចាំនៅកម្ពុជាបានឱ្យដឹងថា ភាពក្រីក្រមានដល់ទៅ៤២,៥% ប្រៀបធៀបតួលេខនៃប្រទេសកំពុងអភិវឌ្ឍនៅតំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីប៉ាស៊ីហ្វិចមានតែ២៥% ប៉ុណ្ណោះ។ ការរៀនមិនចប់បឋមសិក្សា លទ្ធភាពទទួលបានសេវាសុខភាពអនាម័យ និងអាហារូបត្ថម្ភកុមារខ្សត់ខ្សោយ ជាកត្តាសំខាន់ដែលបណ្តាលឱ្យសន្ទស្សន៍ភាពក្រីក្រនៅកម្ពុជាមាន

[25] ទិដ្ឋភាពនៃភាពក្រីក្រឆ្នាំ១៩៩៥

កម្រិតខ្ពស់។ ការបង្កើនលទ្ធភាពទទួលបានសេវាអប់រំមូលដ្ឋាននៅតាមតំបន់ជនបទគឺជាអាទិភាពចម្បងមួយក្នុងការកាត់បន្ថយអត្រាភាពក្រីក្ររបស់ ប្រជាពលរដ្ឋ[26]។ភាពក្រីក្រនៅតាមតំបន់ជនបទ និងទីក្រុងមានលក្ខណៈមិនស្មើគ្នា។ ឧទាហរណ៍ៈសន្ទស្សន៍ភាពក្រីក្រនៅតំបន់ទីក្រុង(១៦%នៃប្រជាជនទាំងអស់)គឺមាន៣៤,២។ ផ្ទុយទៅវិញតួលេខនៅតាមតំបន់ជនបទមាន៤៤,៩ %សម្រាប់៨៤%នៃប្រជាជនទាំងអស់។ប្រជាពលរដ្ឋតាមទីក្រុងមានអាយុកាលមធ្យមលើល៥ឆ្នាំច្រើនជាងប្រជាពលរដ្ឋរស់នៅតំបន់ជនបទនិងទទួលបានកម្រិតអប់រំក៏ខ្ពស់ជាងប្រជាពលរដ្ឋរស់នៅតាមតំបន់ជនបទថែមទៀតផងដែរ។

តាមអង្កេតរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ១៩៩៩ បានបង្ហាញពីសហសម្ព័ន្ធទំនាក់ទំនងរវាងភាពដែលងាយរងគ្រោះ(ពិសេសសន្តិសុខស្បៀង) និងការសម្រេចបានការអប់រំ និងការចូលរៀន។ ឧទាហរណ៍ៈ ប្រហែលជា៥៥០ឃុំ ដែលងាយរងគ្រោះអត្រា អក្ខរកម្មសម្រាប់កុមារអាយុពី១០-១៤ឆ្នាំមានប្រហែលជា៦៣% ប្រៀបធៀបទៅនឹងអត្រាអក្ខរកម្មទូទាំងប្រទេសជាមធ្យម៦៣% សមាមាត្រប្រជាជនដែលរស់នៅឃុំដែលងាយរងគ្រោះមិនបានទៅរៀននោះមានចំនួន៥០% ប្រៀបធៀបទៅនឹងចំនួនប្រជាពលរដ្ឋទូទាំងប្រទេស ដែលជាមធ្យមត្រឹមតែ៤៥%ប៉ុណ្ណោះ។ តួលេខនេះបានបង្ហាញថាកម្មវិធីផ្តល់ស្បៀងសម្រាប់សាលារៀន ជាពិសេសសម្រាប់ថ្នាក់ខ្ពស់ៗនៅបឋមសិក្សា និងទៅអនុវិទ្យាល័យ អាចមានផលប្រយោជន៍ជាវិជ្ជមាន សម្រាប់ធ្វើឱ្យសិស្សចូលសិក្សាកាន់តែច្រើន និងរក្សាទុកសិស្សានុសិស្ស ដែលមកពីគ្រួសារក្រីក្រឱ្យបានគង់វង្ស[27]។

### ក- <u>ឈប់រៀនដើម្បីជួយរកប្រាក់ចំណូលគ្រួសារ</u>

**ក្រាបទី៣**




[26] ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា២០០៣-២០១៥

[27] ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ២០០៣-២០១៥

តាមក្រាបបង្ហាញថាពួកគេ៥៦,៧% និង២៣,៣% បានឯកភាព និងឯកភាពណាស់ថាការបោះបង់ការសិក្សារបស់ពួកគេគឺ បណ្តាលមកពីពួកគេចេញទៅធ្វើការងារដើម្បីរកប្រាក់ចំណូលសម្រាប់គ្រួសារហើយមានតែ២០%ដែលមិនឯកភាពលើមូលហេតុនេះ។

សិស្សអាយុ១៥ឆ្នាំ ជាកូនទី២ ក្នុងគ្រួសារកសិករ ដែលមានបងប្អូន៥ នាក់រស់នៅក្នុងភូមិក្រសាំងក ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលបានបោះបង់ការសិក្សានៅថ្នាក់ទី៦បានរៀបរាប់ប្រាប់ថាៈ

*"ខ្ញុំចង់រៀនឱ្យបានចប់សាលាបឋមសិក្សារួចបន្តចូលរៀននៅអនុវិទ្យាល័យផងដែរ ប៉ុន្តែក្នុងគ្រួសារក្រ ខ្ញុំជាកូនបងទី២ ដូច្នេះខ្ញុំត្រូវរកការងារធ្វើដើម្បីរកប្រាក់ខ្លះមកជួយផ្គត់ផ្គង់ក្រុមគ្រួសារ ព្រោះឪពុកម្តាយខ្ញុំក្រីក្រ "។*

<u>ប្រភពសម្ភាស</u> ១៨ កក្កដា ២០១៩

ដោយស្ថានភាពសេដ្ឋកិច្ច និងជីវភាពគ្រួសារក្រីក្រ បានបង្ខំកុមារ និងយុវជនមួយចំនួនចេញទៅធ្វើការនៅឆ្ងាយផ្ទះ ដើម្បីរកប្រាក់កម្រៃផ្គត់ផ្គង់ជីវភាពគ្រួសារ។ ការងារសម្រាប់កុមារ និងយុវជន មិនមែនជារឿងថ្មីសម្រាប់ប្រទេសកម្ពុជាទេ[28]។ ការងារដែលកុមារ និងយុវជនធ្វើនៅពេលបច្ចុប្បន្នមានដូចជា ការងារសំណង់ ស៊ីឈ្នួលច្រូតកាត់ ការងារកាត់ដេរ លីសែងអីវ៉ាន់ ជាអ្នកបម្រើនៅតាមផ្ទះ តាមហាងការហ្វេ...។

ក្មួយស្រីអាយុ១៦ឆ្នាំ មានបងប្អូន៤នាក់ ជាកូនច្បង ដែលបានបោះបង់ការសិក្សានៅពេលរៀនចប់ថ្នាក់ទី៦បន្ទាប់ពីនាងបានប្រឡងជាប់ នឹងត្រូវចូលរៀនអនុវិទ្យាល័យ។ នាងមានទីលំនៅ ភូមិត្នោតជុំ ឃុំកងមាស ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានប្រាប់ថាៈ

*" ជីវភាពគ្រួសារខ្ញុំមានការខ្វះខាតជាខ្លាំង ខ្ញុំជាកូនច្បងក្នុងគ្រួសារបន្ទាប់ពីខ្ញុំរៀនចប់ថ្នាក់ទី៦ មានអ្នកភូមិ អ្នកស្រុកមួយចំនួន ដែលពួកគេបានទៅធ្វើការជាកម្មករកាត់ដេរនៅភ្នំពេញបបួលខ្ញុំឱ្យទៅធ្វើការជាមួយគេ ពេលនោះខ្ញុំ និងឪពុកម្តាយក៏បានសម្រេចចិត្តឱ្យខ្ញុំឈប់រៀនតាំងពីពេលនោះមក "នាងបានបន្តទៀតថាៈ ខ្ញុំចង់ចូលរៀនវិញណាស់ហើយខ្ញុំចង់រៀនឱ្យបានខ្ពស់ដូចគេដូចឯងដែរតែបំណងខ្ញុំមិនអាចទៅរួចទេនៅពេលនេះ"។*

<u>ប្រភពសម្ភាស</u> ១៣ កក្កដា ២០១៩

---
[28] WVI-Cambodia, 2001, Child Work and ChildLabour

### ខ -ឈប់រៀនដើម្បីជួយធ្វើការងារផ្ទះ ការងារគ្មានប្រាក់ចំណូល

យើងដឹងហើយថា ក្នុងគ្រួសារនីមួយៗតែងតែមានកិច្ចការជាច្រើនដែល កុមារ និង យុវជនត្រូវតែបំពេញជារៀងរាល់ថ្ងៃ។ ប៉ុន្តែសម្រាប់គ្រួសារក្រីក្រ កិច្ចការទាំងនេះច្រើនណាស់ ដែលធ្វើឱ្យពួកគេតែងឃ្លាតឆ្ងាយពីការសិក្សា ពិសេសកុមារនៅតាមជនបទដែលពួកគេធ្វើការងារដោយគ្មានប្រាក់ចំណូលដូចជា មើលឃ្វាលគោក្របី ជួយដកស្ទូងច្រូតកាត់ ដែលជាហេតុធ្វើឱ្យពួកគេមករៀនមិនបានទៀងទាត់ អវត្តមានច្រើនយូរៗទៅពួកគេក៏សម្រេចចិត្តបោះបង់ការសិក្សាចោល។ តាមការសម្ភាសបានបង្ហាញឱ្យឃើញថា ៥៦,៦៧% ឆ្លើយថាឯកភាពណាស់២៦,៦៧% ឆ្លើយថាឯកភាព ១៦,៦៧ %ឆ្លើយថាមិនឯកភាព។ នេះបង្ហាញថាការងារផ្ទះក៏ជាមូលហេតុសំខាន់មួយដែលបណ្តាលឱ្យសិស្សបោះបង់ចោលការសិក្សាផងដែរ(ក្រាបទី៤)។

ប្រទេសកម្ពុជា កសិកម្មនៅតែជាវិស័យមួយដែលលេចធ្លោជាងគេ(វិស័យអាទិភាព) ហើយបានស្រូបយកកម្លាំងពលកម្មច្រើនជាង៨០%ទៅទៀត។ នៅតាមជនបទកម្លាំងពលកម្ម៨៥%ជាកសិករ ឬជាសមាជិកគ្រួសារដែលមិនទទួលបានកម្រៃ។ នៅតាមទីក្រុងមានកម្លាំងពលកម្មប្រមាណជាពីរភាគបី ធ្វើការផ្តល់សេវាកម្ម ឬវិស័យកម្មន្តសាលកម្មខ្នាតតូច ដោយសារតែការវិនិយោគបរទេសក្នុងស្រុកបានរីកចម្រើននៅចុងសវត្សទី២០ និងដើមសតវត្សទី២១នោះមក។ ផ្ទុយទៅវិញ កម្មករដែលមកពីជនបទមានប្រមាណ១៥%ប៉ុណ្ណោះ ធ្វើការក្នុងវិស័យផ្តល់សេវា ជាពិសេសសមាជិកនិយោជិករាជរដ្ឋាភិបាល។ សម្ពាធប្រជាសាស្ត្រ បានពង្រីកសេចក្តីត្រូវការបន្ទាន់សម្រាប់ការបង្កើតការងារ។ មានការព្យាករណ៍ថា កម្លាំងពលកម្មនឹងកើនឡើងប្រមាណជា ២០០.០០០នាក់ក្នុងមួយឆ្នាំៗមកត្រឹមឆ្នាំ២០១០។ ការកើនឡើងនៃទំហំ កម្លាំងពលកម្ម ផ្នែកសិកម្ម បានបណ្តាល ឱ្យ មានការធ្លាក់ចុះជាទូទៅក្នុងផលិតកម្មកសិកម្ម រយៈពេលប៉ុន្មានឆ្នាំថ្មី[29]។

[29] ផែនការជាតិអប់រំសម្រាប់សម្រាប់ការអប់រំទាំងអស់គ្នា ២០០៣-២០១៥ ទំព័រ ១៥

**ក្រាបទី៤**




ក្មួយស្រី អាយុ១៤ឆ្នាំ ធ្លាប់រៀនថ្នាក់ទី៦ នៅសាលាបឋមសិក្សាសានគរ នាដើមឆ្នាំសិក្សា ២០១៨-២០១៩ ជាកូនទី១ ក្នុងចំណោមបងប្អូន៣នាក់ ស្រី២នាក់។ សព្វថ្ងៃនាងរស់នៅភូមិ សំពៅមាស ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានរៀបរាប់ថា៖

*“ពេលខ្លះខ្ញុំមិនអាចទៅសាលារៀនបានទេដោយសារខ្ញុំធ្វើការងារផ្សេងមិនទាន់អស់សព្វគ្រប់ ដូចជាជួយដងទឹក បោសផ្ទះ បោកគក់សម្លៀកបំពាក់ លាងចានឆ្នាំង ចងក្របី...។បើរដូវដកស្ទូង និងច្រូតកាត់វិញ ខ្ញុំជួយធ្វើការងារនេះដោយមមារញឹកបំផុតព្រោះខ្ញុំជាកូនច្បង។ នៅឆ្នាំសិក្សា ២០១៨-២០១៩ ខ្ញុំឈប់អត់ច្បាប់ មានអវត្តមានច្រើន ខ្ញុំរៀនមិនចេះ ខ្លួនកាន់តែធំ ខ្មាសមិត្តភក្តិ លោកគ្រូអ្នកគ្រូខ្ញុំក៏សម្រេចចិត្តឈប់រៀន។”*

ប្រភពសម្ភាស ១៤ កក្កដា ២០១៩

**គ-តម្លៃការសិក្សាខ្ពស់**(គ្រួសារគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ការរៀនសូត្រ)

**ក្រាបទី៥**




តាមក្រាបង្ហាញថា៦៣,៣៣% បានឆ្លើយថាឯកភាពណាស់ និងឯកភាព ២៣,៣៣% ថាការបោះបង់ការសិក្សាគឺបណ្តាលមកពីគ្រួសារគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ការចំណាយលើការហូបចុកប្រចាំថ្ងៃ ទិញសម្លៀកបំពាក់ ទិញសម្ភារៈសិក្សា រៀនគួរក្រៅម៉ោង និងការបង់ប្រាក់ក្រៅផ្លូវការផ្សេងៗទៀត។

ការផ្តល់ហិរញ្ញវត្ថុទូទៅសម្រាប់ប្រព័ន្ធអប់រំ នៅតែពឹងពាក់យ៉ាងខ្លាំងលើវិភាគទានផ្ទាល់ និងមិនផ្ទាល់របស់ប្រជាពលរដ្ឋសម្រាប់អប់រំ។ ការអង្កេតផ្សេងៗជាច្រើនដែលប៉ាន់ស្មានលើការចំណាយនេះ ក៏ដូចជារបាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមបានបង្ហាញថាសិស្សម្នាក់ៗបង់ថ្លៃសាលាប្រចាំខែក្រៅផ្លូវការជាមធ្យម ៣៥០០រៀលនៅសាលាបឋមសិក្សា ៨០០០រៀលនៅអនុវិទ្យាល័យ និង១២០០០រៀលនៅវិទ្យាល័យ។ តម្លៃនេះមិនបានរាប់បញ្ចូលការចំណាយផ្សេងៗ ដូចជាការហូបចុកប្រចាំថ្ងៃ សម្លៀកបំពាក់ សម្ភារៈសិក្សានោះទេ[30]។

ទោះបីយ៉ាណាក៏ដោយ ក៏ការផ្តល់ហិរញ្ញវត្ថុផ្ទាល់ខ្លួនជាច្រើន ដោយមិនបានធ្វើនិយ័តកម្មសម្រាប់ការអប់រំបានបណ្តាលឱ្យមានអន្ទាក់ភាពក្រីក្រ និងការអប់រំ។ ឧទាហរណ៍: តួលេខសិស្សក្រីក្រនៅបឋមសិក្សា មានច្រើនជាងសិស្សមធ្យមសិក្សា ឬសិស្សឧត្តមសិក្សា។ នេះជាការពិតនៅកម្ពុជាសិស្សក្រីក្រ២០%រៀននៅបឋមសិក្សាមានត្រឹមតែ២% ប៉ុណ្ណោះដែលមានប្រភពចេញពីអ្នកមាន ពី២០%នៃចំនួនប្រជាពលរដ្ឋដែលក្រីក្របំផុតបានរៀននៅមធ្យមសិក្សា។ ផ្ទុយទៅវិញ សិស្សនៅមធ្យមសិក្សាទូទាំង

[30] ផែនការអប់រំសម្រាប់ទាំងអស់គ្នា២០០៣ទំព័រ ២០១៥- ១៥

ប្រទេសចំនួន៦១% មានប្រភពមកពីអ្នកក្រីក្រ២០%នៃចំនួនប្រជាពលរដ្ឋអ្នកមានបំផុត។ តួលេខសិស្សក្រីក្រនៅឧត្តមសិក្សាមានចំនួនតិចតួច ចំណែកឯតួលេខប្រជាពលរដ្ឋអ្នកមានបំផុតដែលមាន២០% នោះមានដល់ទៅ ៥៧% រៀននៅឧត្តមសិក្សា។

ទោះបី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់ជំពូកទី៦ មាត្រាទី៦៨ បានចែងថា៖ រដ្ឋផ្តល់ការអប់រំផ្នែកបឋមសិក្សា និងមធ្យមសិក្សាសាធារណៈសម្រាប់ប្រជាជនគ្រប់រូបដោយឥតបង់ថ្លៃយ៉ាងណាក៏ដោយ ក៏តម្លៃសិក្សាដែលសិស្ស និងមាតាបិតាសិស្សត្រូវចំណាយសម្រាប់ការសិក្សានៅតែមានកម្រិតខ្ពស់ បើប្រៀបទៅនឹងចំណូលគ្រួសារ។ មាតាបិតា និងសហគមន៍ត្រូវចំណាយប្រមាណ៧៥%នៃចំណូលសម្រាប់ការសិក្សា[31]។ការចំណាយសម្រាប់ការសិក្សាមានពីររបៀប ចំណាយដោយផ្ទាល់ និងដោយមិនផ្ទាល់ ឬ(ចំណាយផ្លូវការ និងចំណាយមិនផ្លូវការ)។

សំណាកសិស្ស ភេទប្រុស អាយុ ១៤ ឆ្នាំ ជាកូនទី៣ក្នុងគ្រួសារ ដែលមានបងប្អូន ៧នាក់ គេបានបោះបង់ការសិក្សានៅថ្នាក់ទី៥ នាឆ្នាំសិក្សា ២១០៧-២០១៨ សព្វថ្ងៃគេរស់នៅជាមួយមាតាបិតានៅឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំបានរៀបរាប់ថា៖

> *"គ្រួសារខ្ញុំជាគ្រួសារកសិករក្រីក្រ ជីវភាពរស់នៅពឹងផ្អែកលើការធ្វើស្រែ ចម្ការ ប៉ុន្មានឆ្នាំនេះទិន្នផលស្រូវត្រូវធ្លាក់ចុះ តម្លៃស្រូវក៏ទាប ។ ដោយក្នុងគ្រួសារមានសមាជិកក្នុងបន្ទុកច្រើន ការចំណាយសម្រាប់ការសិក្សាមិនគ្រប់គ្រាន់តាមតម្រូវការ ដូច្នេះខ្ញុំបានសម្រេចចិត្តឈប់រៀន ដើម្បីកាត់បន្ថយការចំណាយក្នុងគ្រួសារ។"*

ប្រភពសម្ភាស ១៦ កក្កដា ២០១៩

### ៤.១.២ បញ្ហាអាយុ និងភេទ

កត្តាផ្សេងទៀតដែលមាននៅក្នុងអន្ទាក់ភាពក្រីក្រ នៃការអប់រំ គឺជាសេចក្តីត្រូវការសម្រាប់កុមារគ្រប់វ័យសិក្សាដែលជារឿយៗ ក្មេងស្រីត្រូវចូលរួមចំណែកក្នុងការងារគ្រួសារ និងការរកប្រាក់ចំណូលគ្រួសារ។ ឧទាហរណ៍:តាមការអង្កេតសេដ្ឋកិច្ចសង្គមកម្ពុជានៅឆ្នាំ១៩៩៩ បានប៉ាន់ប្រមាណថាកុមារគ្រប់វ័យសិក្សា១,៦លាននាក់ មិនបាន

[31] M. Bray,1999

ចូលរៀនពេញម៉ោងឡើយ ហើយ២៥% នៃកុមារគ្រប់វ័យសិក្សាទាំងនោះបានទទួលខុសត្រូវក្នុងការរកប្រាក់ចំណូលសម្រាប់គ្រួសារដែលជាកត្តាចម្បង។ ផ្ទុយទៅវិញមានតែ៨% ប៉ុណ្ណោះ ខ្វះខាតការផ្តត់ផ្គង់ផ្នែកអប់រំសមស្របដែលជាឧបសគ្គចម្បងសម្រាប់ពួកគេក្នុងការទទួលឱកាសរៀនសូត្រ។

ក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ការរើសអើងភេទត្រូវបានលុបបំបាត់ស្ទើរទាំងស្រុងក្នុងការរៀនសូត្រ និងក្នុងការងារផ្សេងៗ ទាំងការងារឯកជន ទាំងការងាររាជការផងដែរ។ កម្ពុជាមានទស្សនៈថា៖ ការអប់រំមានសារៈសំខាន់ណាស់ ចំពោះមនុស្សម្នាក់ៗ ចំពោះគ្រួសារ ចំពោះមាតុភូមិ និងដើម្បីអភិវឌ្ឍប្រទេសកម្ពុជា[32]។ ជនកម្ពុជាគ្រប់រូបគេមានមោទនភាពណាស់នៅពេលដែលកូន បងប្អូន ឬមិត្តភក្តិដែលរស់នៅក្នុងភូមិផងរបងជាមួយមានឱកាសសិក្សាបានខ្ពស់ និងមានដំណែងខ្ពស់ក្នុងរដ្ឋាភិបាល ឬក្នុងសង្គម។

ទោះបីទាំងអស់គ្នាមានទស្សនៈថា៖ ការសិក្សាមានសារៈសំខាន់សម្រាប់មនុស្ស ម្នាក់ៗ មិនថាប្រុស ស្រី ក្មេង ចាស់ ឬជនពិការក៏ដោយ ក៏ពិនិត្យជារួមអត្រាបោះបង់ការសិក្សារៀននៅបឋមសិក្សារវាង សិស្សប្រុស និងសិស្សស្រី នៅតែមានគម្លាតពីគ្នាដែល។

**តារាងទី៧** អត្រាបោះបង់ការសិក្សាកុមារា និងកុមារី នៅបឋមសិក្សា

| កម្រិតបឋមសិក្សា | ទូទាំងខេត្ត | កុមារី | គម្លាតយេនឌ័រ |
|---|---|---|---|
| ២០១៧-២០១៧ | ៤,៨% | ៤,២% | ៤,៦% |
| ២០១៧-២០១៨ | ៥,៣% | ៤,១% | ៣,២% |

ក្នុងគ្រួសារមួយ កិច្ចការជាច្រើនជាបន្ទុករបស់កូនស្រី ច្រើនជាងកូនប្រុស ដូចជាការថែទាំប្អូន ធ្វើម្ហូបអាហារ បោកគក់សម្លៀកបំពាក់ និងកិច្ចការជាច្រើនទៀតដែលកូនស្រីត្រូវតែបំពេញ ដែលជាហេតុធ្វើឱ្យក្មេងស្រីមានការបោះការសិក្សាច្រើនជាងក្មេងប្រុស។

[32] Edward B. Fiske, 1995

តាមការស្រាវជ្រាវប្រតិបត្តិអប់រំឆ្នាំ២០០៤ បានបង្ហាញថា កុមារាបោះបង់ការសិក្សាតែ៨% ចំណែកឯកុមារីបោះបង់ការសិក្សារហូតដល់២០% ឯណោះ ។

សិស្ស ស្រី អាយុ១៦ឆ្នាំ ជាកូនច្បង ក្នុងគ្រួសារដែលមានបងប្អូន៣នាក់។ សព្វថ្ងៃនាងរស់នៅជាមួយម្ដាយ នៅភូមិត្នោតជុំ ឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ នាងធ្លាប់បានរៀនថ្នាក់ទី៦ នៃសាលាបឋមសិក្សាត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានបោះបង់ការសិក្សាក្នុងឆ្នាំសិក្សា ២០១៧-២០១៨ ដោយបានរៀបរាប់ថា៖

*"មិត្តភក្តិទាំងអស់នៅក្នុងភូមិជាមួយគ្នា ពួកគេមានអាយុតិចជាងខ្ញុំ គេក៏បានរៀនបន្តទៀត ចំណែកខ្ញុំមានអាយុច្រើនទើបម្ដាយខ្ញុំបង្ខំឱ្យខ្ញុំឈប់រៀន ដើម្បីជួយធ្វើការងារផ្ទះ ជួយលក់ដូរអីវ៉ាន់តិចតួចនៅផ្ទះ"* ។

<u>ប្រភពសម្ភាស:</u> ១៨ កក្កដា ២០១៩

សិស្សមួយចំនួនបោះបង់ការសិក្សាដោយសារពួកគេមានអាយុច្រើន ពិសេសសិស្សស្រីតាមជនបទ។ ក្នុងគ្រួសារក្រីក្រការចូលរៀននៅបឋមសិក្សា(នៅថ្នាក់ទី១) មានការយឺតយ៉ាវខ្លះមានអាយុ ៧ ឬ៨ ឬ៩ ឆ្នាំទើបចូលរៀនថ្នាក់ទី១ ហើយខ្លះទៀតត្រួតថ្នាក់ញឹកញាប់ជាហេតុធ្វើឱ្យពួកគេចូលរៀននៅថ្នាក់ទី៥ ខ្លះមានអាយុច្រើនខ្លះអាយុ១៥ ឬ១៦ឆ្នាំរៀនថ្នាក់ទី៦។

សិស្សប្រុស អាយុ១៦ឆ្នាំ បោះបង់ការសិក្សានៅថ្នាក់ទី៦ ក្នុងឆ្នាំសិក្សា២០១៧-២០១៨ ក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានរៀបរាប់ថា៖

*"ខ្ញុំចូលរៀនថ្នាក់ទី៦ ក្នុងអាយុ១៥ឆ្នាំ ជាមួយសិស្សដទៃទៀតដែលមានអាយុទើបតែ១១ឬ១២ឆ្នាំ ខ្ញុំមានការខ្មាសអៀនគេខ្លះៗដែរ តែខំចូលរៀនរហូតដល់ថ្នាក់ទី៦ទើបសម្រេចចិត្តឈប់រៀនដោយខ្លួនឯង"* ។

<u>ប្រភពសម្ភាស</u> ១៨ កក្កដា ២០១៩ ។

### ៤.១.៣ កត្តាសាលារៀន និងសង្គម

#### ក- <u>បរិស្ថានសាលារៀន និងសម្ភារៈសិក្សា</u>

សាលារៀនត្រូវបានបង្កើតឡើងជាច្រើននៅទូទាំងប្រទេសកម្ពុជា ទាំងបឋមសិក្សាទាំងមធ្យមសិក្សា តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលចង់ឱ្យសាលារៀន

ដល់ជិតលំនៅដ្ឋានរបស់សិស្ស។ ប៉ុន្តែ បញ្ហាដែលលំបាកគឺ សាលារៀនមួយចំនួន គ្មានអគារសិក្សាគ្រប់គ្រាន់ គ្មានទីចាត់ការ គ្មានបណ្ណាល័យ គ្មានបង្គន់អនាម័យសមស្រប

គ្មានអណ្តូងទឹកប្រើប្រាស់ហើយទីធ្លាសាលាក៏មិនទាន់ស្អាត ដូចជា ដីក្រឡុក ដីលិចទឹក គ្មានរបង គ្មានសួនច្បារ...ដែលមិនមែនជាទីមនោរម្យល់សិក្សានុសិស្ស។ ចំណែកសម្ភារៈសិក្សា ក៏នៅខ្វះដូចជា ខ្វះសៀវភៅសិក្សាគោល ខ្វះសម្ភារៈឧបទេស ខ្វះសម្ភារៈពិសោធ ខ្វះតុ កៅអី។ល។ កត្តាទាំងអស់នេះក៏ជាមូលហេតុមួយនាំឱ្យសិស្សធុញទ្រាន់ក្នុងការសិក្សាយូរៗទៅក៏សម្រេចចិត្តបោះបង់ការសិក្សាដែរ។

ឧទាហរណ៍ បើសាលារៀនមួយខ្វះអគារសិក្សា សាលារៀនត្រូវរៀបកាលវិភាគសិក្សាច្រើនវេន(២ ឬ៣វេនក្នុង១ថ្ងៃ) នាំឱ្យសិស្សខ្លះអវត្តមាន បើសិនជាពួកគេត្រូវរៀននៅពេលថ្ងៃ(ម៉ោង១២ ឬម៉ោង១)។ ម្យ៉ាងទៀត បើសាលារៀនគ្មានបណ្ណាល័យ សាលារៀននោះក៏ពុំសូវមានសៀវភៅអានដែរ សាលារៀនខ្វះសៀវភៅ នាំឱ្យសិស្សខ្លះមិនចូលចិត្តអានធ្វើឱ្យពួកគេរៀនខ្សោយយូរៗទៅពួកគេក៏សម្រេចចិត្តបោះបង់ការសិក្សាចោល។

**ខ-<u>សាលារៀននៅឆ្ងាយពីផ្ទះសិស្ស និងផ្ទះគ្រូ</u>**

ទោះបីជាគោលនយោបាយរាជរដ្ឋាភិបាល ឱ្យសាលារៀនទៅដល់ជិតលំនៅដ្ឋានរបស់សិស្សយ៉ាងណាក៏ដោយ ក៏លទ្ធភាពទាំងនេះនៅមានកម្រិតនៅឡើយ។ ជាក់ស្តែងសិស្សមួយចំនួននៅតែផ្ទះឆ្ងាយពីសាលារៀន។ សិស្សខ្លះត្រូវធ្វើដំណើររហូតដល់ទៅ ៣ ឬ ៥គីឡូម៉ែត្រឆ្លងកាត់ស្ទឹងឬព្រៃល្បោះកំណាត់ផ្លូវខ្លះមានការខូចខាតពិបាកធ្វើដំណើរ។ សិស្សខ្លះរអិលដួលប្រឡាក់សម្លៀកបំពាក់ពេលទៅសាលារៀន ឬពេលត្រឡប់មកពីសាលារៀនវិញ។

សិស្ស ភេទស្រី អាយុ១៥ឆ្នាំ បោះបង់ការសិក្សានៅពេលត្រូវចូលរៀននៅថ្នាក់អនុវិទ្យាល័យ មានទីលំនៅភូមិដំរីស្លាប់ ឃុំដំរីស្លាប់ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ការធ្វើដំណើរមករៀនតាមបណ្តោយផ្លូវលំដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រ ដោយជិះកង់ ហើយចំណាយពេលពី១៥នាទីទៅ២០នាទីក្នុងមួយថ្ងៃ ដើម្បីធ្វើដំណើរពីផ្ទះទៅសាលារៀន នឹងពីសាលារៀនមកផ្ទះ។ នាងរៀបរាប់ថា៖

*"ពេលខ្ញុំទៅរៀន ខ្ញុំត្រូវធ្វើដំណើរយ៉ាងយូរចួនកាល១៥នាទី ចួនកាលកន្លះម៉ោង តាមផ្លូវលំបាកពិសេសនៅពេលមានភ្លៀងរដូវវស្សា។ ការធ្វើដំណើររបស់ខ្ញុំ*

*ដោយកង់ ឆ្លងកាត់ប្រឡាយទើបមកដល់សាលារៀន។ ពេលខ្លះកង់ខូចតាមផ្លូវត្រូវទុកចោល ហើយសុំគេជិះជាមួយ។ ជាទូទៅ ការមករៀនរបស់ខ្ញុំមានការយឺតយ៉ាវហើយអវត្តមាន។ នៅចុងឆ្នាំគ្រូឱ្យរូបខ្ញុំប្រឡងឡើងថ្នាក់ជារៀងរាល់ឆ្នាំ។*

*ដោយការលំបាកពេកខ្ញុំ និងមិត្តភក្តិខ្ញុំមួយចំនួនក៏សម្រេចចិត្តបោះបង់ការសិក្សាដើមឆ្នាំសិក្សា ២០១៧-២០១៨" ។*

<u>ប្រភពសម្ភាស</u> ១៥ កក្កដា ២០០១៩ ។

ចំណែក លោកគ្រូ អ្នកគ្រូមួយចំនួនមានផ្ទះឆ្ងាយពីសាលារៀនខ្លះត្រូវធ្វើដំណើរក្នុងចម្ងាយផ្លូវ២០គីឡូម៉ែត្រ ក្នុងពេលវេលាពី២០ទៅ ៣៥នាទី ដោយម៉ូតូ។ ជាញឹកញាប់ លោកគ្រូ អ្នកគ្រូដែលមានផ្ទះឆ្ងាយ តែងតែមកបង្រៀនយឺតជានិច្ច បង្រៀនមិនចប់កម្មវិធី ខ្លះមិនបានធ្វើកិច្ចតែងការបង្រៀន ហើយសិស្សមួយចំនួនមានការមិនពេញចិត្ត និងមានការថ្នាំងថ្នាក់ចិត្តជាមួយគ្រូ ព្រោះពួកគេបានធ្វើដំណើរពីឆ្ងាយដើម្បីមករៀន តែមិនបានរៀនទៅវិញ យូរៗទៅធ្វើឱ្យពួកគេចូលរៀនមិនបានទៀងទាត់នេះក៏ជាមូលហេតុមួយនាំឱ្យសិស្សបោះបង់ការសិក្សា នឹងគុណភាពអប់រំមានការធ្លាក់ចុះដែរ។

អ្នកគ្រូម្នាក់ ជាគ្រូបង្រៀននៅបឋមសិក្សាត្នោតជុំបានមានប្រសាសន៍ថា៖

*"ផ្ទះខ្ញុំនៅឆ្ងាយពីសាលារៀនប្រមាណប្រហែល១៥គីឡូម៉ែត្រ។ខ្ញុំត្រូវការចំណាយពេលប្រមាណជិត៣០នាទី ដើម្បីធ្វើដំណើរទៅសាលារៀន។ រៀងរាល់ព្រឹកខ្ញុំមិនសូវទៅទាន់ពេលវេលាបង្រៀនទេ ព្រោះនៅផ្ទះមានការងារច្រើនដែលត្រូវធ្វើ" ។*

<u>ប្រភពសម្ភាស</u> ២០ កក្កដា ២០១៩។

### គ -<u>ប្រាក់ខែគ្រូបង្រៀន</u>

យើងបានដឹងហើយថា សាលារៀនបានរីកដុះដាលច្រើន នៅប៉ុន្មានឆ្នាំក្រោយនេះរហូតដល់ជនបទចុងកាត់មាត់ញក។ តែបញ្ហាប្រឈមធំមួយគឺការខ្វះគ្រូបង្រៀនពិសេសសាលារៀននៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ នេះក៏ជាមូលហេតុមួយនាំឱ្យសិស្សបោះបង់ការសិក្សាដែរ។ ដោយកម្រងសាលាបឋមសិក្សាទាំងពីរ ជាទូទៅដែលលើកមកសិក្សានេះស្ថិតនៅជនបទ និងតំបន់ដាច់ស្រយាលបញ្ហាខ្វះគ្រូបង្រៀន ជាបញ្ហាប្រឈមធំមួយដូចគ្នាក្នុងពេលកន្លងមកក៏ដូចជាពេលបច្ចុប្បន្ន ព្រោះគ្រូភាគច្រើន

មិនចង់ទៅនៅទីជនបទ។ ការខ្វះគ្រូបង្រៀនធ្វើឱ្យសាលា កាត់បន្ថយម៉ោងសិក្សារបស់សិស្សមួយចំនួន ហើយគ្រូម្នាក់ៗ ត្រូវបង្រៀនដោយមានសិស្សច្រើន ឬច្រើនកម្រិតថ្នាក់ ធ្វើឱ្យការបង្រៀនមិនសូវបានល្អ សិស្សមិនសូវយល់មេរៀន យូរៗទៅសិស្សមួយចំនួនក៏

សម្រេចចិត្តបោះបង់ការសិក្សាចោល។

ម្យ៉ាងទៀតប្រាក់ខែគ្រូបង្រៀនមិនអាចផ្គត់ផ្គង់ជីវភាពគ្រួសារបានទេ។ ដោយជីវភាពគ្រួសារនៅមានកម្រិត ធ្វើឱ្យគ្រូបង្រៀនមួយចំនួនបោះបង់ការងារចោល ទៅរកការងារថ្មីធ្វើ និងមួយចំនួនទៀតឆ្លៀតរកស៊ីក្រៅថែមទៀតដូចជា រត់ម៉ូតូឌុប ធ្វើស្រែចម្ការ ចិញ្ចឹមសត្វ បង្រៀនគួរក្រៅម៉ោងដែលជាហេតុធ្វើឱ្យពួកគាត់មួយចំនួន ឃ្លាតឆ្ងាយពីការងារបង្រៀន និងការគ្រប់គ្រងសិស្ស។

ពេលសិស្សអវត្តមានច្រើន ពួកគាត់គ្មានពេលវេលា ទៅសាកសួរព័ត៌មានពីមាតាបិតា ឬអាណាព្យាបាលសិស្ស ឬអាជ្ញាធរមូលដ្ឋានឡើយ។ ការតាមដានការសិក្សា ឬកិច្ចការរបស់សិស្សក៏ពួកគាត់មិនបានធ្វើដិតដល់។ នេះក៏ជាមូលហេតុមួយធ្វើឱ្យសិស្សបោះបង់ការសិក្សាដែរ។

លោកគ្រូ ជានាយកសាលាបឋមសិក្សា និងជាប្រធានកម្រង មានប្រសាសន៍ថា៖

*"ប្រាក់ខែគ្រូបង្រៀនប្រមាណជាមួយលានរៀល។ រៀងរាល់ថ្ងៃគ្រូបង្រៀនបានចំណាយលើសាំងម៉ូតូ១លីត្រ គិតជាប្រាក់ប្រមាណ ៥០០០រៀល និងអាហារពេលព្រឹកប្រមាណ៨០០០រៀលទៀត ដូច្នេះក្នុងមួយខែត្រូវចំណាយជាង ៥០០០០០ម៉ឺនរៀល។ តើគាត់បានប្រាក់ពីណាដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារហេតុដូចនេះហើយគ្រូបង្រៀនត្រូវឆ្លៀតធ្វើការងារបន្ថែមដូចជាធ្វើស្រែចម្ការ រកត្រីចិញ្ចឹមសត្វ...។ នាំឱ្យការបង្រៀនមិនសូវបានល្អជាការពិត"។*

<u>ប្រភពសម្ភាស</u> ២១កក្កដា ២០១៩ ។

### ៤.១.៤ កត្តាសិស្សផ្ទាល់

តាមការសម្ភាសជាមួយសិស្សបោះបង់ ជាទូទៅពួកគេយល់ថា ការបោះបង់ការសិក្សាមិនទាក់ទងខ្លួនគេឡើយ។ តាមពិតសិស្សមួយចំនួន បានសម្រេចចិត្តបោះបង់ការសិក្សាដោយខ្លួងគេផ្ទាល់(ក្រាបទី១) ដោយមូលហេតុផ្សេងៗដូចជារៀនខ្សោយ ដើរលេងច្រើន មិនស្តាប់ដំបូន្មានលោកគ្រូ អ្នកគ្រូ មិនស្តាប់ដំបូន្មានមាតាបិតា សេពគប់ជាមួយ

មិត្តភក្តិមិនល្អ។ ទាំងនេះក៏ជាមូលហេតុធ្វើឱ្យសិស្សឃ្លាតឆ្ងាយពីសាលារៀន និងបោះបង់ការសិក្សា។

លោកគ្រូ នាយកសាលាបឋមសិក្សា បានមានប្រសាសន៍ថា៖

*"ការបោះបង់ការសិក្សារបស់សិស្សមួយចំនួន បណ្តាលមកពីពួកគេដើរលេងច្រើន ឬសេពគប់ភក្តិមិនល្អ។ កាលណាពួកគេដើរលេងច្រើន អវត្តមានពេលរៀនក៏ច្រើន នាំឱ្យពួកគេរៀនខ្សោយត្រូវប្រឡងឡើងថ្នាក់ ឬរៀនត្រួតថ្នាក់។ ពួកគេខ្មាសមិត្តភក្តិ ខ្មាសគ្រូបង្រៀន ក៏សម្រេចចិត្តបោះបង់ការសិក្សានៅឆ្នាំបន្ទាប់"* ។

<u>ប្រភពសម្ភាស</u> ១៩ កក្កដា ២០១៩។

## ៤.២ របកគំហើញពីក្រុមទសំណួររបស់ឳពុកម្តាយ

ពេលដែលកូនពួកគាត់ទៅរៀនឯសាលា ពួកគាត់គ្រប់គ្នាបានប្រាប់យើងថា៖ សុទ្ធតែធ្លាប់បានទទួលព័ត៌មានអំពីការសិក្សារបស់កូនតាមមធ្យោបាយផ្សេងៗពីគ្នា ក្នុងនោះ២៦នាក់បានប្រាប់ថាគាត់បានទទួលព័ត៌មាន តាមរយៈសៀវភៅទំនាក់ទំនងការសិក្សា ៣នាក់ តាមរយៈព្រឹត្តិបត្រពិន្ទុ និង១នាក់ទៀតបានប្រាប់ថា៖ តាមរយៈលិខិតជូនដំណឹង។ ពេលអ្នកស្រាវជ្រាវសួរថា៖ តើលោកគ្រូ អ្នកគ្រូ និងលោកនាយកសាលាធ្លាប់បានអញ្ជើញ លោក លោកស្រី ទៅសាកសួរព័ត៌មានដែរឬទេ ពេលដែលកូនលោកអ្នកកំពុងសិក្សា? មានតែ១៣,៣៣% ប៉ុណ្ណោះដែលឆ្លើយថាធ្លាប់(ក្រាបទី៦)។

**ក្រាបទី៦**



តាមក្រាបបង្ហាញថា ១៣,៣៣% ធ្លាប់បានទទួលការអញ្ជើញពីសាលារៀនដើម្បីសាកសួរព័ត៌មានអំពីការសិក្សារបស់កូន និងព័ត៌មានផ្សេងៗទៀត ចំណែក៨៦,៦៧ % មិនដែលធ្លាប់ទាល់តែសោះ។ នេះបញ្ជាក់ថាទំនាក់ទំនងរវាងមាតាបិតា និងសាលារៀន មិនសូវជាមានប៉ុន្មានទេ។ អ្នកស្រាវជ្រាវក៏បានសួរទៀតថា៖ តើលោកគ្រូ អ្នកគ្រូ និងនាយកសាលាបានអញ្ជើញលោកលោកស្រី ទៅសាកសួរព័ត៌មានដែរឬទេ ពេលដែលកូនលោកអ្នកបានបោះបង់ការសិក្សា? ចំនួន៩៣,៣៣% បានឆ្លើយថា៖ ពុំដែលបានទទួលការជួបពិភាក្សាអ្វីទាំងអស់ចាប់តាំងពីកូនគាត់ឈប់រៀន(ក្រាបទី៧)។

**ក្រាបទី៧**




តាមក្រាបទាំងពីរខាងលើបានបង្ហាញថា ទំនាក់ទំទងរវាងគ្រូបង្រៀន នាយកសាលា និងមាតាបិតា ឬអាណាព្យាបាលសិស្ស មិនសូវមានទាំងនៅពេលកូនពួកគាត់នៅសិក្សា ដែលចំនួន៩៣,៣៣% បានប្រាប់ថានាយកសាលា ព្រមទាំងគ្រូបង្រៀនមិនដែលអញ្ជើញពួកគាត់ទៅជួបពិភាក្សាអំពីការសិក្សា ក៏ដូចជាអំពីអវត្តមានរបស់កូនគាត់ឡើយ។ ចំណែក(៨៦,៦៧%) បានប្រាប់ថានៅពេលកូនពួកគាត់បោះបង់ការសិក្សា ក៏មិនដែលឃើញលោកគ្រូ អ្នកគ្រូ ឬលោកនាយកសាលាអញ្ជើញពួកគាត់ឱ្យទៅជួបដែរ។ នេះប្រហែលមកពីនាយកសាលា លោកគ្រូ អ្នកគ្រូ ព្រមទាំងមាតាបិតាសិស្សមានការរវល់ក្នុងការរកស៊ីចិញ្ចឹមជីវិតតែរៀងៗខ្លួន។

តាមលទ្ធផលសម្ភាស អាចបង្ហាញពីមូលហេតុសំខាន់ៗដែលបណ្តាលឱ្យកូនរបស់ពួកគាត់បោះបង់ការសិក្សាមានដូចខាងក្រោម៖

### ៤.២.១ កត្តាគ្រួសារ និងកត្តាសិស្សផ្ទាល់

**ក-ប្រាក់ចំណូលក្នុងគ្រួសារមិនគ្រប់គ្រាន់ក្នុងការចំណាយ**

តាមក្រាបទី៨ បានបង្ហាញថា ៧៣,៣៣% បានឯកភាព និងឯកភាពទាំងស្រុងថា មូលហេតុចម្បងដែលបណ្តាលឱ្យកូនរបស់ពួកគាត់បោះបង់ការសិក្សាមកពីប្រាក់ចំណូលប្រចាំថ្ងៃ និងប្រចាំឆ្នាំរបស់គ្រួសារមិនគ្រប់គ្រាន់ក្នុងការចំណាយ។

**ក្រាបទី៨**




លោកស្រីម្នាក់ អាយុ៥៦ឆ្នាំ នៅភូមិក្រសាំងក ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ លោកស្រីធ្លាប់រៀននៅបឋមសិក្សា។ គ្រួសារលោកស្រី ជាគ្រួសារក្រីក្រ មានកូន៧នាក់ ស្រី៤នាក់ ហើយសព្វថ្ងៃកូនគាត់នៅរៀនមានតែ៣នាក់ប៉ុណ្ណោះ។ គាត់បានរៀបរាប់ថា៖

*"គ្រួសារខ្ញុំគ្មានចំណូលអ្វី ក្រៅពីការលក់ស្រូវអង្ករនោះទេ ឯការចំណាយវិញច្រើន ប៉ុន្មានឆ្នាំផលស្រូវពុំសូវបានទេ។ ការលក់ស្រូវថោយនាំឱ្យខ្វះស្រូវហូបនៅរដូវវស្សា ដូច្នេះខ្ញុំត្រូវឱ្យកូនខ្ញុំឈប់រៀនខ្លះដើម្បីជួយរកម្ហូបអាហារត្រីសាច់ នៅ*

*តាមបឹងបួរ ហើយនិងចិញ្ចឹមសត្វខ្លះជាជំនួយ" ។*

ប្រភពសម្ភាស ១៨ កក្កដា ២០១៩

## ខ-គ្រួសារគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ការចំណាយលើការរៀនរបស់កូន

**ក្រាបទី៩**




តាមក្រាបទី៩បង្ហាញថា ៤៣,៣៣% បានឯកភាពណាស់ និងឯកភាព៣៦,៦៧% លើមូលហេតុខាងលើហើយ១៧,៦៧% មិនឯកភាពលើចំណុចនេះទេ។ ប្រហាក់ប្រហែលនឹងចម្លើយរបស់សិស្សដែរ ឪពុកម្តាយមួយចំនួនបានប្រាប់យើងថា ការសិក្សារបស់កូនត្រូវការចំណាយច្រើនដូចជា មធ្យោបាយធ្វើដំណើរ សម្លៀកបំពាក់ សៀវភៅសិក្សា ការរៀនគួរបន្ថែម ហូបចុកប្រចាំថ្ងៃ និងចំណាយផ្សេងៗទៀតតាមការចាំបាច់។ លោកស្រីម្នាក់ អាយុ៤៩ឆ្នាំ ស្ថិតនៅភូមិត្នោតជ្រុំ ឃុំកងមាស ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានត្អូញត្អែរថា៖

*"គ្រួសារខ្ញុំជាគ្រួសារក្រីក្រ សព្វថ្ងៃនេះការចំណាយសម្រាប់ការសិក្សាមានចំនួនច្រើន ដូច្នេះខ្ញុំក៏សម្រេចចិត្តឱ្យកូនបោះបង់ការសិក្សា ដើម្បីកាត់បន្ថយការចំណាយ និងដើម្បីជួយរកចំណូលគ្រួសារ" ។*

ប្រភពសម្ភាស ២១ កក្កដា ២០១៩

គ-ឱ្យកូនឈប់រៀនដើម្បី ឱ្យពួកគេជួយធ្វើការងារផ្ទះ

**ក្រាបទី១០**




តាមក្រាបខាងលើបានបង្ហាញថា៨៦,៦៧ %ពួកគាត់បានប្រាប់ថាការបោះបង់ការសិក្សារបស់កូនគាត់ គឺបណ្តាលមកពីជួយធ្វើការងារផ្ទះញឹកញាប់ ហើយ១៣,៣៣% បានឆ្លើយថា បញ្ហាខាងលើមិនមែនជាមូលហេតុចម្បងដែលធ្វើឱ្យកូនគាត់ឈប់រៀននោះទេ។ យើងដឹងហើយថាការងារច្រើនពិសេសនៅរដូវដកស្ទូង ច្រូតកាត់។ មាតាបិតាមួយចំនួនបានឃាត់កូនមិនឱ្យទៅរៀន ដើម្បីមានឱកាសឱ្យពួកគេជួយធ្វើការងារស្រែចម្ការ។ លោកជាអាណាព្យាបាលសិស្សម្នាក់ អាយុ៥៦ឆ្នាំ មាយកូន៥នាក់ បានប្រាប់ថា៖

*"ខ្ញុំសោកស្តាយណាស់ដែលសម្រេចចិត្តឱ្យកូនឈប់រៀន ប៉ុន្តែបើមិនឱ្យវាឈប់រៀនតើបាននរណា ធ្វើស្រែចម្ការទាំងរដូវប្រាំង ទាំងរដូវវស្សា ព្រោះកូន ៣នាក់រស់នៅបែកជាមួយប្រពន្ធកូនគាត់បាត់ទៅហើយ។ មិនត្រឹមតែប៉ុណ្ណោះទេយើងចិញ្ចឹមសត្វ ដាំបន្លែបន្ទាប់បន្សំផ្សេងៗ ថែមទៀត"* ។

ប្រភពសម្ភាស ២២ កក្កដា ២០១៩

មាតបិតាមួយចំនួន បានទទួលស្គាល់ថាការឈប់រៀនរបស់កូន គឺបណ្ដាលមកពីវាខ្ជិលរៀន និងមួយចំនួនប៉ោឡែ ឬសេពគប់មិត្តភក្តិមិនល្អ និងខ្លះរៀនខ្សោយផងដែរ។

**ឃ-កត្តាសិស្សផ្ទាល់:**

តាមក្រាបទី១បានបង្ហាញថា អ្នកដែលបានសម្រេចចិត្តបោះបង់ការសិក្សា ១៦,៦៧% ជាសិស្សផ្ទាល់។ មាតាបិតា ឬអាណាព្យាបាលមួយចំនួនមានជីវភាពសមល្មម ដែលអាចឱ្យកូនពួកគាត់រៀនចប់ថ្នាក់បឋមសិក្សា ហើយខ្លះអាចឱ្យរៀនបន្តទៅថ្នាក់អនុវិទ្យាល័យថែមទៀត។ មាតាបិតា ឬអាណាព្យាបាលមួយចំនួនទទួលស្គាល់ថាការបោះបង់ការសិក្សារបស់កូនមិនទាក់ទងនឹងជីវភាពគ្រួសារទេ ពួកវាបោះបង់ការសិក្សាពីព្រោះវាខ្ជិលរៀន ហើយសេពគប់មិត្តភក្តិមិនល្អ។

លោកជាអាណាព្យាបាលសិស្សមានអាយុ៥៣ឆ្នាំ មានកូន៣នាក់ ស្រី២នាក់ រស់នៅឃុំសាន់គរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានរៀបរាប់ថា៖

*"ខ្ញុំលក់ដូរ ប្រពន្ធខ្ញុំរកស៊ីលក់ដូរនៅផ្សារដែរ ខ្ញុំមានប្រាក់សមរម្យដែលអាចឱ្យកូនបន្តទៀតបាន ប៉ុន្តែគេគ្មានចិត្តចង់រៀនទេ គេចូលចិត្តដើរលេង សេពគប់មិត្តភក្តិមិនល្អ រួចសម្រេចចិត្តបោះបង់ការសិក្សាដោយខ្លួនឯង"*។

ប្រភពសម្ភាស ២០ កក្កដា ២០១៩

លោក គ្រូបង្រៀននៅសាលាបឋមសិក្សា បានមានប្រសាសន៍ថា៖

*" នៅសាលារៀនយើងខ្ញុំមានសិស្សបោះបង់ការសិក្សាមួយចំនួន បណ្ដាលមកពីពួកគេអវត្តមានច្រើននៅពេលរៀន ខ្លះទៀតមិនយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ខ្លះទៀតរៀនខ្សោយ "*។

ប្រភពសម្ភាស ២៣ កក្កដា ២០១៩

**៤.២.២ កត្តាសាលារៀន និងគ្រូបង្រៀន**

**ក- កត្តាសាលារៀន**

ជាការពិតណាស់សាលារៀនមួយចំនួន ខ្វះអគារសិក្សា បរិស្ថានសាលារៀនមិនល្អ ខ្វះបង្គន់អនាម័យ សម្ភារៈប្រើប្រាស់សម្រាប់បម្រើឱ្យការបង្រៀន និងរៀនមិនគ្រប់គ្រាន់។ ពេលយើងសាកសួរពីទិដ្ឋភាពរួមនៅសាលា គាត់ដូចជាមិនសូវដឹងច្បាស់ប៉ុន្មានឡើយ ពិសេសពួកគាត់ដែលរស់នៅឆ្ងាយពីសាលារៀន។ ប៉ុន្តែ ពួកគាត់ខ្លះគ្រាន់តែយល់ថា សុវត្ថិភាពតាមផ្លូវទៅសាលារៀនគឺជាបញ្ហាមិនគួរឱ្យព្រួយបារម្ភប៉ុន្មានទេ ព្រោះពួក

គេធំៗហើយ អាចមើលការខុសត្រូវលើខ្លួនបាន។ ចំណែកការខ្វះអគារសិក្សា បរិស្ថានសាលារៀនមិនល្អគាត់មិនដឹងឡើយ។ ដូច្នេះ ពួកគាត់មួយចំនួនសន្និដ្ឋានថាការបោះបង់ការសិក្សារបស់កូនគាត់ពុំសូវទាក់ទងនឹងសាលារៀនប៉ុន្មានទេ។ ប៉ុន្តែ ពួកគាត់មួយចំនួនយល់ឃើញថា ការបោះបង់ការសិក្សារបស់កូនគាត់មានពាក់ព័ន្ធនិងសាលារៀនខ្លះដែរ។

ប្រជាពលរដ្ឋម្នាក់ ភេទប្រុស អាយុ៥៩ឆ្នាំ រស់នៅភូមិប្រាសាទអណ្តែត ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំបានរៀបរាប់ថា៖

*"ការបោះបង់ការសិក្សារបស់សិស្សមួយចំនួន គឺបណ្តាលមកពីសាលារៀនមិនគ្រប់កម្រិតសិក្សា និងខ្វះថ្នាក់រៀន ដែលធ្វើឱ្យការរៀនសូត្រមានភាពរញ៉េរញ៉ៃ ក្មេងធុញទ្រាន់ មិនយកចិត្តទុកដាក់ក្នុងការរៀនសូត្រ។ ម៉្យាងទៀត មុខវិជ្ជាសំខាន់ៗខ្លះដូចជាភាសាខ្មែរ គណិតវិទ្យា ក្មេងរៀនមិនសូវចេះតាំងពីថ្នាក់ក្រោម ធ្វើឱ្យពួកគេធុញទ្រាន់នឹងការសិក្សា"។*

<u>ប្រភពសម្ភាស</u> ២១ កក្កដា ២០១៩ ។

**ខ-<u>កត្តាគ្រូបង្រៀន</u>**

ដូចការអង្កេតកម្រងសំណួរសិស្សដែរ កត្តាគ្រូបង្រៀនក៏ជាមូលហេតុមួយដែលធ្វើឱ្យសិស្សបោះបង់ការសិក្សាផងដែរ។ ការគ្រប់គ្រងរបស់លោកនាយមិនសូវបានល្អ ការងាររដ្ឋបាល ការងារបច្ចេកទេស និងការងារគ្រប់គ្រងថវិកា។ ចំណែកលោកគ្រូ អ្នកគ្រូមួយចំនួនមិនសូវយកចិត្តទុកដាក់ក្នុងការបង្រៀននៅក្នុងថ្នាក់ គាត់យកចិត្តទុកដាក់តែលើការបង្រៀនក្រៅម៉ោងតែប៉ុណ្ណោះ។ គ្រូមានការលម្អៀង ក្នុងការផ្តល់ពិន្ទុដល់សិស្ស

ខ្លះទៀតមានការប្រមាថដល់សិស្សដែលមិនសូវជិតដិតនឹងខ្លួន។

អ្នកស្រីអាណាព្យាបាលសិស្ស អាយុ៤០ឆ្នាំ រស់នៅក្នុងស្រុកកំពង់ស្វាយ បានមានប្រសាសន៍ថា៖

*"កូនរបស់ខ្ញុំរៀនខ្សោយ ហើយគ្រូមួយចំនួនតែងតែបណ្តុះបង្អាប់វាជាញឹកញាប់ ឱ្យវាខ្មាសមិត្តភក្តិ ក្រោយមកវាក៏សម្រេចចិត្តបោះបង់ការសិក្សាដោយខ្លួនវា"។*

<u>ប្រភពសម្ភាស</u> ២៣ កក្កដា ២០១៩

**៤.២.៣ កត្តាសង្គម**

នៅពេលអ្នកស្រាវជ្រាវជួបសម្ភាស ជាមួយគាត់ ពួកគាត់ជាច្រើនតែងតែរអ៊ូរទាំថា៖ ទោះបីជាគាត់រៀនបន្តទៅទៀតក៏គ្មានលទ្ធភាពរកការងារល្អធ្វើបានដែរ ព្រោះនៅស្រុកខ្មែរសព្វថ្ងៃការងារដែលមានប្រាក់កម្រៃច្រើនមានតិចតួចបំផុត។ ម្យ៉ាងទៀត គាត់យល់ឃើញថា ការបោះបង់ការសិក្សារបស់សិស្សនៅពេលបច្ចុប្បន្ន មួយផ្នែកបណ្តាលមកពីរដ្ឋាភិបាលសង់អគារសិក្សាមិនបានគ្រប់គ្រាន់ ការបណ្តុះបណ្តាលគ្រូមានចំនួនតិច ពិសេសការផ្តល់គ្រូឱ្យទៅដល់តំបន់ជនបទចុងកាត់មាត់ញក និងតំបន់ជួបការលំបាកនៅមានកម្រិត។

លោកស្រីម្នាក់ជាអាណាព្យាបាលសិស្ស អាយុ៥៣ឆ្នាំ រស់នៅស្រុកបារាយណ៍ គាត់ធ្លាប់បានរៀននៅបឋមសិក្សាបានរៀបរាប់ថា៖

*"កូនរបស់ខ្ញុំបានប្រាប់ខ្ញុំថា(កាលពីនៅរៀន)គ្រូដែលបង្រៀនជាគ្រូគ្មានក្របខ័ណ្ឌ (គ្រូកិច្ចសន្យា)ហើយការបង្រៀនរបស់គាត់មិនបានល្អទេ។ហេតុនេះហើយ សិស្សខ្លះក៏ចេះតែមករៀនឱ្យផុតពីផ្ទះទៅទាំងមិនចេះដឹងអ្វីទាំងអស់"។*

<u>ប្រភពសម្ភាស</u> ២៣ កក្កដា ២០១៩

## ៤ ៣.ការពិភាក្សា

របាយការណ៍ស្រាវជ្រាវនេះបានផ្តល់នូវគំហើញសំខាន់ៗ ដែលទាក់ទងទៅនឹងការបោះបង់ការសិក្សារបស់សិស្សនៅកម្រិតថ្នាក់បឋមសិក្សាដូចខាងក្រោម៖

**៤.៣.១ កត្តាគ្រួសារ**

***<u>ជីវភាពគ្រួសារក្រីក្រ</u>***

តាមលទ្ធផលស្រាវជ្រាវបានបង្ហាញថា មូលហេតុនៃការបោះបង់ការសិក្សាគឺបណ្តាលមកពីកត្តាជីវភាពគ្រួសារដែលមានឥទ្ធិពលជាងគេនៅក្នុងចំណោម មូលហេតុចម្បងទាំងឡាយ។ ដោយជីវភាពខ្វះខាតគេក៏សម្រេចចិត្តបោះបង់ការសិក្សាហើយស្វែងរកការងារធ្វើតាមទីក្រុង និងទីប្រជុំជននានា ដូចជាកម្មករកាត់ដេរ កម្មករសំណង់ លីសែង និងសេវាកម្មផ្សេងៗ ដើម្បីជួយរកប្រាក់ចំណូល ផ្គត់ផ្គង់ជីវភាពគ្រួសារ។ ចំណែកពួកគេមួយចំនួនទៀតឈប់រៀនដើម្បីជួយធ្វើការងារផ្ទះ ដូចជាមើលប្អូន ធ្វើស្រែចម្ការ។ មិនតែប៉ុណ្ណោះ ពួកគេខ្លះមានតួនាទីដ៏សំខាន់ក្នុងការងារស្រែចម្ការ ជំនួសមាតាបិតា

ដូចជាគេ ភ្ជួររាស់ ដកស្ទូង ច្រូតកាត់ ប្រមូលផលជាដើម។ ម្យ៉ាងទៀត សិស្សបោះបង់ការសិក្សាមួយចំនួន បណ្តាលមកពីគ្រួសារគេគ្មានប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ការរៀនសូត្រ ដូចជា ទិញសម្លៀកបំពាក់ ទិញសម្ភារៈសិក្សា ប្រាក់សម្រាប់ហូបចុក និងការចំណាយផ្សេងៗទៀត។

កត្តាធំបំផុត ដែលជះឥទ្ធិពលលើការអប់រំ គឺស្ថានភាពសេដ្ឋកិច្ចសង្គម និងសេដ្ឋកិច្ចគ្រួសារ។ ភាពក្រីក្រមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើតម្រូវការសិក្សា ការចុះឈ្មោះចូលរៀន និងភាពគង់វង្សរបស់សិស្ស[33]។ មូលហេតុធំមួយ ដែលធ្វើឱ្យសិស្សបោះបង់ការសិក្សានៅប្រទេសហ្វីលីពីនក្នុងទសវត្ស១៩៥០ គឺបណ្តាលមកពីសេដ្ឋកិច្ចគ្រួសារ[34]។ ជាងនេះទៅទៀត ប្រាក់ចំណូលគ្រួសារ នឹងធនធានដែលមាននៅផ្ទះរបស់សិស្សបោះបង់ការសិក្សាមានតិចតួចបំផុត។ ភាពក្រីក្ររបស់គ្រួសារបានប៉ះពាល់ដោយផ្ទាល់ទៅនឹងការសិក្សារបស់សិស្ស ដែលត្រូវតែធ្វើការដើម្បីរកកម្រៃដើម្បីផ្គត់ផ្គង់ជីវភាពរបស់ពួកគេ។ ហេតុផលនេះហើយជាការនាំឱ្យសិស្សកាន់តែឃ្លាតឆ្ងាយពីសាលារៀន។ របកគំហើញនេះបានបញ្ជាក់ថា ស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់សិស្សបោះបង់ គឺក្រីក្រហើយក៏ជាការប៉ះពាល់ដ៏អាក្រក់បំផុតដល់ការសិក្សារបស់សិស្សដែរ។ បើយើងប្រៀបធៀបរវាងសាលាបឋមសិក្សាគោលដៅទាំងពីរ ស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់សិស្សបោះការសិក្សា គឺមានលក្ខណៈស្រដៀងគ្នា។

ដូច្នេះ តាមលទ្ធផល ស្រាវជ្រាវនេះ និងការសិក្សាស្រាវជ្រាវពីមុន គឺមានលទ្ធផលប្រហាក់ប្រហែលគ្នា។

---

[33] D.Shapir, B.O, Tambashe.2001

[34] M,Brimer and Paul 1917

<u>ការសិក្សារបស់ឪពុកម្ដាយ</u>

តាមការសង្កេត និងតាមការសាកសួរព័ត៌មានជាមួយលោកនាយកសាលា លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋក្នុងសហគមន៍ បាបង្ហាញថា ក្នុងចំណោមមាតាបិតា ឬអាណាព្យាបាលរបស់សិស្សបោះបង់ការសិក្សាភាគច្រើនមានការអប់រំតិចតួចបំផុត។ ជាក់ស្ដែង ក្នុងចំណោមមាតាបិតា ឬអាណាព្យាបាលរបស់សិស្សបោះបង់ ដែលអ្នកស្រាវជ្រាវជ្រើសរើសជាគំរូសំណាក៣០នាក់ មាន១៨នាក់ធ្លាប់បានរៀននៅបឋមសិក្សា ៩នាក់ធ្លាប់បានរៀននៅមធ្យមសិក្សាបឋមភូមិ និងមានតែ៣នាក់ប៉ុណ្ណោះ ដែលធ្លាប់បានរៀននៅធ្យមសិក្សាទុតិយភូមិ។ ដូច្នេះ បើសង្កេតជាទូទៅ មាតាបិតារបស់សិស្សដែលមានការអប់រំខ្ពស់មានអត្រាកូនបោះបង់ការសិក្សាទាបជាង ឪពុកម្ដាយរបស់សិស្សដែលមានការអប់រំទាប។

### ៤.៣.២ កត្តាសាលារៀន និងសង្គម

<u>កត្តាសាលារៀន</u>

បរិស្ថានសាលារៀនល្អ សាលារៀនមានគ្រប់កម្រិតថ្នាក់ សាលារៀនមានសម្ភារៈគ្រប់គ្រាន់ សម្រាប់បម្រើឱ្យការបង្រៀន និងរៀន វាជាកត្តាមួយធ្វើឱ្យសិស្សភាគច្រើនបានរៀនចប់ភូមិសិក្សា និងអាចបន្តការសិក្សាទៅភូមិសិក្សាដែលខ្ពស់ជាងទៀត។ ម្យ៉ាងទៀត សាលារៀនត្រូវមានអគារសិក្សាគ្រប់គ្រាន់ សម្រាប់សិស្សរៀនបានគ្រប់ម៉ោងកំណត់របស់ក្រសួង និងអាចឈានដល់ការពង្រឹងគុណភាពអប់រំថែមទៀត។

លោក នាយកបឋមសិក្សាមួយបានមាន ប្រសាសន៍ថា៖

*"កាលពីប៉ុន្មានឆ្នាំមុនសាលាបឋមសិក្សារបស់ខ្ញុំ ខ្វះអគារសិក្សា អគារខ្លះចាស់ទ្រុឌទ្រោម ធ្វើឱ្យការរៀនសូត្ររបស់សិស្ស មិនគ្រប់ម៉ោងកំណត់របស់ក្រសួង ។ ចំនួនសិស្សក្នុងថ្នាក់នីមួយៗមានចំនួនច្រើន តុកៅអីក៏ខ្វះ ធ្វើឱ្យការបង្រៀន និងរៀន មិនសូវមានប្រសិទ្ធភាព។ សិស្សខ្លះស្ដាប់គ្រូពន្យល់មេរៀនមិនបាន នាំឱ្យមានការប្រឡងឡើងថ្នាក់ និងត្រួតថ្នាក់ច្រើន ដែលសិស្សទាំងនេះមួយចំនួនធំត្រូវបោះបង់ការសិក្សាចោល" ។*

<u>ប្រភពសម្ភាស</u> ១៥ កក្កដា ២០១៩។

សុន្ទរកថារបស់ មន្ត្រីអប់រំ ឆ្នាំ២០១៤ បានថ្លែងថា មូលហេតុបោះបង់ការសិក្សានៅបឋមសិក្សា មកពីសាលារៀនមិនគ្រប់កម្រិតថ្នាក់។ ដូច្នេះ បរិស្ថានសាលារៀនមិនល្អ ការខ្វះអាគារសិក្សាក៏ជាមូលហេតុមួយដែរ ដែលធ្វើឱ្យសិស្សបោះបង់ការសិក្សា។

<u>កត្តាសង្គម</u>

ប្រាក់បៀវត្សគ្រូបង្រៀននៅទាបមិនអាចទ្រទ្រង់ជីវភាពគ្រួសារគាត់បាន។ ដូច្នេះ គ្រូបង្រៀនត្រូវស្វែងរកប្រាក់កម្រៃក្រៅដើម្បីបំពេញការខ្វះខាត ដូចជា បង្រៀនគួរក្រៅម៉ោង រត់ម៉ូតូឌុប ជួយលក់ដូរប្រពន្ធ ធ្វើស្រែចម្ការ ចិញ្ចឹមសត្វ ដែលធ្វើឱ្យការបំពេញការងាររបស់ពួកគាត់មានការខ្វះចន្លោះ។

ម្យ៉ាងទៀត រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា មិនទាន់អាចរកការងារឱ្យសិស្ស និស្សិតដែលទើបតែបញ្ចប់ការសិក្សា សមស្របតាមសមត្ថភាពរបស់គេឡើយ។ ចំណែកការផ្តល់គ្រូដែលទើបចេញថ្មី ទៅសាលារៀនតាមជនបទ និងតំបន់ជួបការលំបាក នៅតែមានការខ្វះខាតច្រើនដោយគ្រូភាគច្រើនប្រមូលផ្តុំតែនៅតាមទីប្រជុំជន ទីរួមខេត្ត និងរាជធានីភ្នំពេញ។

### ៤.៣.៣ កត្តាសិស្សផ្ទាល់

ការសិក្សាស្រាវជ្រាវមុនៗមិនសូវ បានបង្ហាញអំពីកត្តាសិស្សផ្ទាល់ទេ។ ប៉ុន្តែការសិក្សានេះខ្ញុំសូមលើកយកបញ្ហាបោះបង់ការសិក្សារបស់សិស្សមួយចំនួនពាក់ព័ន្ធនឹងខ្លួនគេផ្ទាល់។ តាមការអង្កេតផ្ទាល់បានបង្ហាញថា សិស្សមួយចំនួនមិនយកចិត្តទុកដាក់ក្នុងការរៀនសូត្រ ធ្វើឱ្យការសិក្សារបស់គេខ្សោយ។ មួយចំនួនចេញឱ្យផុតតែពីផ្ទះ រួចគេចដើរលេងជាមួយមិត្តភក្តិមិនល្អ ចួនកាលបង្កទំនាស់ឬ បង្កស្នាមរបួសដល់អ្នកដទៃ នាំឱ្យក្រុមគ្រួសារមានការលំបាកខ្លាំង។ ខ្លះទៀតបានបង្ខំទារប្រាក់ ឬរបស់មានតម្លៃពីមាតាបិតា យកទៅចាយវាយ ឬប្រព្រឹត្តអំពើមិនគប្បីដែលសង្គមស្អប់ខ្ពើម។

# ជំពូកទី៥៖

# សន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥៖

# សន្និដ្ឋាន និងសំណូមពរ

## ៥.១ សង្ខេបរបកគំហើញ

### ៥.១.១ កត្តាជីវភាពគ្រួសារ (ភាពក្រីក្រ)

ភាពក្រីកជាឧបសគ្គមួយចំពោះការអប់រំ សម្រាប់កុមារ និងយុវជន នៅក្នុងប្រទេសកម្ពុជា។ គ្រួសារក្រីក្រតម្រូវឱ្យកូនរបស់ពួកគេជួយធ្វើការងារផ្ទះ និងធ្វើការងាររកប្រាក់ចំណូល ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ មិនតែប៉ុណ្ណោះ គ្រួសារក្រីក្រខ្លះបានឱ្យកូនរបស់ពួកគាត់ជាអ្នករកស៊ីចិញ្ចឹមគ្រួសារទៀតផង។ តាមលទ្ធផលសម្ភាសបានបង្ហាញថា៨០%នៃសិស្សបោះបង់ការសិក្សាដែលជាសំណាកគំរូ បានឆ្លើយថាពួកគេបោះបង់ការសិក្សាដោយពួកគេទៅធ្វើការងាររកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ចំណែកមាតាបិតា ឬអាណាព្យាបាលដែលមានកូនបោះបង់ការសិក្សា៧៩,៣% បានឯកភាពថាការបោះបង់ការសិក្សារបស់កូនគឺបណ្តាលមកពីប្រាក់ចំណូលប្រចាំថ្ងៃ និងប្រចាំឆ្នាំរបស់គ្រួសារមិនគ្រាន់ក្នុងការចំណាយ។ ម្យ៉ាងទៀត ទោះបីជាការសិក្សានៅមធ្យមសិក្សារដ្ឋមិនតម្រូវឱ្យបង់ប្រាក់យ៉ាងណាក៏ដោយ ក៏ការចំណាយរបស់មាតាបិតា សម្រាប់ឱ្យកូនសិក្សានៅតែមានកម្រិតខ្ពស់ដដែល ដូចជាសម្លៀកបំពាក់ ទិញសម្ភារៈសិក្សា បង់ការរៀនបន្ថែមក្រៅម៉ោង ប្រាក់សម្រាប់ចាយនៅសាលា និងការរៃអង្គាសផ្សេងៗទៀត។

### ៥.១.២ បញ្ហាអាយុ និងភេទ

តាមការសាកសួរផ្ទាល់ជាមួយលោកយកសាលា លោកគ្រូ អ្នកគ្រូ និងតាមការអង្កេតផ្ទាល់របស់អ្នកស្រាវជ្រាវ ឃើញថាសិស្សបោះបង់ការសិក្សាភាគច្រើនជាសិស្សស្រី និងសិស្សដែលមានអាយុច្រើន។ ទោះបីជាគោលនយោបាយអប់រំបានកំណត់ថាការចូលរៀនប្រកបដោយសមភាព និងសមធម៌ យ៉ាងណាក៏ដោយ ក៏សិស្សនៅបឋមសិក្សាមានអត្រារួម និងអត្រាតពិតនៃការសិក្សាតិចជាងសិស្សប្រុសដែរ។ ម្យ៉ាងទៀត សិស្សស្រី និងសិស្សដែលមានអាយុច្រើនជាអ្នកដែលមានភារកិច្ចថែទាំប្អូន ជួយធ្វើការងារផ្ទះ និង ធ្វើការរកកម្រៃដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។

### ៥.១.៣ កត្តាសាលារៀន និងសង្គម

រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងដៃគូអភិវឌ្ឍវិស័យអប់រំទាំងអស់ ទាំងអង្គការជាតិ និងអន្តរជាតិបាននឹងកំពុងខិតខំយកចិត្តទុកដាក់អភិវឌ្ឍវិស័យអប់រំនៅកម្ពុជា ទាំងហេដ្ឋារចនាសម្ព័ន្ធ ទាំងធនធានមនុស្ស ទាំងធនធានសម្ភារៈ និងថវិកា។ ទោះបីជាមានការខិតខំយកចិត្តទុកដាក់យ៉ាងណាក៏ដោយ ក៏ការខ្វះខាតក្នុងវិស័យនេះនៅតែមានច្រើនដូចជា សាលារៀនច្រើនខ្វះអគារសិក្សា ខ្វះគ្រូបង្រៀន ខ្វះបង្គន់អនាម័យ ខ្វះណ្តូងទឹក បរិស្ថានមិនល្អ ខ្វះសម្ភារៈសិក្សា ខ្វះសម្ភារៈពិសោធ ខ្វះថវិកាសម្រាប់ដំណើរការសាលារៀន និងជីវភាពគ្រូបង្រៀនខ្វះខាត។ ទាំងអស់នេះក៏ជាមូលហេតុមួយដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សាផងដែរ។ ដូចជាខ្វះអគារសិក្សានាំឱ្យសិស្សក្នុងថ្នាក់ច្រើន(លើសពីនិយាម)និងរៀនច្រើនវេន(២ឬ៣វេន)ក្នុង១ថ្ងៃជាហេតុធ្វើឱ្យសិស្សមានការធុញទ្រាន់ ហើយគ្រូបង្រៀនគ្រប់គ្រងសិស្សមិនបានល្អក្នុងពេលបង្រៀន។ ប្រសិនបើជីវភាពគ្រូបង្រៀនខ្វះខាតវិញ គ្រូបង្រៀនមិនសូវយកចិត្តទុកដាក់ក្នុងការបង្រៀន និងក្នុងការបំពេញភារកិច្ចផ្សេងៗទៀតទេ ពួកគាត់ យកពេលវេលាបង្រៀនទៅធ្វើការងារផ្សេងៗ ដើម្បីរកប្រាក់ចំណូលផ្គត់ផ្គង់ជីវភាពគ្រួសារ។ មិនតែប៉ុណ្ណោះពួកគាត់ខ្លះបង្ខំឱ្យសិស្សរៀនគួរ និងលក់របស់ញ៉ាំ ដែលធ្វើឱ្យសិស្សក្រីក្រមួយចំនួនបង្ខំចិត្តបោះបង់ការសិក្សាមាតាបិតា ពួកគេគ្មានប្រាក់គ្រប់គ្រាន់ដើម្បីចំណាយលើការរៀនសូត្ររបស់កូន។

### ៥.១.៤ កត្តាសិស្សផ្ទាល់ និងមាតាបិតា

មូលហេតុមួយទៀត ដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សា គឺខ្លួនសិស្សផ្ទាល់ និងមាតាបិតា ឬអាណាព្យាបាលសិស្សផ្ទាល់។ តាមការសម្ភាសបានបង្ហាញថា ៥៣,៣% ឆ្លើយថាខ្ញុំបោះបង់ការសិក្សាដោយសារខ្ញុំរៀនខ្សោយ ហើយ៥៨,៦០% បានឆ្លើយថាកូនខ្ញុំបោះបង់ការសិក្សាដោយពួកវារៀនខ្សោយពេក។ ម្យ៉ាងទៀត ការបោះបង់ការសិក្សារបស់សិស្សមួយចំនួន គឺបណ្តាលមកពីមាតាបិតាជាអ្នកសម្រេចចិត្ត (៦៧%) និងមាតាបិតាសិស្សខ្លះទៀត មិនសូវយល់ពីតម្លៃនៃការសិក្សាដោយគាត់គិតថា ទោះជាឲ្យកូនរៀនបន្តទៀតក៏មិនអាចរកការងារល្អធ្វើបានដែរ(៣៩,៥០%) សូម្បីតែជីវភាពគ្រួសារគាត់ ធូរធាអាចឱ្យកូនរៀនបន្តទៀតបានយ៉ាងណាក៏ដោយ។

## ៥.២ សន្និដ្ឋាន

តាមលទ្ធផលសិក្សាស្រាវជ្រាវ ដែលបានមកពីការសម្ភាស ការអង្កេត ការសាកសួរព័ត៌មានពីគ្រប់ភាគីពាក់ព័ន្ធមួយចំនួន(ជំពូក៤) បានបង្ហាញឱ្យឃើញថា សិស្សបោះបង់ការសិក្សាបណ្តាលមកកត្តាជាច្រើនដូចជា កត្តាជីវភាពគ្រួសារក្រី(៤.១.១) កត្តាអាយុ និងភេទ(៤.១.២) កត្តាសាលារៀន និងសង្គម (៤.១.៣) កត្តាសិស្សផ្ទាល់ និងមាតាបិតា(៤.១.៤) កត្តាសាលារៀន និងគ្រូបង្រៀន(៤.២.២)ព្រមទាំងមានកត្តាជាច្រើនផ្សេងៗទៀត។

## ៥.៣ សំណូមពរ

តាមលទ្ធផលសិក្សាស្រាវជ្រាវបានបង្ហាញឱ្យឃើញថា មានមូលហេតុជាច្រើនដែលបណ្តាលឱ្យសិស្សបោះបង់ការសិក្សា។ ដូច្នេះ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ត្រូវរួមគ្នាដោះស្រាយបញ្ហាមួយចំនួនដូចខាងក្រោម៖

- ❖ មាតបិតា ឬអាណាព្យាបាលសិស្ស និងលោកគ្រូ អ្នកគ្រូ ត្រូវមានទំនាក់ទំនងល្អក្នុងការតាមដានការសិក្សា និងអវត្តមានរបស់សិស្ស។
- ❖ លុបបំបាត់ចោលនូវពលកម្មខុសច្បាប់លើកុមារ និងជំទង់
- ❖ លោកគ្រូ អ្នកគ្រូ ត្រូវមានមនសិការវិជ្ជាជីវៈខ្ពស់ លុបបំបាត់ការរៃអង្គាសប្រាក់ ឬគាបសង្កត់ផ្នែកផ្លូវកាយ ផ្លូវចិត្តលើសិស្ស គ្រប់រូបភាព
- ❖ សាលារៀនគួរមានអគារសិក្សា និងមានគ្រូបង្រៀនគ្រប់គ្រាន់ ពិសេសនៅតំបន់ជនបទ តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាល
- ❖ ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រឱ្យបានច្រើន
- ❖ គួរផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់សាលារៀន ដើម្បីឱ្យការប្រើប្រាស់មានប្រសិទ្ធភាព
- ❖ អ្នកសិក្សាក្រោយៗ គួរសិក្សាស្រាវជ្រាវពីផលប៉ះពាល់ដែលបណ្តាលមកពីការបោះបង់ការសិក្សា។

# ឯកសារយោង


1. មន្ទីរអេយក ខេត្តកំពង់ធំសន្និបាទបូកសរុបការវាយតម្លៃការងារអប់រំ ២០១៧-២០១៨
2. ស្ថិតិ និងអាំងឌីកាទ័រមន្ទីរអប់រំខេត្តកំពង់ធំ ២០១៦-២០១៧ ២០១៨-២០១៩
3. មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ២០០២ ស្តីពីពលកម្មកុមារ
4. ADB 2000 តម្រូវការផ្នែសុខាភិបាល និងអប់រំ
5. ក្រសួងអយក ២០០៧ គោលនយោបាយសាលាកុមារមេត្រី
6. រាជរដ្ឋាភិបាលកម្ពុជា ២០០៣ *ផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា ២០០៣-២០១៥*
7. ក្រសួងអយក ២០០៤ *ការស្រាវជ្រាវប្រតិបត្តិអប់រំ*
8. Karen Knight and Macleod, 2004, *Integration of teacher's voices into Education For All in Cambodia.*
9. Ministry of Education, Youth, and Sport,2000,*Report on Assessment of the Functional Literacy Level of Adults Population in Cambodia.*
10. KAPE, 2004, *Educational Operational Research* ,NEP
11. ADB,2005,*SWAP Seminar for Education*
12. Report, 2000, *on the Assessment of the Functional Literature Level of the Adult Population in Cambodia.*
13. Education Management Information System ,2016-2017
14. Ministry of Education, 1990, *Country Paper of the State of Cambodia.*
15. UNESCO ,EFA, 1998
16. Edward B.Fiske (1995) Using Both Hands: *Women and Education in Cambodia* ,ADB
17. UNDP, 2001, *Human Development Report* ,Chapter one
18. T.Husen and T.N. Postlethwait , Intl. *Encyclopedia of Education,* 2nd Vol. 4
19. MoP, 1999, *Cambodia Poverty Assessment.*

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ ៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៃវិទ្យាស្ថានជាតិអប់រំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ [illegible] អយក.វិដក

ថ្ងៃព្រហស្បតិ៍ [illegible] ខែចេត្រ ឆ្នាំ[illegible] ស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០១៩

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៨១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ឧបសម្ព័ន្ធទី២ ៖ លិខិតឧទ្ទេសនាមនិស្សិត ចុះប្រមូលទន្នន័យតាមរាជធានី/ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :** ១១៩ **ខជអ.** ភក

**លិខិតឧទ្ទេសនាម**

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ ភ័ឡុងទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអែល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណារី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត ភ័វុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណាភ័ | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៊ុម សូគ៌ា | ប | ខេត្តកណ្ដាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្ដាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្តាល |
| ២៥ | វ៉ា សុកក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាវស្មី | ប | ខេត្តកណ្តាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈៀន | ប | ខេត្តកណ្តាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណូ | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធី | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ុំ សិរីរដ្ឋ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធិ | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខន្ធរា

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ

-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក

-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

## ឧបសម្ព័ន្ធទី៣ ៖ ចំណារអនុញ្ញាតឱ្យនិស្សិត ចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅ នៅក្នុងខេត្តកំពង់ធំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**
**លេខ :** ១១៩ **ខជអ. ភក**

មន្ទីរអប់រំខេត្តកំពង់ធំ
លេខ: 762
ថ្ងៃទី 29.5.2019 ម៉ោង
បញ្ជូន

### លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអើល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណាវី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ារុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៌ា | ប | ខេត្តកណ្ដាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្ដាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ រង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គឹមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធី | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីរដ្ឋ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធី | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គឹមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

**បណ្ឌិត.សៀង សុវណ្ណារ៉ា**

**កន្លែងទទួល៖**

- សាលារាជធានី-ខេត្តពាក់ព័ន្ធ
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
- មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

[illegible]
[illegible]
"[illegible]"
[illegible] 27/05/2019
[illegible]

អ៊ិត ឧត្តរី

ឧបសម្ព័ន្ធទី៤ ៖ លិខិតឧទ្ទេសនាមគណៈកម្មការ ទទួលខុសត្រូវរួមការពារនិក្ខេបបទ សម្រាប់ ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៦២៩ **អយក.** ប្រក
**(ការសម្ងាត់)**

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វ៉ៃ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឧបសម្ព័ន្ធទី៥ ៖ កម្រងសំណួរសម្រាប់មាតបិតា ឬអាណាព្យាបាល

## កម្រងសំណួរស្ទាបស្ទង់
## លើការបោះបង់ការសិក្សារបស់សិស្សនៅបឋមសិក្សា

## សម្រាប់មាតបិតាសិស្ស

ការផ្តល់ព័ត៌មានរបស់លោក លោកស្រី មានសារៈសំខាន់ណាស់ក្នុងការចូលរួមបំពេញកម្រងសំណួរស្រាវជ្រាវ អំពីការបោះបង់ការសិក្សា របស់កូនចៅលោក លោកស្រី ពីព្រោះលោក លោកស្រីត្រូវបានក្រុមការងារជ្រើសរើសសម្រាប់ជាទុនយកមកវិភាគ និងសិក្សាលើបញ្ហាទាំងឡាយណាដែលកើតមានឡើង ដើម្បីជាគន្លឹះក្នុងការកាត់បន្ថយការបោះបង់នៅបឋមសិក្សា។ គ្រប់ព័ត៌មានដែលទទួលបានពីលោកលោកស្រីនឹងត្រូវរក្សាទុកជាការសម្ងាត់។យើងខ្ញុំសង្ឃឹមថា លោក លោកស្រី នឹងចូលរួមឆ្លើយនូវសំណួរស្រាវជ្រាវនេះដោយស្មោះត្រង់ និងរីករាយបំផុត។

ខេត្ត..................................ក្រុង-ស្រុក..................................ឃុំ..............................ភូមិ......................
ឈ្មោះ...........................................................ភេទ.....................អាយុ.............ឆ្នាំ
ថ្ងៃ ខែ ឆ្នាំ សម្ភាស............./............./..........

### I ស្ថានភាពគ្រួសារ និងប្រវត្តិសិក្សាកូននៅរៀន

១-តើលោក លោកស្រីមានកូនប៉ុន្មាននាក់? ....នាក់ ស្រី...នាក់

២-តើលោក លោកស្រីមានមុខរប..........................................

-មុខរបរបន្ទាប់បន្សំ.......................................................

៣-មុខរបបរប្តី ឬប្រពន្ធ.......................................................

-មុខរបរបន្ទាប់បន្សំ.......................................................

៤-កូនៗរបស់លោកលោកស្រីនៅរៀនប៉ុន្មាននាក់?....នាក់ ឈប់រៀនប៉ុន្មាន...នាក់?

៥-ជីវភាពគ្រួសារៈ

- ចំណូលប្រចាំថ្ងៃជាមធ្យម ☐
- ចំណាយជាមធ្យម ☐
- ប្រភពចំណូល ☐លក់ស្រូវអង្ករ ☐លក់អីវ៉ាន់ ☐លក់បន្លែ ផ្លែឈើ ☐ប្រាក់បៀវត្សរ៍ ☐ផ្សេងៗ

៦-លោក លោកស្រីបានរៀននៅ

☐បឋមសិក្សា ☐មធ្យមសិក្សាបឋមភូមិ ☐មធ្យមសិក្សាទុតិយភូមិ

៧-មធ្យោបាយធ្វើដំណើររបស់កូន ពីផ្ទះទៅសាលារៀន

☐ដើរ ☐ជិះកង់ ☐ជិះម៉ូតូ

ឬមធ្យោបាយផ្សេងទៀត(សូមបញ្ជាក់)................

៨-រយៈពេលធ្វើដំណើររបស់កូនពីផ្ទះទៅសាលារៀន.............(នាទី)

៩-☐កូនអ្នកជាអ្នកសម្រេចចិត្តដោយខ្លួនឯង

☐ឪពុកម្តាយ ជាអ្នកសម្រេចចិត្តឱ្យឈប់រៀន

☐ឪពុកម្តាយ និងកូន ជាអ្នកសម្រេចចិត្តឱ្យឈប់រៀន

១០-ធ្លាប់បានទទួលព័ត៌មានអំពីការសិក្សារបស់កូនដែរឬទេ ?

☐ធ្លាប់ ☐មិនធ្លាប់

បើធ្លាប់ ☐ម្តងម្កាល ☐ញឹកញាប់

១១-ធ្លាប់ទទួលដំណឹងពីសាលារៀន អំពីចំនួនអវត្តមានរបស់កូនដែរឬទេ?

☐ធ្លាប់ ☐មិនធ្លាប់

បើធ្លាប់តាមរយៈអ្វី? ☐សៀវភៅតាមដាន ☐ព្រឹត្តិបត្រពិន្ទុ

☐សេចក្តីជូនដំណឹង ឬតាមមធ្យោបាយផ្សេងទៀត(សូមបញ្ជាក់)......

១២-តើសាលាធ្លាប់បានអញ្ជើញលោក លោកស្រី ចូលរួមដោះស្រាយបញ្ហាអវត្តមាន របស់កូនឬទេ? ☐មិនធ្លាប់ ☐ធ្លាប់ម្តងម្កាល ☐ញឹកញាប់

## II **មូលហេតុដែលបណ្តាលឱ្យកូនបោះបង់ការសិក្សា**

១-ប្រាក់ចំណូលប្រចាំថ្ងៃ ប្រចាំឆ្នាំទាបគ្មានប្រាក់គ្រប់គ្រាន់ក្នុងការចំណាយ

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

២-គ្រួសារគ្មានប្រាក់ចំណាយលើការសិក្សារបស់កូនដូចជាសៀវភៅ ប៊ិក កាបូប

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

៣-ឱ្យកូនឈប់ញឹកញាប់នៅផ្ទះធ្វើការងារ ឬជួយប្រមូលផល

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

៤-ឱ្យកូនឈប់ញឹកញាប់ជួយធ្វើការរកប្រាក់ម្រៃ

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

៥-ការសិក្សាពួកគេខ្សោយពេក

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

៦-គិតថាទោះបីរៀនច្រើនក៏មិនអាចរកការងារបានល្អធ្វើ

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

៧-សាលារៀននៅឆ្ងាយពីផ្ទះ ពិបាកធ្វើដំណើរ ទៅរៀនមិនទាន់ពេលវេលា

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

៨-តាមផ្លូវគ្មានសុវត្ថិភាព លំបាកធ្វើដំណើរ

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

៩-គ្រូនិងអ្នកគ្រប់គ្រងមិនល្អ

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

១០-សុខភាពកូនមិនល្អ

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

១១-កូនមានពិការភាព (គ ថ្លង់...)

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

១២-កូនឆាប់រៀបការ

1☐ឯកភាពទាំងស្រុង 2☐ឯកភាព 3☐មិនឯកភាព

★ជ្រើសរើសមូលហេតុសំខាន់ចំនួន៣ ដែល ....................................................................1

សំខាន់តាមចំណាត់ថ្នាក់ ....................................................................2

....................................................................៣

ឧបសម្ព័ន្ធទី៦ ៖ កម្រងសំណួរសម្រាប់សិស្ស

# កម្រងសំណួរស្ទាបស្ទង់លើ
# ការបោះបង់ការសិក្សានៅបឋមសិក្សា

(សម្រាប់សិស្ស)

ការផ្តល់ព័ត៌មានរបស់ប្អូនមានសារៈសំខាន់ណាស់ក្នុងការចូលរួមបំពេញកម្រងសំណួរស្រាវជ្រាវ អំពីការបោះបង់ការសិក្សា ពីព្រោះប្អូនត្រូវបានក្រុមការងារជ្រើសរើសសម្រាប់ជាទុនយកមកវិភាគ និងសិក្សាលើបញ្ហាទាំងឡាយណាដែលកើតមានឡើងដើម្បីជាគន្លឹះក្នុងការកាត់បន្ថយអត្រាបោះបង់ការសិក្សានៅបឋមសិក្សា។ គ្រប់ព័ត៌មានដែលទទួលបានពីប្អូន នឹងត្រូវរក្សាទុកជាការសម្ងាត់។យើងខ្ញុំសង្ឃឹមថាប្អូនៗ នឹងចូលរួមឆ្លើយនូវសំណួរស្រាវជ្រាវនេះដោយស្មោះត្រង់ និងរីករាយបំផុត។

១-ភេទ □ប្រុស □ស្រី

២-អាយុ..............ឆ្នាំ

៣-ទីលំនៅបច្ចុប្បន្ន:ភូមិ..............................ឃុំ...........................ស្រុក..........................ខេត្ត........

៤-ធ្លាប់រៀននៅបឋមសិក្សា:.......................................................................ថ្នាក់ទី......................

នៅភូមិ...................ខេត្ត.....................ស្រុក..........................ឃុំ..............................

៥-ប្អូនរស់នៅជាមួយ: □ឪពុកម្តាយ □ឪពុក □ម្តាយ ឬរស់ ...............................................................................នៅជាមួយ

៦-តើប្អូនមានបង ប្អូនប៉ុន្មាន? ...នាក់ ប្អូនជាកូនទីប៉ុន្មាន?...

## I ប្រវត្តិសិក្សា

សូមសរសេរចម្លើយ ឬគូសសញ្ញា ☑ នៅក្នុងប្រអប់ចម្លើយដែលប្អូនជ្រើសរើស

១-អាយុពេលឈប់រៀនឆ្នាំ.......................

២-បោះបង់ការសិក្សានៅថ្នាក់ទី................

៣-បោះបង់ការសិក្សានៅឆ្នាំ.....................

៤-មធ្យោបាយធ្វើដំណើរទៅសាលារៀន

1□ ដើរប្រហែលនាទី...........

2□ ជិះកង់ប្រហែលនាទី.......

3□ ជិះម៉ូតូប្រហែលនាទី.......

II **មូលហេតុនៃការបោះបង់**

ខាងក្រមនេះគឺជាមូលហេតុនៃការឈប់រៀ។ គូសសញ្ញា ☑ ក្នុងប្រអប់មុខចម្លើយ ដើម្បីបង្ហាញថាមូលហេតុនីមួយៗជាមូលហេតុសំខាន់ ឬមិនសំខាន់ដែលធ្វើឱ្យប្អូនឈប់រៀន។

| | |
|---|---|
| ១-គ្រួសារខ្ញុំមិនមានប្រាក់សម្រាប់ការរៀន ឬរៀនបន្ថែមក្រៅម៉ោងទេដូចជាប្រាក់ហូបចុកប្រចាំថ្ងៃ ខោអាវ សម្ភារៈសិក្សាផ្សេងទៀត | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |
| ២-ពេលខ្លះមិនបានទៅរៀនដើម្បីធ្វើការងារផ្ទះ ឬជួយប្រមូលផលដំណាំ មើលប្អូន ឃ្វាលគោក្របី ដកស្ទូងច្រូតកាត់ | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |
| ៣-ពេលខ្លះមិនបានទៅរៀនដើម្បីជួយរកប្រាក់ចំណូល ជួយលក់ដូរ ធ្វើស្រែចំការ ស៊ីឈ្នួលដកជំឡូង | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |
| ៤-បរិយាកាសគ្រួសារមិនអំណោយផលការទាស់ទែងឈ្លោះប្រកែកក្នុងគ្រួសារ កំព្រា ឬនៅឆ្ងាយម្ដាយឪពុក | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |
| ៥-ការសិក្សារបស់ខ្ញុំខ្សោយរៀនត្រួតថ្នាក់ច្រើនដង | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |
| ៦-ខ្ញុំគិតថារៀនបន្តទៀតក៏មិនអាចរកការងាបានដែរ | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |
| ៧-សាលារៀននៅឆ្ងាយពីផ្ទះ | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |
| ៨-គ្រួសារខ្ញុំតែងផ្លាស់ទីលំនៅញឹកញាប់ | 1☐ ឯកភាពណាស់<br>2☐ ឯកភាព<br>3☐ មិនឯកភាព |

៩-សាលារៀនមានអគារទ្រុឌទ្រោម 1☐ ឯកភាពណាស់
2☐ ឯកភាព
3☐ មិនឯកភាព

១០-បរិយាការជុំវិញសាលាមិនល្អ (បងតូច បងធំ ល្បែងស៊ីសង...) 1☐ ឯកភាពណាស់
2☐ ឯកភាព
3☐ មិនឯកភាព

១១-សុខភាពមិនល្អ 1☐ ឯកភាពណាស់
2☐ ឯកភាព
3☐ មិនឯកភាព

១២-រៀបការ 1☐ ឯកភាពណាស់
2☐ ឯកភាព
3☐ មិនឯកភាព

- ជ្រើសរើសមូលហេតុសំខាន់ចំនួន៣ ដែលធ្វើឱ្យប្អូនបោះបង់ការសិក្សា

១...............................................................................................

២...............................................................................................

៣...............................................................................................

## III ស្ថានភាពក្រោយពេលបោះបង់

១-តើប្អូនសព្វថ្ងៃធ្វើការងារអ្វី?
1☐ ការងារគ្មានប្រាក់ចំណូល (ឃ្វាលគោ មើលប្អូន...)
2☐ ការងារមានប្រាក់ចំណូល
3☐ មិនមានអ្វីធ្វើច្បាស់លាស់

២-តើធ្លាប់មានមិត្ត ឬគ្រូហៅឱ្យចូលរៀនវិញទេ?
1☐ ធ្លាប់ 2☐ មិនធ្លាប់

៣-តើប្អូនចង់ចូលរៀនវិញទេ?
1☐ ចង់ចូលវិញ 2☐ មិនចង់ចូលវិញ (បញ្ជាក់មូលហេតុ)

.......................................................................................................................

.......................................................................................................................

.......................................................................................................................